00655338

E 51/5/3/1

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

សាធារណៈ / Public

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

**ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អនុលោមតាមវិធាន ៨៩**

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធូ មណី

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ:**
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក ស សូវាន

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 21 / 03 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

E51/5/3/1

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសង*

លោក Jacques VERGÈS
លោក Phillipe GRECIANO
លោក ផាត់ ពៅសៀង
កញ្ញា Diana ELLIS QC

## I. សេចក្តីផ្តើម

១. អនុលោមតាមដីការបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ និង ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១១[1] សហព្រះរាជអាជ្ញា សូមផ្តល់ជូននូវចម្លើយតបរួមទៅនឹង អញ្ញត្រកម្មបឋមរបស់ នួន ជា, អៀង សារី, ខៀវសំផន, និង អៀង ធីរិទ្ធ អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ដូចខាងក្រោមនេះ ៖

២. តាមការស្នើសុំរបស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាបានខិតខំព្យាយាមដើម្បីកំណត់អត្តសញ្ញាណ ទៅលើអញ្ញត្រកម្មបឋមទាំងនោះដែលបានលើកឡើងដោយជនជាប់ចោទ ដែលសារណានៃអញ្ញត្រកម្មទាំងនេះកាលពីមុន ត្រូវបានដាក់ជូនរួចហើយ និងផ្តល់ជូននូវសេចក្តីសង្ខេបមួយអំពីគោលជំហររបស់សហព្រះរាជអាជ្ញា និងការយោងទៅលើឯកសារដែលបានដាក់កាលពីមុនៗ សំរាប់អញ្ញត្រកម្មនានាបែបនេះ។ អញ្ញត្រកម្មបឋមទាំងអស់នេះដែលត្រូវបានឆ្លើយតបតាមលក្ខណៈដូចជា៖ អំពីយុត្តាធិការទូទៅរបស់ អវតក ទៅលើឧក្រិដ្ឋកម្មអន្តរជាតិនានាដែលស្ថិតនៅក្រោមគោលការណ៍ស្តីពីនីត្យានុកូលភាព (ផ្នែកទីII.ក)។ តើឧក្រិដ្ឋកម្មនានាក្រោមច្បាប់ជាតិត្រូវបានរាំងដោយអាជ្ញាយុកាលដែរឬទេ? (ផ្នែកទីII.ខ)។ តើអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរនានាត្រូវបានរាំងដោយអាជ្ញាយុកាលដែរឬទេ? (ផ្នែកទីII.គ)។ ការអនុវត្តនូវសហកម្មឧក្រិដ្ឋកម្មរួម (ផ្នែកទីII.ឃ)។ និង ការទទួលខុសត្រូវរបស់ថ្នាក់លើ ក្នុងទម្រង់ផ្សេងៗនៃការទទួលខុសត្រូវ(ផ្នែកទីII.ង)។ ការអនុវត្តនូវការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ, ការរំលោភសេពសន្ថវៈដែលស្ថិតនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ, ការបាត់ខ្លួនដោយបង្ខំ និងការជម្លៀសចេញដោយបង្ខំ ដែលជា

[1] នីតិវិធីក្នុងការដាក់អញ្ញត្រកម្ម របស់អង្គជំនុំជម្រះសាលាដំបូងដែលត្រូវបានធ្វើវិសោធនកម្ម និងការបញ្ជាក់ឱ្យបានច្បាស់អំពីកាលបរិច្ឆេទកំណត់ដែលគ្រោងទុកជាមុនក្នុងការឆ្លើយតប, ចុះថ្ងៃទី១៤ កុម្ភៈ ២០១១, ឯកសារលេខ E51។ ដីកាសម្រេចលើសំណើរបស់ សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលសុំពន្យារពេល និងចំនួនទំព័របន្ថែមពីលើការកំណត់, ចុះថ្ងៃទី៤ មីនា ២០១១, ឯកសារលេខ E51/5/3 ។

អំពើអមនុស្សធម៌ដទៃទៀត, ព្រមទាំងការឃុំឃាំង និងការធ្វើទារុណកម្ម គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ផ្នែកទីII.ច)។ ការជំទាស់របស់ អៀង សារី ដែលថាការកាត់ទោសគាត់ គឺត្រូវបានហាមឃាត់ដោយព្រះរាជក្រឹត្យឆ្នាំ១៩៩៦ (ផ្នែកទីII.ឆ) និងគោលការណ៍ស្តីពីការកាត់ក្តីពីរដងលើបទល្មើសដដែលតែមួយ (ផ្នែកទីII.ជ)។

៣. សហព្រះរាជអាជ្ញា ក៏សូមឆ្លើយតបផងដែរ ទៅនឹងអញ្ញត្រកម្មបឋមចំនួនបីដែលត្រូវបានលើកឡើងដោយជនជាប់ចោទគឺៈ ទៅនឹងការជំទាស់របស់ ខៀវ សំផន ដែលថាគាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬជាអ្នកទទួលខុសត្រូវខ្ពស់បំផុតដែលស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការនោះទេ (ផ្នែកទីII.ឈ)។ និងការជំទាស់របស់ នួន ជា អំពីភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចស៊ើបសួរ (ផ្នែកទីII.ញ) និងអំពីនីត្យានុកូលភាពនៃវិធានផ្ទៃក្នុងរបស់ អវតក និងដីការបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីដាក់សម្ភារៈក្នុងការរៀបចំសវនាការ (ផ្នែកទីII.ដ)។

៤. សហព្រះរាជអាជ្ញា សង្កេតឃើញថា ផ្ទុយពីដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ការដាក់ឯកសាររបស់ អៀង សារី អនុលោមតាមវិធាន៨៩ នៃវិធានផ្ទៃក្នុង ខកខានមិនបានផ្តល់សេចក្តីសង្ខេប ឬសេចក្តីថ្លែងអំពីអញ្ញត្រកម្មបឋមរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ ហើយផ្ទុយទៅវិញ គឺគ្រាន់តែធ្វើជាបញ្ជីសាមញ្ញនានាអំពីការដាក់ឯកសារកាលពីមុនៗរបស់គាត់តែប៉ុណ្ណោះ។ ឧទាហរណ៍ដូចជា មានអញ្ញត្រកម្មមួយក្នុងចំណោមអញ្ញត្រកម្មបឋមរបស់គាត់គ្រាន់តែនិយាយថា"អវតក គ្មានយុត្តាធិការដើម្បីអនុវត្តឧក្រិដ្ឋកម្មនានាក្រោមច្បាប់អន្តរជាតិ និងទម្រង់ផ្សេងៗនៃការទទួលខុសត្រូវឡើយ" បន្ទាប់មកទៀតបានលើកសំអាងដែលមានចំនួន២៨០ទំព័រ ទៅលើឯកសារដែលបានដាក់កាលពីមុនចំនួនប្រាំមួយ[2]។ ការខកខានរបស់ អៀង សារី ក្នុងការលើកឡើងឱ្យបានគ្រប់គ្រាន់អំពីថាអញ្ញត្រកម្មបឋមរបស់គាត់ មិនអាចបន្ទោសថាមកពីការកំណត់ចំនួនទំព័ររបស់អង្គជំនុំជម្រះសាលា

[2] សេចក្តីសង្ខេបនៃអញ្ញត្រកម្មបឋមរបស់ អៀង សារី, ចុះថ្ងៃទី២៥ កុម្ភៈ ២០១១ , ឯកសារលេខ E51/4 , កថាខណ្ឌទី២៤។

00655342



ដំបូងបានឡើយ ដោយគាត់គ្រាន់តែប្រើត្រឹមតែ១៥ទំព័រ នៃ៣៥ទំព័រ ដែលត្រូវបានអនុញ្ញាតឱ្យគាត់តែប៉ុណ្ណោះ[3] ហើយសុខចិត្តលះបង់៩ទំព័រ ក្នុងចំណោម១៥ទំព័រ ដើម្បីប្តឹងតវ៉ាអំពីនីតិវិធី និងសេចក្តីបង្គាប់នៃការដាក់ឯកសាររបស់អង្គជំនុំជម្រះទៅវិញ។ ដោយសារតែការខកខានរបស់មេធាវី អៀង សារី ក្នុងការអនុវត្តតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះនៅក្នុងករណីជាច្រើននេះហើយ ទើបបានជាមិនអាចដឹងពិតប្រាកដអំពីការជំទាស់ជាក់លាក់ផ្សេងៗ ដែលគាត់ចង់លើកឡើងនោះទេ។ ចំណែកឯសហព្រះរាជអាជ្ញាវិញ បានយកអស់លទ្ធភាពរបស់ខ្លួនក្នុងវង្វង់នៃពេលវេលា និងចំនួនទំព័រដែលកំណត់ឱ្យដើម្បីធ្វើអត្ថសញ្ញាណកម្ម និងឆ្លើយតបទៅនឹងអញ្ញត្រកម្មបឋមរបស់ជនជាប់-ចោទទាំងនេះ ទោះជាយ៉ាងណាក្តី សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង មិនគួរពិចារណាចំពោះអញ្ញត្រកម្មណាមួយដែលមិនបានលើកឡើងច្បាស់លាស់ ហើយគ្រាន់តែជាសេចក្តីសង្ខេប ដូចនៅក្នុងការដាក់ឯកសាររបស់ជនជាប់ចោទអនុលោមតាមវិធាន៨៩ នៃវិធានផ្ទៃក្នុងនេះទេ។

## II. អំណះអំណាង

### ក. យុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មអន្តរជាតិ

៥. ជារួម ចំពោះអញ្ញត្រកម្មដែលបានដាក់ដោយជនជាប់ចោទទាំងបួននាក់នោះ គឺសុទ្ធតែជាអំណះអំណាង ដែលផ្អែកលើការផ្តាច់ឱ្យដាច់ចេញពីគ្នារវាងប្រព័ន្ធច្បាប់ជាតិ និងប្រព័ន្ធច្បាប់អន្តរជាតិ និងអ្វីដែលគេហៅថា គោលការណ៍ជាតិស្តីពីនីត្យានុកូលភាព[4]។ ជនជាប់ចោទសន្និដ្ឋានថា សូម្បីតែ

[3] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីចំនួនទំព័រកំណត់សម្រាប់ការដាក់អញ្ញត្រកម្មបឋមចុះថ្ងៃទី២២ កុម្ភៈ ២០១១៖ ដីកាបង្គាប់ទៅមេធាវីរបស់ អៀង សារី ស្តីពីការដាក់អញ្ញត្រកម្មបឋម, ចុះថ្ងៃទី២៥ កុម្ភៈ ២០១១,ឯកសារលេខ E51/6។

[4] ដោយសារបញ្ហាការកំណត់ចំនួនទំព័រ សហព្រះរាជអាជ្ញាផ្តល់នូវទិដ្ឋភាពជារួមអំពីអំណះអំណាងទាំងនេះ ហើយកត់សំគាល់ឃើញថា ធាតុផ្សំជារួមដែលជនជាប់ចោទម្នាក់ៗបានពឹងផ្អែក ទោះយ៉ាងណាក៏ដោយ បានប្រើពាក្យខុសៗគ្នា ។ អំណះអំណាងទាំងនេះមាននៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ២៥ តុលា ២០១០, D427/1/6, កថាខណ្ឌទី១០៣-១៣៧ និង ១៨០-២៣១ ។ ចម្លើយតបរបស់ អៀង សារី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវ ("ឧក្រិដ្ឋកម្មអន្តរជាតិ") ដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិនៅក្នុងអម្លុងពេល ដែលគ្របដណ្តប់ដោយដីកាដំណោះស្រាយ ("អម្លុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ") នោះក៏ដោយ ក៏មិនអាចយកមកអនុវត្តនៅប្រទេសកម្ពុជាបានដែរ។ យោងតាមជនជាប់ចោទថា ដោយសារពុំមានច្បាប់ជាតិត្រូវបានអនុម័តដើម្បីបញ្ចូលគោលការណ៍ទាំងនេះទៅក្នុងច្បាប់របស់កម្ពុជា[5] នោះច្បាប់តែមួយគត់ដែលអាចអនុវត្តបាន គឺក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ ពួកគេធ្វើការសន្និដ្ឋានបន្ថែមទៀតថា ការអនុញ្ញាតឱ្យមានយុត្តាធិការទៅលើឧក្រិដ្ឋកម្មអន្តរជាតិនានាដល់ អ.វ.ត.ក គឺជាការបំពានលើគោលការណ៍នីត្យានុកូលភាពជាតិ ដែល

ប្រឆាំងនឹងដីកាដំណោះស្រាយ, ៦ ធ្នូ ២០១០, D427/1/23, កថាខណ្ឌទី៦៤-១១១ ។ ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅ អ.វ.ត.ក, ៣០ តុលា ២០០៩, D240, កថាខណ្ឌទី១៣-៣៤ ។ ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក, ១៣ មេសា ២០១០, D378, កថាខណ្ឌទី១១-២៤។ ជម្រើសមួយញត្តិស្នើសុំរបស់ អៀង សារី អំពីការកម្រិតលើការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅ អ.វ.ត.ក, ២៣ មិថុនា ២០១០, D378/2, កថាខណ្ឌទី១-២៦ ។ ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ នៅ អ.វ.ត.ក, ៧ ឧសភា ២០១០, D379, កថាខណ្ឌទី១-២៨ ។ ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក លើទម្រង់នៃការទទួលខុសត្រូវ ដែលគេស្គាល់ថា សហកម្មឧក្រិដ្ឋកម្មរួម, ២៨ កក្កដា ២០០៨, D97, កថាខណ្ឌទី១-៣៣ ។ ចម្លើយតបរបស់ អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ពាពរអនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម របស់សហព្រះរាជអាជ្ញា, ១ កញ្ញា ២០១០, D390/1/2/1.3, កថាខណ្ឌទី២៩-៧០ ។ អញ្ញត្រកម្មបឋមរបស់ អៀង សារី អនុលោមតាមវិធាន៨៩ (អាជ្ញាយុកាលសម្រាប់អំពើបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ), ១៤ កុម្ភៈ ២០១១, E43, កថាខណ្ឌទី១-៩ ។ ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួររបស់ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងការបាត់ខ្លួនមនុស្សដោយបង្ខំ និងសំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់, ៦ សីហា ២០០៩, D180/4, កថាខណ្ឌទី១-៣៧ ។ ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួររបស់ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ, ១១ សីហា ២០០៩, D188/3, កថាខណ្ឌទី១-៣២ ។ អញ្ញត្រកម្មបឋមរួមបញ្ចូលគ្នា, ២៥ កុម្ភៈ ២០១១, E51/3, កថាខណ្ឌទី៤១-៥៦ ។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៨ តុលា ២០១០, កថាខណ្ឌទី២៣-៣៨ ។ ចម្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ៦ ធ្នូ ២០១០, D427/3/11, កថាខណ្ឌទី៦-១៦ ។ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ចេញពីដីកាដំណោះស្រាយ, ១៨ តុលា ២០១០, D427/2/1, កថាខណ្ឌទី៦-៩៤។ ចម្លើយតបរបស់មេធាវីការពារក្តី ទៅនឹងចម្លើយតបរួមរបស់អយ្យការទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ៦ ធ្នូ ២០១០, D427/2/11, កថាណ្ឌទី៣២-៦៩។ អញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ, ១៤ កុម្ភៈ ២០១១, E44, កថាខណ្ឌទី៩-១៩។ Exceptions Préliminaires Portant Sur la Competence, ១៤ កុម្ភៈ ២០១១, E46, កថាខណ្ឌទី៣-៣៣។ Exceptions Préliminaires Portant Sur léxtinction de l'action Publique (Crimes Nationaux), ១៤ កុម្ភៈ ២០១១, E47, កថាខណ្ឌទី៨-២៤ ។

[5] អៀង សារី ក៏ធ្វើការសន្និដ្ឋានដែរថា ច្បាប់អន្តរជាតិអាចអនុវត្តនៅក្នុងប្រទេសបាន បើសិនច្បាប់រដ្ឋធម្មនុញ្ញអនុញ្ញាត ឬក្នុងករណីអនុសញ្ញាស្វ័យអនុវត្ត។

បានរកឃើញនៅក្នុងមាត្រា៦ នៃក្រមព្រហ្មទណ្ឌនេះ។ ពួកគេអះអាងថា គោលការណ៍នេះមានអាទិភាពលើគោលការណ៍នីត្យានុកូលភាពអន្តរជាតិ ដែលមានចែងនៅក្នុងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPC) ដូចជាការលើកលែងដែលបានរកឃើញនៅក្នុងកតិកាសញ្ញានេះមិនអាចអនុវត្តបានទេ។ ជាបច្ច័យចំពោះអំណះអំណាងទាំងនេះ គឺជាការអះអាងថា អ.វ.ត.ក ជាតុលាការក្នុងស្រុកមួយ ដែលមិនអនុវត្តច្បាប់អន្តរជាតិដោយមិនបានបញ្ចូលទៅក្នុងយុត្តាធិការរបស់កម្ពុជាក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ។

៦. សហព្រះរាជអាជ្ញាសន្និដ្ឋានថា អញ្ញត្រកម្មបឋមទាំងនេះ គួរត្រូវបានច្រានចោល ដោយផ្អែកលើមូលហេតុដូចតទៅ៖

(ក) ឧក្រិដ្ឋកម្មបានបង្កើតជាផ្នែកនៃច្បាប់អន្តរជាតិ នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលជនជាប់ចោទអាចរកបាន។ គេអាចព្យាករណ៍បានជាមុនចំពោះជនជាប់ចោទនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យថា ពួកគេអាចត្រូវបានចោទប្រកាន់ចំពោះបទឧក្រិដ្ឋទាំងនេះ។

(ខ) អ.វ.ត.ក អាចអនុវត្តបានយ៉ាងត្រឹមត្រូវចំពោះយុត្តាធិការទៅលើឧក្រិដ្ឋកម្មអន្តរជាតិនានា ដោយសារ៖ (១) ច្បាប់ អ.វ.ត.ក ដែលបានផ្តល់យុត្តាធិការនេះឱ្យតុលាការគឺត្រឹមត្រូវតាម រដ្ឋធម្មនុញ្ញ និងស្របតាមលិខិតុបករណ៍សិទ្ធិមនុស្សដែលនៅជាធរមាននៅកម្ពុជា និង (២)ការអនុម័ត និងប្រតិបត្តិការនៃច្បាប់ អ.វ.ត.ក ទោះក្នុងមធ្យោបាយណាក៏ដោយ ក៏មិនត្រូវ បានរាំងដោយអ្វីដែលគេហៅថា គោលការណ៍នីត្យានុកូលជាតិ ដែលថាបានរកឃើញនៅក្នុងមាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នោះដែរ។

(គ) ទោះបីសហព្រះរាជអាជ្ញានៅតែរក្សាជំហរថា អ.វ.ត.ក គឺជាតុលាការកូនកាត់ដែលមានលក្ខណៈជាអន្តរជាតិក៏ដោយ តាមស្មារតីនៃភាសាច្បាស់លាស់នៃច្បាប់ អ.វ.ត.ក ឋានៈរបស់តុលាការនេះគឺមិនពាក់ព័ន្ធគ្នាទេ សម្រាប់គោលបំណងនៃការកំណត់អំពីថាតើ ច្បាប់ណាមួយដែលអាចអនុវត្តបាននៅចំពោះមុខខ្លួននោះ។

៧. ទាក់ទងមាត្រា៦ នេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា៖

(ក) មាត្រានេះ គួរត្រូវបានអានដែលអនុវត្តចំពោះតែក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ខ្លួនវាប៉ុណ្ណោះ។ ដោយសារអវត្តមាននៃភាសាជាក់លាក់ដែលចែងថា គ្រប់ច្បាប់ផ្សេងទៀតទាំងអស់ត្រូវតែអនុលោមតាមក្រមនេះ នោះគេគ្មានមូលដ្ឋានអ្វីដើម្បីសន្និដ្ឋានថា ច្បាប់នេះមានបំណងដើម្បីបានទទួលនូវអានុភាពដូច្នេះទេ។

(ខ) ផ្សេងពីនេះ បើសិនជាមាត្រា៦ នេះ មានចេតនាដើម្បីអនុវត្តចំពោះច្បាប់ដទៃទៀតនោះវាមិនអនុវត្តចំពោះច្បាប់ អ.វ.ត.ក ទេ ដោយហេតុថា ច្បាប់ អ.វ.ត.ក ពុំមែនជា "ក្រមព្រហ្មទណ្ឌ" ប៉ុន្តែជាច្បាប់ផ្តល់យុត្តាធិការទាក់ទងនឹងឧក្រិដ្ឋកម្មទាំងឡាយដែលបានកើតឡើងរួចហើយ[6] ។

(គ) ជាការបន្ថែម និងតាមរបៀបផ្សេង មិនថាមាត្រា៦ មានចេតនាផ្តល់អត្ថន័យ ឬវិសាលភាពប៉ុណ្ណាទេ ដែលជាច្បាប់សាមញ្ញមួយអនុម័តដោយអង្គនីតិបញ្ញត្តិ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនអាចដាក់កំហិតទៅលើលទ្ធភាពរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការអនុម័តច្បាប់ដទៃទៀត

---

[6] ស្រដៀងគ្នានេះដែរ បើសិនច្បាប់អន្តរជាតិអាចត្រូវបានពិចារណាថា "ជាច្បាប់ព្រហ្មទណ្ឌ" លើកលែងតែមានចែងសម្រាប់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ, មិនមែនអនុវត្តដោយសារ "អានុភាពប្រតិសកម្ម" នោះទេ ដោយហេតុថា បទល្មើសបានកើតមានឡើងក្នុងឆ្នាំ១៩៧៥ រួចទៅហើយ។

ឡើយ។ ក្នុងការអនុវត្តអំណាចនីតិបញ្ញត្តិក្នុងអធិបតេយ្យភាពរបស់ខ្លួន អង្គនីតិបញ្ញត្តិកម្ពុជាមានសេរីភាពក្នុងការអនុម័តច្បាប់ថ្មីៗដោយងាកចេញពី ឬធ្វើការកែប្រែអានុភាព នៃមាត្រា៦។ ច្បាប់ អ.វ.ត.ក ជាច្បាប់កើតមាននាពេលក្រោយមក និង*ជាច្បាប់លក្ខន្តិកៈពិសេស (Lex specialis)* នៅលើបញ្ហាឧក្រិដ្ឋកម្មអន្តរជាតិ មានអាទិភាពលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អំពីភាពមិនស៊ីសង្វាក់គ្នានៃច្បាប់។

៨. ដូចដែលជនជាប់ចោទ កំពុងតែស្វែងរកការតវ៉ាអំពីសុពលភាពនៃច្បាប់ អ.វ.ត.ក (ឬអំពីការផ្តល់អំណាចផ្នែកយុត្តាធិការនៅ អ.វ.ត.ក) សហព្រះរាជអាជ្ញាសន្និដ្ឋានថា មធ្យោបាយតែមួយគត់សម្រាប់ការជំទាស់តវ៉ា គឺរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ដែនដីប៉ុណ្ណោះ[7]។ គ្មានរដ្ឋធម្មនុញ្ញជាធរមាន[8] (ទាំងរបស់កម្ពុជាប្រជាធិបតេយ្យ និងរដ្ឋធម្មនុញ្ញបច្ចុប្បន្ននេះផង) មានបទប្បញ្ញត្តិជាក់លាក់ពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាពទេ។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្នដែលបានប្រកាសឱ្យប្រើក្នុងឆ្នាំ១៩៩៣ និងនៅជាធរមានក្នុងពេលអនុម័តច្បាប់ អ.វ.ត.ក នៅត្រង់ផ្នែកដែលពាក់ព័ន្ធចែងថា ៖

"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។

---

[7] មាត្រា១៥០ នៃរដ្ឋធម្មនុញ្ញ ចែងថាៈ "រដ្ឋធម្មនុញ្ញនេះ ជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ហើយច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត" ។

[8] ដូចសហព្រះរាជអាជ្ញា បានចង្អុលបង្ហាញនៅក្នុងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ នៃសាធារណរដ្ឋខ្មែរ បញ្ឈប់លែងមានអានុភាពបន្តទៅទៀតនៅពេលដួលរលំរបបសាធារណរដ្ឋខ្មែរ នៅថ្ងៃទី១៧ មេសា ១៩៧៥។ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៩ វិច្ឆិកា ២០១០, D427/3/6, កថាខណ្ឌទី១៦៥ ("ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ") ។

00655347



៩. ក្នុងពេលដែលរដ្ឋធម្មនុញ្ញនេះត្រូវបានប្រកាសឱ្យប្រើ កម្ពុជាគឺជាភាគីនៃកតិកាសញ្ញា ICCPR រួចទៅហើយ[9]។ អ្នកតាក់តែងរដ្ឋធម្មនុញ្ញ បានជ្រើសរើសមិនដាក់បញ្ចូលបទប្បញ្ញត្តិជាក់លាក់ស្តីពីគោលការណ៍នីត្យានុកូលភាពនៅក្នុងរដ្ឋធម្មនុញ្ញទេ ប៉ុន្តែជាជំនួសមកវិញ បានជ្រើសយកការប្តេជ្ញាចិត្តដើម្បីអនុវត្តតាមកតិកាសញ្ញា ICCPR ដែលមានដាក់បញ្ចូលគោលការណ៍នេះ ។ ការណ៍នេះត្រូវបានបញ្ជាក់អះអាងយ៉ាងច្បាស់ តាមរយៈការចែងកំណត់អំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញ ខណៈដែលសិទ្ធិផ្សេងទៀតអាចអនុវត្តបានតាមសេចក្តីយោងទៅលើមាត្រា៣១[10]។ ដោយស្របទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ អ.វ.ត.ក តម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តតាមគោលការណ៍នីត្យានុកូលភាពដែលបានចែងនៅក្នុងមាត្រា១៥ នៃកតិកាសញ្ញា ICCPR[11] ។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះបានធ្វើការសន្និដ្ឋានដោយត្រឹមត្រូវថា គោលការណ៍នីត្យានុកូលភាពចំពោះឧក្រិដ្ឋកម្មអន្តរជាតិដែលអង្គជំនុំជម្រះនេះមានយុត្តាធិការទៅលើនោះ គឺបានរកឃើញនៅក្នុងកតិកាសញ្ញា ICCPR នេះ[12] ។

១០. ដោយបានពិចារណាយ៉ាងជាក់ច្បាស់លើបញ្ហា "គ្មានប្រតិសកម្ម" ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានសម្រេចថា ច្បាប់ អ.វ.ត.ក គឺស្របទៅនឹងរដ្ឋធម្មនុញ្ញ[13]។ នៅចំពោះមុខអង្គជំនុំជម្រះនេះ និងក៏ដូចជានៅចំពោះមុខអង្គបុរេជំនុំជម្រះដែរ គ្មានជនជាប់ចោទណាម្នាក់ធ្លាប់បានចោទសួរអំពីការរកឃើញនេះទេ[14]។ ផ្ទុយមកវិញ ពួកគេបានព្យាយាមយ៉ាងមានប្រសិទ្ធភាពដើម្បីលើកឡើងពីឋានៈនៃមាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ទៅនឹងបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញដែលមានឧត្តមភាពលើ

[9] កម្ពុជាផ្តល់សច្ចាប័នលើកតិកាសញ្ញានេះ ក្នុងឆ្នាំ១៩៩២។ *សូមអាន* ឋានៈនៃការធ្វើសច្ចាប័ននេះ ក្នុងគេហទំព័រ: http://www.ccprcentre.org/doc/ICCPR/Status%20ICCPR.pdf.

[10] សម្រាប់បទប្បញ្ញត្តិដែលចែងអំពីសិទ្ធិជាក់លាក់ សូមអានមាត្រា៣២, ៣៣, ៣៤ថ្មី, ៣៦, ៣៧ និង៤០-៤៦ ។

[11] មាត្រា៣៣ថ្មី នៃច្បាប់ អ.វ.ត.ក ។

[12] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ,១៥ កុម្ភៈ ២០១១, D427/3/15,កថាខណ្ឌ៩៩។

[13] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ 040/002/2001, ១២ កុម្ភៈ ២០០១។

[14] ជាការពិត សេចក្តីសម្រេចរបស់ក្រុមប្រឹក្សានេះចូលជាស្ថាពរហើយៈ មាត្រា១៤២ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។

ច្បាប់ដទៃ (ដូចជាច្បាប់ អ.វ.ត.ក នេះជាដើម)។ យ៉ាងណាមិញ ដូចបានបង្ហាញពីខាងលើ គេគ្មានមូលដ្ឋានផ្លូវច្បាប់ដើម្បីអនុវត្តក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ក្នុងរបៀបដូច្នេះឡើយ[15]។

១១. នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ អំណះអំណាងនានាពាក់ព័ន្ធទៅនឹងដំណើរការប្រព្រឹត្តិទៅនៃ អវតក ដែលត្រូវបានចោទថាប្រតិសកម្ម គឺត្រូវបានដាក់ខុសកន្លែង។ ដូចអង្គបុរេជំនុំជម្រះបានរកឃើញនៅក្នុងសេចក្តីសម្រេចដំបូងរបស់ខ្លួន លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ច្បាប់ អវតក គ្រាន់តែផ្តល់ជាយានមួយសម្រាប់ការស៊ើបអង្កេតលើឧក្រិដ្ឋកម្មនានា ដែលមានអត្ថិភាពក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវជាប់កាតព្វកិច្ចក្នុងការធ្វើការកាត់សេចក្តី[16]។ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញនៅក្នុងសំណុំរឿងលេខ ០០១ ថាបទល្មើសនានាដែលមាននៅក្នុងមាត្រា ៥ និង ៦ នៃច្បាប់ អវតក (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាអន្តរជាតិទីក្រុងហ្សឺណែវ) បង្កើតបានជាឧក្រិដ្ឋកម្មនានានៅក្រោមច្បាប់អន្តរជាតិក្នុងអំឡុងពេលពាក់ព័ន្ធនោះ ហើយថាការដាក់ឱ្យអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះនេះ គឺត្រូវគ្នាទៅនឹងគោលការណ៍នីត្យានុកូលភាព[17]។ អាស្រ័យហេតុដូច្នេះ វាមិនមានឧក្រិដ្ឋភាវូនីយកម្មជាប្រតិសកម្មនៃការប្រព្រឹត្តិណាមួយនោះទេ ហើយជនជាប់ចោទក៏មិនឋិតនៅក្រោមការកាត់សេចក្តីចំពោះបទល្មើសឧក្រិដ្ឋទាំងឡាយណា ដែលមិនមានអត្ថិភាពនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យដែរ។ ជាសេចក្តីសន្និដ្ឋាន ហើយដូចដែលសហព្រះរាជអាជ្ញាធ្លាប់បានលើកសំអាងពីមុនរួចមកហើយ ការអនុវត្តនូវឧក្រិដ្ឋកម្មអន្តរជាតិនៅចំពោះមុខ អវតក គឺត្រឹមត្រូវយ៉ាងពេញលេញទៅនឹងគោលការណ៍នីត្យានុកូលភាព ដែលមាននៅក្នុងមាត្រា១៥ នៃ ICCPR ។ សហព្រះរាជអាជ្ញាដាក់រួមបញ្ចូល ដោយមានយោងនូវសេចក្តី

[15] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ 040/002/2001, ១២ កុម្ភៈ ២០០១, ត្រង់ទំព័រទី២ ។

[16] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ , ថ្ងៃទី១៥ កុម្ភៈ ២០១១, D427/2/15, ត្រង់កថាខណ្ឌទី ១០៣ ។

[17] សាលក្រម, ថ្ងៃទី២៦ កក្កដា ២០១០, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ, E188, កថាខណ្ឌទី ២៨៣-២៩៦ និង ៤០២-៤០៨ ("សាលក្រមលើសំណុំរឿងលេខ ០០១") ។

សន្និដ្ឋានរបស់ខ្លួនលើបញ្ហាទាំងនេះ ទៅក្នុងចម្លើយតបរួមរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ រួមទាំងអំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលថា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានកំណត់នៅក្នុងច្បាប់ ហើយអាចរកបាន និងអាចព្យាករណ៍ជាមុនបានចំពោះជនជាប់ចោទ នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩[18] ។

## ខ. ឧក្រិដ្ឋកម្មជាតិ - អាជ្ញាយុកាល

១២. នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ទាំងអស់គ្នាសុទ្ធតែតវ៉ាអំពីយុត្តាធិការរបស់ អ.វ.ត.ក ទាក់ទិនឧក្រិដ្ឋកម្មជាតិ ដោយផ្អែកលើមូលដ្ឋានថា ការពន្យាររយៈពេលអាជ្ញាយុកាល ឆ្នាំ២០០១ គឺជាប្រតិសកម្ម និងរំលោភលើគោលការណ៍នីត្យានុកូលភាព[19]។ ខៀវ សំផន និង អៀង ធីរិទ្ធ តវ៉ាទៀតថា ការពន្យាររយៈពេលអាជ្ញាយុកាលសម្រាប់ករណីរឿងក្តីនៅ អ.វ.ត.ក ដែលជាការរំលោភលើគោលការណ៍សមភាពចំពោះមុខច្បាប់[20]។ ខណៈដែល អៀង សារី គ្រាន់តែអះអាងថា អ.វ.ត.ក

[18] ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌទី ១៣១-២០៥ ដែលជាពិសេសសំដៅទៅលើ បទល្មើសប្រល័យពូជសាសន៍ (កថាខណ្ឌ១៦៨-១៧១), បទល្មើសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (កថាខណ្ឌ ១៧២-១៩៩) និងការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញានៃទីក្រុងហ្សឺណែវ (កថាខណ្ឌ២០០-២០៥)។

[19] អញ្ញត្រកម្មរួមបញ្ចូលគ្នារបស់ នួន ជា, ២៥ កុម្ភៈ ២០១១, E53/1, កថាខណ្ឌទី៤១ ។ អញ្ញត្រកម្មបឋម ស្តីពីការរំលត់បណ្តឹងអាជ្ញា (បទល្មើសជាតិ) របស់ ខៀវ សំផន, (Khieu Samphan *Exceptions Preliminaires Portant sur L'Extinction de L'Action Publique (Crimes Nationaux)*, ១៤ កុម្ភៈ ២០១១, E47 [មានតែជាភាសាខ្មែរ និងបារាំង មកដល់ថ្ងៃនេះ] ។ អញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ, ១៤ កុម្ភៈ ២០១១, E44, កថាខណ្ឌទី២២។

[20] អញ្ញត្រកម្មបឋម ស្តីពីការរំលត់បណ្តឹងអាជ្ញា (បទល្មើសជាតិ) របស់ ខៀវ សំផន, (Khieu Samphan *Exceptions Preliminaires Portant sur L'Extinction de L'Action Publique (Crimes Nationaux)*, ១៤ កុម្ភៈ ២០១១, E47, កថាខណ្ឌទី៩ ។ អញ្ញត្រកម្មបឋមរបស់ មេធាវីការពារក្តី អៀង ធីរិទ្ធ, ១៤ កុម្ភៈ ២០១១, E44, កថាខណ្ឌទី២៣ ។

"គ្មានយុត្តាធិការដើម្បីអនុវត្តឧក្រិដ្ឋកម្មជាតិ" ហើយក៏មិនបានបញ្ជាក់ពីមូលដ្ឋានសម្រាប់អញ្ញត្រកម្មនោះ វាហាក់ដូចជា គាត់មានចេតនាលើកនូវបញ្ហាដូចគ្នានឹងជនជាប់ចោទដទៃទៀតដែរ[21]។

១៣. ជាការឆ្លើយតប សហព្រះរាជអាជ្ញា ធ្វើការបង្រួមដោយប្រើសេចក្តីយោងលើអំណះអំណាងដែលមាននៅចែងនៅក្នុងកថាខណ្ឌទី ៨៣ ដល់ ១៣០ នៃចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ[22] និងធ្វើសេចក្តីសង្ខេបពីអំណះអំណាងទាំងនេះដូចទៅ។ ជាដំបូង សហព្រះរាជអាជ្ញា ជំទាស់ថា គោលការណ៍នីត្យានុកូលភាពអនុវត្តចំពោះតែនិយមន័យនៃឧក្រិដ្ឋកម្មជាសារវ័ន្ត ឬការដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មទាំងនេះតែប៉ុណ្ណោះ មិនមែនចំពោះការផ្លាស់ប្តូររយៈពេលនៃអាជ្ញាយុកាលជាធរមានណាមួយនោះទេ។ គេគ្មានបញ្ហាទេថា ឧក្រិដ្ឋកម្មជាតិដូចជា ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា សុទ្ធតែបានកំណត់និយមន័យនៅក្នុងច្បាប់ ហើយអាចរកបាន និងអាចព្យាករណ៍បានជាមុនយ៉ាងគ្រប់គ្រាន់ចំពោះជនជាប់ចោទ នៅក្នុងរយៈកាលចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ និងថាហេតុដូច្នេះ មិនអាចត្រូវបានរារាំងដោយសារតែគោលការណ៍នីត្យានុកូលភាពនេះឡើយ។ អង្គបុរេជំនុំជម្រះធ្លាប់បានបដិសេធបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលប្រឆាំងនឹងដីកាដំណោះស្រាយរួចហើយដែលផ្អែកលើមូលដ្ឋានទាំងអស់នេះ ដោយសម្រេចថា គេគ្មានមូលដ្ឋានដើម្បីពន្យារគោលការណ៍នីត្យានុកូលភាព ឲ្យទៅជាការផ្លាស់ប្តូរដែលមានលក្ខណៈប្រតិសកម្មនៅក្នុងរយៈពេលនៃអាជ្ញាយុកាលឡើយ[23]។

---

[21] សេចក្តីសង្ខេបអញ្ញត្រកម្មបឋមតាមវិធាន៨៩ របស់ អៀង សារី, ២៥ កុម្ភៈ ២០១១, E51/4, កថាខណ្ឌទី២៨ ។ បញ្ហាផ្សេងទៀតដែលបានលើកនៅក្នុងឯកសារពីមុន ដែលបានលើកយោងដោយ អៀង សារី ក្នុងកថាខណ្ឌទី២៨ ហាក់ដូចជាមិនមានគុណវុឌ្ឍិជាអញ្ញត្រកម្មទេ ដូច្នេះមិនត្រូវបានឆ្លើយតបដោយសហព្រះរាជអាជ្ញានៅក្នុងចម្លើយតបនេះទេ ។

[22] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី៨៣-១៣០ ។

[23] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៥ កុម្ភៈ ២០១១, D427/3/15, កថាខណ្ឌទី១៨៣ ។

00655351



១៤. លើសពីនេះទៀត រយៈពេលនៃអាជ្ញាយុកាលដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មានអាយុកាលយ៉ាងហោចណាស់រហូតដល់ពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៩០ ហើយក៏មិនបានផុតកំណត់ដែរដោយសារប្រទេសកម្ពុជាជួបប្រទះសង្គ្រាមស៊ីវិល ហើយជនជាប់ចោទបានដឹកនាំកងកម្លាំងប្រឆាំង និងបានតស៊ូយ៉ាងសកម្មអំពីយុត្តាធិការរបស់រដ្ឋាភិបាលកម្ពុជា។ ដូច្នេះ អាជ្ញាយុកាលសម្រាប់ជនជាប់ចោទម្នាក់ៗមិនទាន់រាប់បានទេ រហូតដល់ពេលដែលពួកគេបានចុះចូលជាមួយរដ្ឋាភិបាលៈ គឺខែធ្នូ ឆ្នាំ១៩៩៨ សម្រាប់ នួន ជា និង ខៀវ សំផន[24] និង ខែកញ្ញា ឆ្នាំ១៩៩៦ សម្រាប់ អៀង សារី និង អៀង ធីរិទ្ធ[25]។ ការពន្យាររយៈពេលអាជ្ញាយុកាលដោយនីតិបញ្ញត្តិក្នុងឆ្នាំ២០០១ បានកើតឡើងមុនពេលផុតកំណត់របស់វា និងជាការផ្លាស់ប្ដូរមួយក្នុងច្បាប់នីតិវិធីរបស់កម្ពុជា មិនមែនបទល្មើសជាសារវន្តដែលជនជាប់ចោទអាចនឹងត្រូវបានចោទប្រកាន់នោះទេ។

១៥. ទាក់ទិននឹងសមភាពនៅចំពោះមុខច្បាប់ សហព្រះរាជអាជ្ញាអះអាងថាការចោទប្រកាន់លើជនជាប់ចោទដោយ អ.វ.ត.ក មិនបានរំលោភលើមាត្រា១៤ ឬ មាត្រា២៦ នៃអនុសញ្ញា ICCPR ឡើយ ដោយហេតុថា ការជ្រើសយកជនជាប់ចោទទាំងនេះ គឺបានធ្វើឡើងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលមានហេតុផល និងសត្យានុម័តដែលថា ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានកំណត់យ៉ាងប្រាកដថា មាត្រា៣ នៃច្បាប់ អ.វ.ត.ក គឺស្របតាមរដ្ឋធម្មនុញ្ញ និងមិនរំលោភចំពោះសិទ្ធិទទួលបានសមភាពនៅចំពោះមុខច្បាប់ទេ។

---

[24] Alexander Hinton, *ហេតុអ្វីបានជាពួកគេសម្លាប់? (Why did they Kill?)*, D313/1.2.7 ត្រង់ ERN 00431457; Nic Dunlop, *ពេជ្ឈឃាដដែលបាត់ខ្លួន (The Lost Executioner)*, D222/1.4, ត្រង់ ERN 00370203; David Chandler, *សម្លេងពីមន្ទីរស-២១ (Voices from S-21)*, D108/50/1.4.6, ត្រង់ ERN 00192858; AP, *មេដឹកនាំកំពូលខ្មែរក្រហមចុះចូល (Top Khmer Rouge Leaders to Defect)*, ២៥ ធ្នូ ១៩៩៨, D56-Doc. 477, ត្រង់ ERN 00132427; AFP, *មេដឹកនាំកំពូលខ្មែរក្រហមនឹងចុះចូលជាមួយរដ្ឋាភិបាល (Top Khmer Rouge Leaders Defect to Government)*, ២៦ ធ្នូ ១៩៩៨, D56-Doc. 478, ត្រង់ ERN 00132425 ។

[25] Jiji Press English News Service, *អៀង សារី ប្រកាសអំពីការចចារផ្លូវការជាមួយរដ្ឋាភិបាល (Ieng Sary Announces Formal Negotiations with Govt.,)* ៩ កញ្ញា ១៩៩៦, D56-Doc. 445, ត្រង់ ERN 00115846; ព្រះរាជក្រឹត្យដោយ នរោត្តម សីហនុ, ការអនុគ្រោះទោសរបស់ អៀង សារី, ១៤ កញ្ញា ១៩៩៦, D366/7.1.191, ត្រង់ ERN 00523598 ។

១៦. នៅក្នុងសាលក្រមនៃសំណុំរឿងលេខ០០១ របស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង ខកខានមិនបាន ឈានដល់ការសម្រេចលើបញ្ហានេះទេ ។ មតិភាគច្រើនបានរកឃើញថា រយៈពេលនៃការចាប់ផ្តើម អាជ្ញាយុកាលគឺ មានយ៉ាងហោចណាស់រហូតដល់ខែកញ្ញា ឆ្នាំ១៩៩៣ ហើយការពន្យាររយៈពេល អាជ្ញាយុកាលគឺមានសុពលភាពស្របតាមរដ្ឋធម្មនុញ្ញ[26]។ មតិភាគតិចរកឃើញថា សហព្រះរាជ អាជ្ញា ខកខានក្នុងការបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ថា "គ្មានការចោទប្រកាន់ ឬកិច្ចស៊ើបសួរ នឹងអាចធ្វើទៅបានឡើយចាប់ពីឆ្នាំ១៩៧៩-១៩៩៣" ដូច្នេះ អាជ្ញាយុកាលបានផុតរួចទៅហើយ មុនពេលការអនុម័តច្បាប់ អ.វ.ត.ក ក្នុងឆ្នាំ២០០១ ដែលជាឆ្នាំនៃការពន្យាររយៈពេលនៃអាជ្ញាយុ កាលនេះ[27]។ ស្របពេលនេះដែរ ចៅក្រមដែលខ្វែងយោបល់បានសង្កេតឃើញថា "គ្មានភាពផ្ទុយ គ្នាច្បាស់លាស់រវាងបទដ្ឋានអន្តរជាតិ ស្តីពីការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ ដែលនៅជាធរមានចំពោះមុខ អ.វ.ត.ក និងវិសោធនកម្មប្រតិសកម្ម ធ្វើឡើងដោយអង្គនីតិបញ្ញត្តិ កម្ពុជា អំពីរយៈពេលនៃអាជ្ញាយុកាល"[28] នេះទេ ។ ការអះអាងរបស់ អៀង ធីរិទ្ធ ដែលថា សហ-ព្រះរាជអាជ្ញា "បានស្រុះស្រួល" ទៅតាម "ការរកឃើញផ្នែកច្បាប់" លើបញ្ហានេះដោយមិនប្តឹង ឧទ្ធរណ៍ គឺជារឿងមិនទំនង[29] ដោយហេតុថាការរកឃើញរបស់មតិភាគច្រើននៃចៅក្រមទាំងនេះ បានយល់ស្របតាមគោលជំហររបស់សហព្រះរាជអាជ្ញា។

១៧. សហព្រះរាជអាជ្ញា សន្និដ្ឋានថា ភស្តុតាងដែលនឹងបង្ហាញក្នុងពេលសវនាការកាត់សេចក្តីលើសំណុំ រឿងលេខ០០២ នឹងកំណត់បានថា គេគ្មានលទ្ធភាពសមហេតុផលដើម្បីធ្វើការចោទប្រកាន់ អៀង សារី, អៀង ធីរិទ្ធ, នួន ជា និង ខៀវ សំផន ឡើយ រហូតដល់ពេលនៃការចុះចូលរបស់ពួកគេជា

[26] សេចក្តីសម្រេចអំពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ, ២៦ កក្កដា ២០១០, *សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសហ*, E187, *កថាខណ្ឌទី១៩-២០, ២៥, ៣៨*("*សេចក្តីសម្រេចអំពីអាជ្ញាយុកាលជាតិ*") ។

[27] *សេចក្តីសម្រេចអំពីអាជ្ញាយុកាលជាតិ, កថាខណ្ឌទី៣១-៣២, ៣៥* ["*ផ្អែកលើភស្តុតាងនៅចំពោះមុខពួកគេ ចៅក្រមអន្តរជាតិមិនអាចធ្វើការសន្និដ្ឋាន...*"] ។

[28] *សេចក្តីសម្រេចអំពីអាជ្ញាយុកាលជាតិ, កថាខណ្ឌទី៤៣* ។

[29] អញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ, ១៤ កុម្ភៈ ២០១១, E44, កថាខណ្ឌទី២១ ។

00655353



មួយរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ១៩៩៦ និង១៩៩៨ តាមលំដាប់លំដោយ និងថា ការពន្យាររយៈពេលអាជ្ញាយុកាល គឺមានអានុភាពរហូតដល់ពេលនេះ។ គោលជំហររបស់ជនជាប់ចោទទាំងនេះ មានលក្ខណៈខុសគ្នាជាមូលដ្ឋានជាងគោលជំហររបស់ ឌុច ក្នុងសំណុំរឿងលេខ០០១ ហើយវាជាការលំបាកក្នុងការគិតថា តើអាជ្ញាយុកាលផុតកំណត់ដោយរបៀបណា ក្នុងអម្លុងពេលដែលជនជាប់-ចោទអាចត្រូវបានវិនិច្ឆ័យទោសតែ*ដោយកំបាំងមុខ* ប៉ុណ្ណោះ ដោយសារពួកគេស្ថិតនៅខាងក្រៅយុត្តាធិការ ឬកំពុងលាក់ខ្លួនតាមព្រំដែនថៃ ដែលទទួលបានការការពារពីកងទ័ពរបស់ខ្លួនផ្ទាល់នៅចំកណ្តាលនៃសង្គ្រាមស៊ីវិលនោះ។ ដោយសារសេចក្តីសម្រេចលើបញ្ហានេះតម្រូវឱ្យមានសវនាការលើភស្តុតាង និងការកាត់សេចក្តីលើអង្គហេតុ អង្គជំនុំជម្រះសាលាដំបូង គួរពន្យារសេចក្តីសម្រេចរបស់ខ្លួនសិនរង់ចាំរហូតដល់មានសាលក្រមលើអង្គសេចក្តី ដូចបានអនុញ្ញាតក្រោមវិធាន៨៩(៣) ។

## គ. អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ - អាជ្ញាយុកាល

១៨. អៀង សារី តវ៉ាអំពីបញ្ហាយុត្តាធិការរបស់ អ.វ.ត.ក ទាក់ទងនឹងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ តាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក ដោយគាត់អះអាងថា ស្ថិតក្រោមអាជ្ញាយុកាលដែលបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦[30] ។

១៩. សហព្រះរាជអាជ្ញា នៅតែប្រកាន់ជំហរតាមអំណះអំណាងរបស់ខ្លួន[31] និងសន្និដ្ឋានថា អញ្ញត្រកម្មរបស់ អៀង សារី មិនទទួលបាននូវការគាំទ្រដោយច្បាប់ អ.វ.ត.ក ឬ ច្បាប់អន្តរជាតិទេ។ គ្មានអាជ្ញាយុកាលសម្រាប់ការចោទប្រកាន់ចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ត្រូវបានកំណត់ឡើង

[30] អញ្ញត្រកម្មបឋមរបស់ អៀង សារី អនុលោមតាមវិធាន៨៩ (អាជ្ញាយុកាលសម្រាប់អំពើបំពានយ៉ាងធ្ងន់ធ្ងរ), ១៤ កុម្ភៈ ២០១១, E43, កថាខណ្ឌទី១-៩ ។

[31] សហព្រះរាជអាជ្ញាធ្វើការបង្រួមតាមរយៈសេចក្តីយោងដែលមាននៅក្នុងអំណះអំណាងក្នុងកថាខណ្ឌទី២០២ ដល់ ២០៤ នៃចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ។

នោះទេ ទាំងអនុសញ្ញាទីក្រុងហ្សឺណែវ ឬ ច្បាប់ អ.វ.ត.ក ក៏គ្មានដែរ ហើយច្បាប់ទម្លាប់អន្តរជាតិបានបញ្ជាក់អះអាងថា ឧក្រិដ្ឋកម្មទាំងនេះមិនស្ថិតក្រោមអាជ្ញាយុកាលណាមួយឡើយ។ ការអះអាងដើម្បីការពារខ្លួនរបស់ អៀង សារី អំពីអាជ្ញាយុកាល ដែលសូម្បីតែរយៈពេលកំណត់សម្រាប់ឧក្រិដ្ឋកម្មបែបនេះក៏គ្មានដែរ នោះគឺជាអំណះអំណាងឥតបានការដែលគួរត្រូវបានបដិសេធចោលដោយមិនចាំបាច់គិតវែងឆ្ងាយ។

២០. គេបានកំណត់យ៉ាងល្អនៅក្នុងច្បាប់ទម្លាប់អន្តរជាតិដែលថា អាជ្ញាយុកាលមិនអាចអនុវត្តបានទេសម្រាប់អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ[32]។ មាត្រា៦ នៃច្បាប់ អ.វ.ត.ក មិនអាចត្រូវបានគេបកស្រាយងាកចេញពីគោលការណ៍នេះ ហើយធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចក្នុងការចោទប្រកាន់ចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរឡើយ ដោយសារវាបានកំណត់នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ[33] និងបានធ្វើឱ្យបញ្ជាក់រឹតតែច្បាស់នៅក្រោមច្បាប់ទម្លាប់អន្តរជាតិ[34]។ ការចោទប្រកាន់ឧក្រិដ្ឋកម្មនៅក្រោមច្បាប់អន្តរជាតិជាពិសេសចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ត្រូវតែពង្រឹងការអនុវត្តឱ្យបាន ហើយ"រដ្ឋត្រូវតែមានវិធានការដើម្បីធានាឱ្យប្រាកដថា ជនសង្ស័យមិនត្រូវទទួលបាននិទណ្ឌភាពឡើយ"[35] ។

---

[32] J.-M. Henckaerts និង L. Doswald-Beck, ច្បាប់ទម្លាប់មនុស្សធម៌អន្តរជាតិ *(Customary International Humanitarian Law)*, វិធាន 160, ទំព័រ 614-618 ("Henckaerts និង Doswald-Beck"): "ទម្លាប់អនុវត្តរបស់រដ្ឋបង្កើតបាននូវវិធាននេះ [អាជ្ញាយុកាល អាចមិនប្រើចំពោះឧក្រិដ្ឋកម្មសង្គ្រាម] ជានិយាមនៃច្បាប់ទម្លាប់អន្តរជាតិ ទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាមដែលបានប្រព្រឹត្តទាំងនៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ និងមិនមែនអន្តរជាតិ"; R. Bellelli., យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ *(International Criminal Justice)*, 2010, ទំព័រ 6; F. Bouchet-Saulnier, L. Brav, C.Olivier, ការណែនាំអនុវត្តចំពោះច្បាប់មនុស្សធម៌, 2007, ទំព័រ 484 ។

[33] អនុសញ្ញាទីក្រុងហ្សឺណែវ I, មាត្រា 49; អនុសញ្ញាទីក្រុងហ្សឺណែវ II, មាត្រា 50; អនុសញ្ញាទីក្រុងហ្សឺណែវ III, មាត្រា 129; អនុសញ្ញាទីក្រុងហ្សឺណែវ IV, មាត្រា 146; ពិធីសារបន្ថែម I, មាត្រា 85 ។ ការអានក្នុងន័យដ៏ចង្អៀតពេករបស់ អៀង សារី នៃមាត្រា៦ នៃច្បាប់ អ.វ.ត.ក គឺមិនត្រឹមតែមិនស្របនឹងន័យត្រង់ផង និងគោលបំណងដ៏រស់រវើកនៃអនុសញ្ញាទីក្រុងហ្សឺណែវផង ។

[34] Henckaerts និង Doswald-Beck, វិធាន 158 ។

[35] J.-M. Henckaerts, របបនៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ជាច្បាប់ទម្លាប់អន្តរជាតិ *(The Grave Breaches Regime as Customary International Law)*, JICJ 7 (2009), ទំព័រ 694, 697 ។

២១. ផ្ទុយពីការអះអាងរបស់ អៀង សារី អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ គឺជាឧក្រិដ្ឋកម្មក្នុងប្រភេទពិសេសមួយដែលគេមិនអាចប្រដូចទៅនឹងប្រភេទនៃបទឧក្រិដ្ឋធម្មតាបានឡើយ ដូចជា បទឧក្រិដ្ឋនៅក្រោមច្បាប់កម្ពុជាដែលត្រូវស្ថិតក្រោមរបបនៃច្បាប់ព្រហ្មទណ្ឌធម្មតា[36]។ ច្បាប់ជាតិដែលបានលើកយោងដោយ អៀង សារី គឺពាក់ព័ន្ធតែបទឧក្រិដ្ឋធម្មតា និងមិនចាំបាច់ដើម្បីកំណត់អំពីភាពអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទេ[37]។ ការពិតច្បាប់យុត្តិសាស្ត្រដែលពាក់ព័ន្ធនឹងការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មសង្គ្រាម បញ្ជាក់អះអាងពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាល[38]។ រដ្ឋទាំងអស់បានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិឆ្នាំ ១៩៦៨ ស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬច្បាប់លក្ខន្តិកៈរបស់ ICC[39] ឬបានអនុវត្តគោលការណ៍នៃភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ដែលមានចែងនៅក្នុងសៀវភៅក្បួនយោធា សេចក្តីថ្លែងការផ្លូវការ និងច្បាប់ជាតិនានា[40]។ ជាចុងក្រោយ មហាសន្និបាតអង្គការ

---

[36] បានលើកយោងនៅក្នុង Henckaerts និង Doswald-Beck, ទំព័រ 615: សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិអំពីអនុសញ្ញាស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, 25 វិច្ឆិកា 1968, ប្រជុំពេញអង្គលើកទី XXIII, A/RES/2391, សេចក្តីថ្លែងការរបស់ប៊ូលហ្គារី, សហរដ្ឋអាមេរិក, ឆេកូស្លូវាគី, បារាំង, ឥណ្ឌា, អ៊ីស្រាអែល, ប៉ូឡូញ, រ៉ូម៉ានី, ចក្រភពអង់គ្លេស, អ៊ុយក្រែន, សហភាពសូវៀត, អូរូហ្គាយ, យូហ្គោស្លាវី ។

[37] អញ្ញត្រកម្មបឋមរបស់ អៀង សារី អនុលោមតាមវិធាន៨៩ (អាជ្ញាយុកាលសម្រាប់អំពើបំពានយ៉ាងធ្ងន់ធ្ងរ), ១៤ កុម្ភៈ ២០១១, E43, កថាខណ្ឌទី៥-៦ ។

[38] *Priebke* និង *Haas*, អ៊ីតាលី, តុលាការយោធា នៅទីក្រុងរ៉ូម (Rassegna Giustizia Militare), Sentenza del Tribunale Militare di Roma, ២២ កក្កដា ១៩៩៧, អាចរកបានតាមរយៈ: http://www.difesa.it/GiustiziaMilitare/RassegnaGM/Processi/Priebke+Erich/08_22-07-97.htm; Guido Acquaviva, 'Priebke and Haas', *in* Antonio Cassese (ed), *The Oxford Companion to International Criminal Justice*, Oxford, 2009, ទំព័រ 880 ។ ប្រទេសឈីលី, តុលាការឧទ្ធរណ៍នៃទីក្រុងសានទីយ៉ាហ្គូ, ករណីរឿង *Videla*; ប្រទេស អេត្យូពី, ការិយាល័យពិសេសរបស់រដ្ឋអាជ្ញា, *Mengistu* និងករណីដទៃទៀត; អ៊ីតាលី, តុលាការឧទ្ធរណ៍យោធា និងសាលាវិនិច្ឆ័យនៃតុលាការកំពូល, ករណី *Hass* និង *Priebke* ដែលបានដកស្រង់នៅក្នុង Henkaerts និង Doswald-Beck, វិធាន 4045-4056 ។

[39] ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម, មាត្រា២៩ ចែងយ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មទាំងនោះមិនស្ថិតក្រោមអាជ្ញាយុកាលណាមួយទេ ។

[40] Henckaerts និង Doswald-Beck, វិធាន 160, ទំព័រ 616-617 ។

សហប្រជាជាតិ ក៏បាននអនុម័តសេចក្តីសម្រេចមួយចំនួន ដោយលើកតម្កើងភាពមិនអាចអនុវត្តបាន នៃអាជ្ញាយុកាលទាំងនេះ[41]។

## ឃ. សហកម្មខក្រិដ្ឋកម្មរួម

២២. ដីកាដំណោះស្រាយ ចោទប្រកាន់ជនជាប់ចោទនៅលើមូលដ្ឋាន, *inter alia,* ទម្រង់នៃការទទួលខុសត្រូវស្តីពីសហកម្មខក្រិដ្ឋកម្មរួម (JCE) I[42] ។ អៀង សារី និង ខៀវ សំផន ជំទាស់នឹងការអនុវត្ត JCE នៅចំពោះមុខ អវតក, រីឯ អៀង ធីរិទ្ធ ឯកភាពថា JCE I គឺអាចអនុវត្តបាន ក៏ប៉ុន្តែជំទាស់ ទៅនឹង JCE II[43] ។ ការជំទាស់ទាំងនោះមានមូលដ្ឋាននៅលើទឡ្ហីករណ៍មួយចំនួន ដែលជាដំបូងៗមាន៖ ទី១) JCE មិនមែនជាផ្នែកនៃច្បាប់តាមទម្លាប់អន្តរជាតិក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យទេ, ទី២) បើទោះបីជាវាដូច្នោះ វាមិនមែនជាផ្នែកនៃច្បាប់កម្ពុជាទេ ហើយដូច្នោះវាមិន អាចអនុវត្តនៅចំពោះមុខ អវតក ដែលជាតុលាការមួយនៅក្នុងប្រទេសកម្ពុជាបានដែរ, និងទី៣) ការអនុវត្ត JCE ត្រូវបានរារាំងដោយគោលការណ៍នីត្យានុកូលភាព។

---

[41] ដំណោះស្រាយរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 2391 (XXIII), 2583 (XXIV), 2712 (XXV) និង 2840 (XXVI) ។

[42] ដីកាដំណោះស្រាយ, ថ្ងៃទី១៥ កញ្ញា ២០១០, D427, កថាខណ្ឌទី ១៥៤០-១៥៤២ (“ដីកាដំណោះស្រាយ”) ។

[43] ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា *សហកម្មខក្រិដ្ឋកម្មរួម* (JCE), ថ្ងៃទី២៨ កក្កដា ២០០៨, D97, កថាខណ្ឌទី ១-៣៣ ។ សេចក្តីសង្កេតបន្ថែមរបស់លោក អៀង សារី ស្តីពីការអនុវត្តន៍ ទ្រឹស្តីសហកម្មខក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក, ថ្ងៃទី២៤ វិច្ឆិកា ២០០៨, D97/7 ។ អញ្ញត្រកម្មរបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ, ថ្ងៃទី១៤ កុម្ភៈ ២០១១, E44, កថាខណ្ឌទី ៣៣-៣៨ ។ សារណារបស់អ្នកស្រី អៀង ធីរិទ្ធ ស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាសហកម្មខក្រិដ្ឋកម្មរួម អនុលោមតាមដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨, ថ្ងៃទី៣០ ធ្នូ ២០០៨, D97/3/2, កថាខណ្ឌទី ៣៣-៣៨ ។ អញ្ញត្រកម្មបឋមលើយុត្តាធិការ, ថ្ងៃទី១៤ កុម្ភៈ ២០១១, E46, កថាខណ្ឌទី ១៨ ។ ចម្លើយរបស់សហមេធាវីការពារក្តីលោក ខៀវ សំផន តបនឹងចម្លើយរួមរបស់សហព្រះរាជអាជ្ញាលើសហកម្មខក្រិដ្ឋកម្មរួម, ថ្ងៃទី២៥ មីនា ២០១០, D97/16/9, កថាខណ្ឌទី ១៣-២៦ ។

២៣. សហព្រះរាជអាជ្ញា ដាក់រួមបញ្ចូលដោយមានយោងនូវសេចក្តីសន្និដ្ឋានពីមុនៗរបស់ខ្លួនលើបញ្ហានេះ និងផ្តល់ជូននូវសេចក្តីសង្ខេបខ្លីមួយស្តីពីការសន្និដ្ឋានទាំងនោះនៅទីនេះ[44]។ ការទទួលខុសត្រូវ ក្នុងការចូលរួមនៅក្នុងផែនការរួម មានអត្ថិភាពជាទម្រង់មួយចំនួននៅក្នុងការតាក់តែងច្បាប់ជាតិ ឬនៅក្នុងយុត្តិសាស្ត្រនៃប្រទេសជាច្រើន ចាប់តាំងពីយ៉ាងហោចណាស់ក៏សតវត្សរ៍ទី១៩ ដែរ[45]។ ការដាក់បញ្ចូលនូវ "ផែនការរួម" ដែលជាទម្រង់នៃការទទួលខុសត្រូវទៅក្នុងធម្មនុញ្ញ Nuremberg និងច្បាប់ស្តីពីក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ (the Control Council Law Number 10), ការអនុវត្តរបស់វានៅក្នុងការជំនុំជម្រះក្តី ពីបទឧក្រិដ្ឋកម្មសង្គ្រាមនៅក្រោយសង្គ្រាមលោកលើកទី២ ហើយនិងការអនុវត្ត និង *កាតព្វកិច្ចតាមផ្លូវច្បាប់ (opinio juris)* របស់ប្រទេសដទៃទៀត បានធ្វើឱ្យ JCE កាន់តែភ្លឺច្បាស់ថាជាគោលការណ៍មួយនៃច្បាប់តាមទម្លាប់អន្តរជាតិ នៅក្នុងប៉ុន្មានឆ្នាំភ្លាមៗក្រោយពីសង្គ្រាមលោកលើកទី២[46]។

២៤. JCE ត្រូវបានគេទទួលស្គាល់ជាបន្តបន្ទាប់មកទៀត នៅក្នុងយុត្តិសាស្ត្រតុលាការមួយចំនួន រួមទាំង ICTY ICTR និង SCSL ដែលបានរកឃើញថាពាក្យ "បានប្រព្រឹត្ត" នៅក្នុងច្បាប់លក្ខន្តិកៈរៀងៗខ្លួនមានបញ្ចូលនូវការចូលរួម ទៅក្នុងសមិទ្ធិកម្មនៃបែបផែន ឬគោលបំណងរួម[47] (in the realisation

---

[44] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី១៩ កុម្ភៈ ២០១០, D97/16/5 ។ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងញត្តិរបស់ អៀង សារី ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី១១ សីហា ២០០៨, D97/II ។ សេចក្តីអង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី៣១ ធ្នូ ២០០៨, D97/8 ។

[45] ICTY, *Tadic*, សាលដីកា, ថ្ងៃទី១៥ កក្កដា ១៩៩៩, កថាខណ្ឌទី ២២៤-២២៥ ។

[46] *សូមមើល,* របាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិស្តីពីការងារក្នុងសម័យប្រជុំរបស់ខ្លួនលើកទី៤៨, ៦ ឧសភា - ២៦ កក្កដា ១៩៩៦, កំណត់ត្រាផ្លូវការរបស់មហាសន្និបាត, សម័យប្រជុំលើកទី៥១, ឯកសារបន្ថែមលេខ១០, ត្រង់កថាខណ្ឌទី ១៩, អាចរកបានតាមៈ http://www.unorg/law.ilc/index.htm។ សេចក្តីបញ្ជាក់លើគោលការណ៍ច្បាប់អន្តរជាតិដែលបានទទួលស្គាល់ដោយធម្មនុញ្ញនៃតុលាការ Nuremberg, G.A. Res. 95(I), UN GAOR, 1st Sess., U.N. Doc A/236 (1946) ចំណុចទី២, ត្រង់កថាខណ្ឌទី ១១៤៤ ។

[47] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី ២០ ឧសភា ២០១០, D97/15/9 ។ សាលក្រមលើសំណុំរឿងលេខ០០១, កថាខណ្ឌទី៥០៤-៥១០ ។ ICTY, *Tadic*, សាលដីកា, ថ្ងៃទី១៥ កក្កដា ១៩៩៩, កថាខណ្ឌទី ១៩៣ និង ១៨៧-២២៦ ។ ICTR, *Ntakirutimana & Ntakirutimana*, សាលដីកា, ថ្ងៃទី១៣ ធ្នូ ២០០៤, កថាខណ្ឌទី ៤៦៨ ។ SCSL, *Brima និងគូកន*, សាលដីកា, ថ្ងៃទី២២ កុម្ភៈ ២០០៨, កថាខណ្ឌទី ៧២-៧៥ ។

00655358



of a common design or purpose)។ មាត្រា២៩ នៃច្បាប់ អវតក មានការប្រើ ពាក្យពេជន៍ដូចគ្នា បេះបិទទៅនឹងបទប្បញ្ញត្តិទាំងនោះ ហើយដូច្នោះ ពួកអ្នកព្រាងច្បាប់ អវតក មានចេតនានឹងដាក់ JCE រួមបញ្ចូលទៅក្នុងច្បាប់ អវតក។

២៥. ស្តីពីបញ្ហានីត្យានុកូលភាព សហព្រះរាជអាជ្ញា សូមលើកជាថ្មីម្តងទៀតនូវសំអាងនានាដែលមាននៅខាងលើនេះក្នុងផ្នែក II.ក ដែលពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់ អវតក លើឧក្រិដ្ឋកម្មអន្តរជាតិ។ ដោយសារ JCE ត្រូវបានពិចារណាថាជាទម្រង់មួយនៃការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ នៅក្រោមច្បាប់តាមទម្លាប់អន្តរជាតិ ដែលបានបង្កើតឡើងយ៉ាងរឹងមាំក្នុងឆ្នាំ១៩៧៥ នោះការអនុវត្តរបស់វាគឺត្រូវគ្នាទៅនឹងមាត្រា១៥ នៃ ICCPR។ JCE គឺអាចរកបាន និងអាចមើលឃើញបាន នៅក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩។ មាត្រា៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានកំណត់អត្តសញ្ញាណពីការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្ម ថាជាទម្រង់មួយនៃការទទួលខុសត្រូវ ដោយបានថ្លែងថា ជនណាចូលរួមប្រព្រឹត្តដោយចេតនានូវឧក្រិដ្ឋកម្ម ដោយផ្ទាល់ក្តី ដោយប្រយោលក្តី ជននោះត្រូវមានទោសដូចជា អាទិចារី[48]។

២៦. ភាពអនុវត្តបាននូវ JCE ត្រូវមានវិវាទនៅចំពោះមុខអង្គជំនុំជម្រះនេះ[49]។ នៅក្នុងសំណុំរឿងលេខ ០០២ អង្គបុរេជំនុំជម្រះបានសម្រេចថា JCE I និង JCE II គឺជាទម្រង់នៃការទទួលខុសត្រូវ នៅក្នុងច្បាប់តាមទម្លាប់អន្តរជាតិ ដែលគេបានទទួលស្គាល់ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលអាចរកបាន និងអាចមើលឃើញបានយ៉ាងគ្រប់គ្រាន់ទៅលើជនជាប់ចោទរូបនេះ នៅ

---

[48] មាត្រា៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។ *សូមមើលផងដែរ* មាត្រា២៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[49] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយលើករណី ឌុច, ផ្នែកទី VII– ទឡ្ហីករណ៍ទី ២ ។ សាលក្រមលើសំណុំរឿងលេខ០០១, កថាខណ្ឌទី ៥១២-៥១៣ ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី២០ ឧសភា ២០១០, D97/15/9, កថាខណ្ឌទី ៦៩ ។

ក្នុងអំឡុងពេលនោះ[50]។ នៅក្នុងសំណុំរឿងលេខ ០០១ អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញផងដែរថា JCE I និង JCE II គឺជាផ្នែកនៃច្បាប់តាមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយថាបានត្រូវទៅតាមលក្ខខណ្ឌតម្រូវនានាស្តីពីភាពអាចរកបាន និងភាពអាចមើលឃើញបាន[51]។

## ង. ការទទួលខុសត្រូវរបស់ថ្នាក់លើ

២៧. អៀង ធីរិទ្ធ និង អៀង សារី តវ៉ាអំពីយុត្តាធិការរបស់ អ.វ.ត.ក ទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ ថាជាទម្រង់នៃការទទួលខុសត្រូវមួយបែបផ្សេង។ អៀង ធីរិទ្ធ និង អៀង សារី តវ៉ាជាចំបងថា ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនមែនជាផ្នែកនៃច្បាប់ទម្លាប់អន្តរជាតិទេ ក្នុងចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ និងថាបើដូច្នេះ ជាការរំលោភលើគោលការណ៍នីត្យានុកូលភាព[52]។ អៀង ធីរិទ្ធ តវ៉ាបន្ថែមថា ការទទួលខុសត្រូវរបស់ថ្នាក់លើ អនុវត្តបានតែចំពោះឧក្រិដ្ឋកម្មសង្គ្រាមប៉ុណ្ណោះ មិនមែនឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ[53]។ អៀង សារី ក៏សន្និដ្ឋានដែរថា ការទទួលខុសត្រូវរបស់ថ្នាក់លើ អនុវត្តបានតែចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិ និងមេបញ្ជាការយោធាប៉ុណ្ណោះ មិនអនុវត្តចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ទេ និងអនុវត្តបានតែនៅពេលណាមានទំនាក់

---

[50] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី ២០ ឧសភា ២០១០, D97/15/9, កថាខណ្ឌទី ៦៩, ៧២ និង ៧៧ ។

[51] សាលក្រមលើសំណុំរឿងលេខ០០១, កថាខណ្ឌទី ៥១២ ។

[52] អញ្ញត្រកម្មបឋមរបស់ មេធាវីការពារក្តី អៀង ធីរិទ្ធ, ១៤ កុម្ភៈ ២០១១, E44, កថាខណ្ឌទី៣៩-៤០ យោងទៅលើ: បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៨ តុលា ២០១០, D427/2/1, កថាខណ្ឌទី៨៤-៨៩ និង ការឆ្លើយតបរបស់មេធាវីការពារក្តីទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ៦ ធ្នូ ២០១០, D427/2/11, កថាខណ្ឌទី៧០-៧៨ ។ សេចក្តីសង្ខេបអញ្ញត្រកម្មបឋមតាមវិធាន៨៩ របស់ អៀង សារី, ២៥ កុម្ភៈ ២០១១, E51/4, កថាខណ្ឌទី២៦ ដោយលើកយោងឈ្មោះនៃការដាក់ឯកសារពីមុន យោងឯកសារ D345/2; D345/3; D345/5/1; D390/1/2/1.3 ត្រង់កថាខណ្ឌទី២៥-២៧ និង១២៧-១៤៣; D427/1/6 ត្រង់កថាខណ្ឌទី២៨៣-៣២៤; D427/1/23 ។

[53] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៨ តុលា ២០១០, D427/2/1, កថាខណ្ឌទី៩០-៩២ និង ការឆ្លើយតបរបស់មេធាវីការពារក្តីទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ៦ ធ្នូ ២០១០, D427/2/11, កថាខណ្ឌទី៧៩-៨៥ ។

ទំនាក់ដែលនាំឱ្យមានការបង្កហេតុរវាងសកម្មភាពរបស់ថ្នាក់លើ និងឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួនតែប៉ុណ្ណោះ[54]។

២៨. ទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ សហចៅក្រមស៊ើបអង្កេតបានធ្វើការបកស្រាយមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក ថា ជាទម្រង់នៃការទទួលខុសត្រូវមួយ ដោយបានរៀបរាប់ដូចតទៅ: "ថ្នាក់លើជាអ្នកទទួលខុសត្រូវចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយរបស់ថ្នាក់ក្រោម ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ពេលណាថ្នាក់លើនោះបានដឹង ឬមានហេតុផលនឹងដឹងអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ ប៉ុន្តែពុំបានចាត់វិធានការចាំបាច់ និងសមហេតុផលនានាដើម្បីទប់ស្កាត់អំពើនោះកុំឱ្យកើតឡើង ឬដាក់ទណ្ឌកម្មអ្នកក្រោមបង្គាប់ដែលប្រព្រឹត្តនោះ ដោយសារថ្នាក់លើមានអំណាចត្រួតត្រាយ៉ាងមានប្រសិទ្ធភាពទៅលើអ្នកក្រោមបង្គាប់"[55]។

២៩. តាមរយៈនេះ សហព្រះរាជអាជ្ញាធ្វើការបង្រួម ដោយសេចក្តីយោងនៅលើអំណះអំណាងដែលមានចែងនៅក្នុងកថាខ័ណ្ឌទី២០៦ ដល់២៥៧ នៃចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ[56] និងធ្វើការសង្ខេបពីអំណះអំណាងទាំងនេះដូចទៅ៖

(ក) ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាននៅ អ.វ.ត.ក ដោយហេតុថា (១) មាត្រា២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក ចែងយ៉ាងច្បាស់អំពីការអនុវត្តចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើនេះ។ (២) ការទទួលខុសត្រូវរបស់

[54] ចម្លើយតបរួមសំណើសុំរបស់ អៀង សារី ស្តីពីការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក, ១៥ កុម្ភៈ ២០១០, D345/3, កថាខណ្ឌទី ៥-២១។ អំណះអំណាងនេះបានធ្វើឡើងវិញ ក្នុងD345/3, កថាខណ្ឌទី ៥៨-៧៤ និង D427/1/6, កថាខណ្ឌទី៣០៧-៣២៤ ។

[55] ដីកាដំណោះស្រាយ, កថាខណ្ឌទី១៣១៩ ។

[56] ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌទី២០៦-២៥៧ ។

ថ្នាក់លើជាផ្នែកនៃទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារវាបានវិវត្តន៍ពីគោលការណ៍នៃការបញ្ជារបស់ថ្នាក់លើ មកគោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើវិញក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ ច្បាប់ជាតិ និងលិខិតុបករណ៍អន្តរជាតិនានា និង (៣) ការអនុវត្តចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក បំពេញលក្ខខណ្ឌតម្រូវនៃ ភាពអាចដឹងជាមុន និងលទ្ធភាពរកបាន ព្រមទាំងស្របគ្នាជាមួយនឹងគោលការណ៍នីត្យានុកូលភាព[57]។

(ខ) ដីកាដំណោះស្រាយធ្វើការឆ្លុះបញ្ចាំងបានយ៉ាងត្រឹមត្រូវអំពីទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយហេតុថា: (១) អនុវត្តចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនមែនចំពោះតែឧក្រិដ្ឋកម្មប៉ុណ្ណោះទេ ហើយក៏ចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ ដូចជាអំពើប្រល័យពូជសាសន៍ ជាដើម។ (២) អនុវត្តដោយស្មើភាពគ្នាចំពោះមេដឹកនាំយោធា និងស៊ីវិល។ (៣) អនុវត្តក្នុងជម្លោះប្រដាប់អាវុធផ្ទៃក្នុងប្រទេស និងអន្តរជាតិ និង (៤) មិនមានលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនង នៃការបង្កហេតុរវាងឧក្រិដ្ឋកម្មជាដើមអាទិ៍ និងសកម្មភាពរបស់ថ្នាក់លើទេ[58] ។

៣០. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា៖ “ទ្រឹស្តីស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើដូចដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ទាក់ទងនឹង អៀង ធីរិទ្ធ មានអត្ថិភាពជាបញ្ញាមួយនៃច្បាប់តាមទម្លាប់អន្តរជាតិ ចាប់ពីឆ្នាំ ១៩៧៥-១៩៧៩។ ដោយមានទាក់ទងនឹង ក្រោយសង្គ្រាមលោកលើកទី២ ករណីយុត្តិសាស្ត្រអន្តរជាតិបានលើកឡើង (...) ហើយចរិតលក្ខណៈដ៏ធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺទាំងភាពអាចដឹងមុនបាន និងភាពអាចរកបាន

[57] ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌទី២១០-២៣៧ ។

[58] ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌទី២៣៨-២៥៧ ។

ចំពោះ អៀង ធីរិទ្ធ ដែលថាគាត់អាចនឹងត្រូវបានធ្វើការកាត់សេចក្តីក្នុងឋានៈជាថ្នាក់លើ ទោះជាយោធា និងមិនមែនជាយោធា ចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តដោយពួកអ្នកនៅក្រោមបង្គាប់របស់គាត់ចាប់ពីឆ្នាំ ១៩៧៥-១៩៧៩" [59] ។

៣១. ក្រោយមក អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសាលក្រមលើសំណុំរឿងលេខ០០១ របស់ខ្លួនបានកត់សម្គាល់ថា៖ "តុលាការ Nuremberg យល់ឃើញថា ការខកខានរបស់ថ្នាក់លើក្នុងការអនុវត្តតួនាទីរបស់ខ្លួនដើម្បីគ្រប់គ្រងអំពើឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់ អាចនាំឲ្យមានការទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនោះ" ដោយបានលើកឡើងពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ("ការទទួលខុសត្រូវចំពោះការបញ្ជា គឺជាផ្នែកនៃច្បាប់ទម្លាប់អន្តរជាតិទាក់ទងនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ មុនពេលអនុម័តយកពិធីសារបន្ថែម I") ហើយបានរកឃើញថា "ក្រោមច្បាប់ទម្លាប់អន្តរជាតិ ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនត្រូវបានកំណត់ចំពោះតែមេបញ្ជាការយោធាប៉ុណ្ណោះទេ"[60]។

## ច. អំពើអមនុស្សធម៌ផ្សេងៗទៀត, ការធ្វើទារុណកម្ម និងការដាក់ក្នុងមន្ទីរឃុំឃាំង គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៣២. អៀង ធីរិទ្ធ ជំទាស់ថា អាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបាត់ខ្លួនមនុស្សដោយបង្ខំ មិនអាចចាត់បញ្ចូលជាប្រភេទ ជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ហើយថា ការបាត់ខ្លួនដោយបង្ខំ មិនសម្រេចបាននូវឋានៈជា

---

[59] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ , ថ្ងៃទី១៥ កុម្ភៈ ២០១១, D427/2/15, ត្រង់កថាខណ្ឌទី ២៣២ ។

[60] សាលក្រមលើសំណុំរឿងលេខ ០០១, កថាខណ្ឌទី ៤៧៦-៤៧៧។

00655363



ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងឆ្នាំ១៩៧៥-១៩៧៩ នោះទេ[61] ។ អៀង សារី មិនបានដាក់អញ្ញត្រកម្មបឋមជាក់លាក់ណាមួយឡើយពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងនេះ ក៏ប៉ុន្តែមានតែអញ្ញត្រកម្មទូទៅមួយដែលថា អវតក មាន "យុត្តាធិការដែលនៅមានកម្រិតក្នុងការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" និងបញ្ជីមួយស្តីពីការដាក់[ឯកសារ]ពីមុនៗ ដែល[ឯកសារ]ខ្លះជំទាស់នឹងការអនុវត្តនូវ "អំពើអមនុស្សធម៌ផ្សេងៗទៀត" រួមមាន អាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ ការបាត់ខ្លួនដោយបង្ខំ និង ការជម្លៀសដោយបង្ខំ, ការធ្វើទារុណកម្ម និងការដាក់ក្នុងមន្ទីរឃុំឃាំងគឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[62]។

៣៣. ជាការឆ្លើយតប សហព្រះរាជអាជ្ញា បានដាក់បញ្ចូលនៅក្នុងនេះ ដោយយោងទៅលើទឡ្ហីករណ៍ទាំងឡាយដូចដែលមានចែងនៅក្នុងកថាខណ្ឌទី ១៨៧-១៨៩ និង ១៩៣-១៩៩ នៃចម្លើយតបរួមរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ នឹងធ្វើសេចក្តីសង្ខេបនៃទឡ្ហីករណ៍ទាំងនោះដូចខាងក្រោមនេះ[63]៖

---

[61] អញ្ញត្រកម្មរបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ, ថ្ងៃទី១៤ កុម្ភៈ ២០១១, E44, កថាខណ្ឌទី ២៥-៣២, ដែលបានយោងដល់ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១៨ តុលា ២០១០, D427/2/1, កថាខណ្ឌទី ៦១-៦២ និងយោងដល់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ និង នួន ជា, ចម្លើយតបរួមរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ, ថ្ងៃទី២៤ កក្កដា ២០១០, D180/2 ("ចម្លើយតបរួមរបស់មេធាវីទាក់ទងទៅនឹងការបាត់ខ្លួនដោយបង្ខំ") ។

[62] សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន៨៩ របស់លោក អៀង សារី, ថ្ងៃទី២៥ កុម្ភៈ ២០១១, E51/4, កថាខណ្ឌទី ២៧ ។ ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្ត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅ អវតក, ថ្ងៃទី២៣ មិថុនា ២០១០, D378/2, កថាខណ្ឌទី ១៣-១៧,១៩, ២១-២៣ ។ ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា តាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម, ថ្ងៃទី១ កញ្ញា ២០១០, D390/1/1/1.3, កថាខណ្ឌទី ៤៦,៤៩, ៦០-៦៣ ។ បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹង ដីកាដំណោះស្រាយ, ថ្ងៃទី២៥ តុលា ២០១០, D427/1/6, កថាខណ្ឌទី២០៥,២០៦,២០៨, ២២០-២៣១ ។ សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី៦ ធ្នូ ២០១០, D427/1/23, កថាខណ្ឌទី ៩៤,៩៧, ៩៩-១០៥ ។

[63] ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ, កថាខណ្ឌទី១៨៧-១៨៩,១៩៣-១៩៩។

៣៤. មាត្រា៥ នៃច្បាប់ អវតក រៀបរាប់តាមលំដាប់លំដោយនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនានា ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អវតក ដែលក្នុងនោះរួមទាំង “អំពើអមនុស្សធម៌ដទៃទៀត” ផង[64]។ អង្គបុរេជំនុំជម្រះបានសំរេចថាមិនមានភាពចាំបាច់ឡើយ ដែលអនុប្រភេទនីមួយៗ នៃ “អំពើអមនុស្សធម៌ដទៃទៀត” តោងតែជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយដាច់ដោយឡែកពីគេ[65] និងថាប្រភេទដ៏ទូលំទូលាយនៃ “អំពើអមនុស្សធម៌ដទៃទៀត” ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានធ្វើឲ្យទៅជាបទព្រហ្មទណ្ឌនៅក្រោមច្បាប់ទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥[66]។ ទាំងអង្គជំនុំជម្រះសាលាដំបូង និងទាំងអង្គបុរេជំនុំជម្រះ សុទ្ធតែឯកភាពថា “អំពើអមនុស្សធម៌ដទៃទៀត”គឺជាប្រភេទសំណល់មួយនៃបទល្មើសទាំងឡាយដែលត្រូវបានបង្កើតឡើង ដើម្បីជៀសវាងកុំឲ្យមានការខ្វះចន្លោះនៅក្នុងច្បាប់ ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្រោមច្បាប់មនុស្សធម៌អន្តរជាតិ[67]។ ប្រភេទសំណល់នេះ រួមមានបទល្មើសផ្សេងដែលមិនសក្តិសម និងស្ថិតនៅក្នុងឧក្រិដ្ឋកម្មណាមួយក្នុងចំណោមឧក្រិដ្ឋកម្មនានាដូចដែលបានរៀបរាប់តាមលំដាប់លំដោយ ក៏ប៉ុន្តែមាន “ស្ថានទម្ងន់ទោសស្រដៀងគ្នាយ៉ាងគ្រប់គ្រាន់ទៅនឹងឧក្រិដ្ឋកម្មនានាដែលបានរៀបរាប់តាមលំដាប់លំដោយ” គឺបានន័យថា អំពើមនុស្សឃាត, ការសម្លាប់រង្គាល, ការធ្វើឲ្យទៅជាទាសករ, និងការនិរទេស[68]។ អង្គបុរេជំនុំជម្រះ បានថ្លែងថា ចំណុចចាប់ផ្តើមនេះអាចនឹងបំពេញបានដោយបទល្មើសណាមួយដែល “(១)មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវិតរស់នៅ និងសេរីភាពរបស់បុគ្គល...ឬ ...(២) ឬដែលម្យ៉ាងទៀតផ្សារភ្ជាប់ទៅនឹងឧក្រិដ្ឋកម្មប្រឆាំង

---

[64] ច្បាប់ អវតក, មាត្រា៥។

[65] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និងអៀង ធីរិទ្ធប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ កុម្ភៈ ២០១១, ឯកសារលេខ D427/2/15, កថាខណ្ឌទី១៥៦ (“សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ចំពោះដីកាដំណោះស្រាយ ” )។

[66] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ចំពោះដីកាដំណោះស្រាយ, កថាខណ្ឌទី១៥៧។ សូមអានផងដែរ សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី៣៦៧។

[67] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ចំពោះដីកាដំណោះស្រាយ, កថាខណ្ឌទី១៥៨។

[68] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី៣៦៧ (ដែលលើកសំអាងលើ តុលាការ ICTY *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Naletilic* និងគូកន, សាលក្រមអង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ IT-98-34-T, ចុះថ្ងៃទី៣១ មីនា ២០០៣, កថាខណ្ឌទី៦៣៦, ICTR, *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Niyitegeka*, សាលក្រមអង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ ICTR-96-14-T, ចុះថ្ងៃទី១៦ ឧសភា ២០០៣ កថាខណ្ឌទី៤៦០។

00655365



នឹងមនុស្សជាតិណាមួយដែលបានរៀបរាប់តាមលំដាប់លំដោយ”[69]។ អង្គបុរេជំនុំជម្រះ ក៏បានរកឃើញផងដែរថា “និយមន័យនៃពាក្យ *អំពើពិរុទ្ធ* សម្រាប់ “អំពើអមនុស្សធម៌ដទៃទៀត” ក្រោមច្បាប់មនុស្សធម៌អន្តរជាតិ គឺមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ តាមដូចដែលថា អាចឱ្យមានសិទ្ធប្រើប្រាស់បាន និងអាចឱ្យព្យាករណ៍ទុកជាមុនបានសម្រាប់ដើមបណ្តឹងសាទុក្ខ ដែលប្រភេទនៃការប្រព្រឹត្តិខ្លះក្រៅពីអំពើមនុស្សឃាត, ការសម្លាប់រង្គាល, ការធ្វើឱ្យទៅជាទាសករ, និងការនីរទេស គួរបានធ្វើឱ្យទៅជាបទព្រហ្មទណ្ឌ ក្នុងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”[70] ។

៣៥. ទឡ្ហីករណ៍របស់ អៀង ធីរិទ្ធ ស្តីពីភាពគ្រប់គ្រាន់នៃការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយទាក់ទងនឹង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលពាក់ព័ន្ធនឹងបញ្ហាលាយឡំគ្នាខាងអង្គច្បាប់ និងអង្គហេតុផង[71] ហើយដែលមិនមែនជាអញ្ញត្រកម្មបឋមទាក់ទងនឹងយុត្តាធិការរបស់អង្គជំនុំជម្រះដែលមានសុពលភាពទេ[72]។ និយមន័យអំពីធាតុផ្សំនៃបទល្មើសណាមួយ និងការកំណត់អំពីថាតើអង្គហេតុដែលមានចែងនៅក្នុងដីកាដំណោះស្រាយបំពេញបានគ្រប់តាមលក្ខខណ្ឌនៃធាតុផ្សំទាំងនោះ មិនមែនជាបញ្ហាទាក់ទងនឹង

---

[69] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ចំពោះដីកាដំណោះស្រាយ, កថាខណ្ឌទី១៦៤។

[70] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ចំពោះដីកាដំណោះស្រាយ, កថាខណ្ឌទី១៦៥។

[71] សូមអាន ឧទាហរណ៍ដូចជា អញ្ញត្រកម្មបឋមរបស់មេធាវី អៀង ធិរិទ្ធិ, ចុះថ្ងៃទី១៤ កុម្ភៈ ២០១១,ឯកសារលេខ E44,កថាខណ្ឌទី២៧ (ដែលមេធាវីបានពិភាក្សាអំពីការរកឃើញនានាផ្នែកភស្តុតាង ដោយសហចៅក្រមស៊ើបអង្កេត) និងកថាខណ្ឌទី៣០-៣១ ( ដែលមេធាវីបានពិភាក្សាអំពី “ការចោទប្រកាន់”អំពីការរំលោភសេពសន្ថវៈទៅវិញទៅមក)។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា “ទាក់ទងនឹងបញ្ហាចុងក្រោយអំពីតើសហចៅក្រមស៊ើបអង្កេតបានមានការភាន់ច្រឡំដែរឬទេនៅក្នុងការចោទពីបទអាពាហ៍ពិពាហ៍ដោយបង្ខំ, អំពើហិង្សាខាងផ្លូវភេទ, និងការបាត់ខ្លួន(មនុស្ស)ដោយបង្ខំ ក្រោមនិយមន័យ នៃពាក្យ “អំពើអមនុស្សធម៌ដទៃទៀត” ដូចដែលបានបញ្ជាក់រួចហើយពីខាងដើម” , អង្គបុរេជំនុំជម្រះ បានរកឃើញថា នេះគឺជាការបង្កើតបានជាបញ្ហាលាយចម្រុះគ្នាមួយអំពីអង្គហេតុ និងអង្គច្បាប់” ហើយគឺមិនមែនជា “បញ្ហាទាក់ទងនឹងយុត្តាធិការទេ” ៖ សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ចំពោះដីកាដំណោះស្រាយ, កថាខណ្ឌទី១៦៦។,

[72] វិធាន៨៩.១ នៃវិធានផ្ទៃក្នុង។

យុត្តាធិការទេ តែវាគឺជាបញ្ហាទាក់ទងនឹងអង្គហេតុ និងអង្គច្បាប់ទៅវិញ ដែលគួរបានធ្វើការដោះស្រាយនៅពេលសវនាការជំនុំជម្រះក្តី ឬមួយយ៉ាងណា?[73] ។

៣៦. សហព្រះរាជអាជ្ញា បានបញ្ជាក់ជាថ្មីឡើងវិញនៅក្នុងដីកាសន្និដ្ឋានរបស់ខ្លួនកាលពីមុនៗថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាខាងផ្លូវភេទ (ដែលរួមបញ្ចូលទាំង ការរំលោភសេពសន្ថវៈ), ការជម្លៀសចេញដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ គឺបំពេញបាន តាមលក្ខខណ្ឌតម្រូវនៃចំណុចចាប់ផ្តើមដើម្បីឲ្យបង្កើតបានទៅជា "អំពើអមនុស្សធម៌ដទៃទៀត"[74]។ ឧក្រិដ្ឋកម្មទាំងនេះមានលក្ខណៈនិងស្ថានទម្ងន់ទោសស្រដៀងគ្នា នឹង អំពើមនុស្សឃាត, ការសម្លាប់រង្គាល, ការធ្វើទារុណកម្ម, ការធ្វើឲ្យទៅជាទាសករ, ការនិរទេស , និងការដាក់នៅក្នុងមន្ទីរឃុំឃាំង ហើយដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវិតរស់នៅ និងសេរីភាពរបស់មនុស្ស។ អំពើហិង្សាខាងផ្លូវភេទ ដែលរួមបញ្ចូលទាំងអំពើនានានៃការរំលោភសេពសន្ថវៈ (នៅក្នុង ឬមិននៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ជាលទ្ធផល គឺបណ្តាលឲ្យមានការខូចខាតធ្ងន់ធ្ងរខាងផ្លូវកាយ និងការរងទុក្ខវេទនាអស់មួយជីវិត។ អំពើនានានៃការរំលោភសេពសន្ថវៈត្រូវបានសម្រេចថាបង្កើតបានជាការធ្វើទារុណកម្ម[75]។ អំពើនានានៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាខាងផ្លូវភេទត្រូវបានធ្វើការហាមប្រាមតាំងពីយូរយារណាស់មកហើយនៅក្នុងច្បាប់ទម្លាប់អន្តរជាតិ ដែលរួមទាំងនៅក្នុងអនុសញ្ញានានានៃទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ផង[76]។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏មានផលប៉ះពាល់ផងដែរដល់ជីវិតរស់នៅ និងសេរីភាពបុគ្គល និងដែលត្រូវបានគេរកឃើញមុនឆ្នាំ១៩៧៥ ថាមានលក្ខណៈស្រដៀងគ្នានឹងការធ្វើឲ្យទៅជាទាសករ[77]។

[73] ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ, កថាខណ្ឌទី២២-២៨។

[74] ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ, កថាខណ្ឌទី១៨៧, ១៩១-១៩៩។

[75] ICTY, រដ្ឋអាជ្ញាទល់នឹង Kunarak និងគូកន, សាលដីកាបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ មិថុនា កថាខណ្ឌទី១៥០-១៥១។

[76] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ចំពោះដីកាដំណោះស្រាយ, កថាខណ្ឌទី១៥១,១៧៣។

[77] អនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ចោលការធ្វើឲ្យទៅជាទាសករ ការជួញដូរទាសករ និងស្ថាប័ននានាហើយនិងការអនុវត្តនានាដែលស្រដៀងគ្នានឹងការធ្វើឲ្យទៅជាទាសករ, ឯកសារលេខ 266 UNTS 3,ដែលបានចូលជាធរមានកាលពីថ្ងៃទី៣០ មេសា ១៩៥៧, ដែលត្រូវបានចុះ

៣៧. ឧក្រិដ្ឋកម្មជម្លៀសចេញដោយបង្ខំ គឺស្រដៀងគ្នាទៅនឹងការនិរទេស ឧក្រិដ្ឋកម្មទាំងពីរនេះមានលក្ខណៈខុសគ្នាតែនៅត្រង់ ទីដៅដែលបុគ្គលទាំងឡាយត្រូវបានគេឱ្យផ្លាស់ទីទៅតែប៉ុណ្ណោះ[78]។ ដែលហេតុដូចនេះ គឺបង្កើតបានទៅជា "អំពើអមនុស្សធម៌ដទៃទៀត" មួយដែលស្ថិតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[79]។ ការជម្លៀសចេញដោយបង្ខំត្រូវបានកំណត់លក្ខណៈសម្បត្តិថាជាឧក្រិដ្ឋកម្មមួយដែលស្ថិតនៅក្រោមធម្មនុញ្ញនៃទីក្រុងនូរ៉ាំប៊ឺហ្គ, ធម្មនុញ្ញរបស់តុលាការសឹក IMTFE, និងក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ដែលហេតុដូចនេះគឺបង្កើតបានជាឧក្រិដ្ឋកម្មមួយក្រោមច្បាប់ទម្លាប់អន្តរជាតិនៅក្នុងអម្លុងពេលដែលពាក់ព័ន្ធ[80]។

៣៨. ឧក្រិដ្ឋកម្មបាត់ខ្លួនមនុស្សដោយបង្ខំ ដែលជា "អំពើអមនុស្សធម៌ដទៃទៀត" មួយ ក៏ត្រូវបានហាមឃាត់នៅក្រោមច្បាប់ទម្លាប់អន្តរជាតិដែរ ក្នុងអម្លុងពេលដែលពាក់ព័ន្ធ។ មានអនុសញ្ញាពីមុនៗចំនួនមួយចំនួនមានបំណងចង់ធ្វើឱ្យរាងចាលចំពោះការបាត់ខ្លួនមនុស្សដោយបង្ខំ[81]។ ក្នុងឆ្នាំ១៩៧៨ មហាសន្និបាតអង្គការសហប្រជាជាតិបានអំពាវនាវដល់រដ្ឋាភិបាលនានាឱ្យបង្កើតជាអាជ្ញាធរផ្សេង

---

ហត្ថលេខាយល់ព្រមដោយប្រទេសកម្ពុជា, កាលពីថ្ងៃទី១២ មិថុនា ១៩៥៧។ បើចង់ដឹងបន្ថែមទៀតស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ *សូមអាន* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ចំពោះដីកាដំណោះស្រាយ, កថាខណ្ឌទី១៩៥។

[78] ICTY, រដ្ឋអាជ្ញា ទល់នឹង *Brđanin*, សាលក្រមអង្គជំនុំជម្រះសាលាដំបូង IT-99-36-T, ចុះថ្ងៃទី១ កញ្ញា២០០៤,កថាខណ្ឌ៥៤២។

[79] ICTY, *ករណីរឿក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Blagojevic* និងគូកន,, សាលក្រមអង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ (IT-02-60-T), ចុះថ្ងៃទី១៧ មករា ២០០៥,កថាខណ្ឌទី ៦២៩-៦៣០។ *ករណីរឿក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Krstic*, សាលក្រមអង្គជំនុំជម្រះសាលាដំបូង (សំណុំរឿងលេខ IT-98-33-T), , ចុះថ្ងៃទី២ សីហា ២០០១,កថាខណ្ឌទី ៥២៣។ *ករណីរឿក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Stakic*, សាលក្រមអង្គជំនុំជម្រះសាលាដំបូង (សំណុំរឿងលេខ IT-97-24-T), , ចុះថ្ងៃទី៣១ កក្កដា ២០០៣, កថាខណ្ឌទី ៧២៣។

[80] ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ, កថាខណ្ឌទី១៨៧, ១៩១-១៩២។

[81] អនុសញ្ញានៃទីក្រុងឡាអេ (ទីIV)ស្តីពីការគោរពច្បាប់និងទម្លាប់ស្តីពីសង្គ្រាមដីគោក និង ឧបសម្ព័ន្ធ៖បទបញ្ញាទាក់ទងនឹងច្បាប់ និងទម្លាប់ស្តីពីសង្គ្រាមលើដីគោក, ចុះថ្ងៃទី ១៨ តុលា ១៩០៧, ឯកសារលេខ U.S.T.S 539, មាត្រា១៤។ អនុសញ្ញា (ទី IV) ទាក់ទងនឹងការការពារចំពោះជនស៊ីវិលនៅក្នុងពេលសង្គ្រាម, ចុះថ្ងៃទី១២ សីហា ១៩៤៩, ឯកសារលេខ 75 U.N.T.S 287, មាត្រា២៦,១៣៧។

១ដែលទទួលការខុសត្រូវមុខច្បាប់ចំពោះឧក្រិដ្ឋកម្មបាត់ខ្លួនមនុស្សដោយបង្ខំ[82]។ ការបាត់ខ្លួនមនុស្សដោយបង្ខំក៏ត្រូវបានតម្រូវឱ្យផងដែរឱ្យមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌ នៅក្នុងដំណើរការនីតិវិធីតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ នៅមុនកាលបរិច្ឆេទខែមេសា ឆ្នាំ១៩៧៥ ដែលក្នុងនោះរួមមាន*ករណីរឿងក្តីស្វែងយុត្តិធម៌មួយ* ដែលក្នុងនោះមានការនិរទេសអ្នកទោសដោយសម្ងាត់ ដែលត្រូវបានរកឃើញថាជាអំពើអមនុស្សធម៌[83] ។

៣៩. ការធ្វើទារុណកម្មបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គិតត្រឹមឆ្នាំ១៩៧៥[84]។ ការធ្វើទារុណកម្ម ត្រូវបានបញ្ចូលក្នុងនិយមន័យនៃឧក្រិដ្ឋកម្មនេះក្នុងច្បាប់គ្រប់គ្រងក្រុមប្រឹក្សា (Control Council Law) លេខ១០[85]។ ការហាមឃាត់ការធ្វើទារុណកម្មអាចត្រូវបានរកឃើញនៅក្នុងលិខិតុបករណ៍អន្តរជាតិជាច្រើន រួមទាំង អនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុបឆ្នាំ១៩៥០[86], កតិកាសញ្ញា ICCPR ឆ្នាំ១៩៦៦[87], អនុសញ្ញាសិទ្ធិមនុស្សសហរដ្ឋអាមេរិកឆ្នាំ១៩៦៩[88], សេចក្តីប្រកាសរបស់មហាសន្និ

---

[82] ឯកសារ អង្គការសហប្រជាជាតិ លេខA/RES/33/173, ចុះថ្ងៃទី២០ ធ្នូ ១៩៧៨។

[83] ករណីរកយុត្តិធម៌, ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ សវនាការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការសឹកNuremberg នៅក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ (ឆ្នាំ១៩៤៧, ក្បាលទី៣),កថាខណ្ឌទី១០៥៧-១០៥៨,១០៦១។*សូមអានផងដែរ*ពីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងសវនាការជំនុំជម្រះក្តីវរៈសេនីយត្រីជនជាតិអាល្លឺម៉ង់ដែលជាឧក្រិដ្ឋជនសង្គ្រាម ដំណើការសវនាការរបស់តុលាការសឹកអន្តរជាតិដែលបើកធ្វើនៅទីក្រុងនូរ៉ាំប៊ឺហ្គ ប្រទេសអាល្លឺម៉ង់(ឆ្នាំ១៩៤៦, ក្បាលទី២២)ដែលករណីការបាត់ខ្លួនដោយបង្ខំត្រូវបានសម្រេចថាជាបទឧក្រិដ្ឋកម្មសង្គ្រាមមួយ។

[84] សូមមើល ចម្លើយតបរួមទៅនឹងដីកាដំណោះស្រាយ, កថាខ័ណ្ឌទី១៨៩ ។

[85] William Schabas, តុលាការព្រហ្មទណ្ឌអន្តរជាតិនៃ អសប, អតីតយូហ្គោស្លាវី, រ្វ៉ាន់ដា, សៀរ៉ាឡេអូន, សារព័ត៌មានមហាវិទ្យាល័យខាំប្រ៊ីច (Cambridge University Press), ឆ្នាំ២០០៦, ទំព័រ២០៦, យោងច្បាប់គ្រប់គ្រងក្រុមប្រឹក្សា លេខ១០, ការផ្តន្ទាទោសបុគ្គលដែលមានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មសង្គ្រាម, ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងប្រឆាំងមនុស្សជាតិ, មាត្រា II(l)(គ): ច្បាប់គ្រប់គ្រងក្រុមប្រឹក្សា លេខ១០, ការផ្តន្ទាទោសបុគ្គលដែលមានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មសង្គ្រាម, ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងប្រឆាំងមនុស្សជាតិ, ២០ ធ្នូ ១៩៤៥, រដ្ឋកិច្ចផ្លូវការរបស់ក្រុមប្រឹក្សាគ្រប់គ្រងរបស់ប្រទេសអាល្លឺម៉ង់, លេខ៣, ទីក្រុងប៊ែកឡាំង, ៣១ មករា ១៩៤៦, ៥០-៥៥, មាត្រា២(ក) ។

[86] មាត្រា៣ នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប ។

[87] មាត្រា៧ នៃកតិកាសញ្ញា ICCPR ។

[88] មាត្រា៥(២) នៃអនុសញ្ញាសិទ្ធិមនុស្សសហរដ្ឋអាមេរិក ។

បាតអង្គការសហប្រជាជាតិប្រឆាំងការធ្វើទារុណកម្មឆ្នាំ១៩៧៥[89], អនុសញ្ញាប្រឆាំងការធ្វើទារុណកម្មឆ្នាំ១៩៨៤ (CAT),[90] និងធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនឆ្នាំ១៩៨១[91]។ តុលាការ ICTY បានរកឃើញនិយមនេះនៅក្នុងអនុសញ្ញា CAT ដែលឆ្លុះបញ្ចាំងឱ្យឃើញពីបញ្ហានេះតាមរយៈសេចក្តីប្រកាសឆ្នាំ១៩៧៥ ដែលនឹងក្លាយជាសេចក្តីប្រកាសនៃច្បាប់ទម្លាប់អន្តរជាតិ[92] ហើយក៏បានសម្រេចផងដែរថា ការហាមឃាត់ការធ្វើទារុណកម្មបានទទួលនូវឋានៈជានិយមនៃច្បាប់អន្តរជាតិដែលគេមិនអាចបដិសេធបាន[93]។ ការធ្វើទារុណកម្មត្រូវបានចុះបញ្ជីថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុង *សេចក្តីព្រាងក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពនិងសន្តិសុខមនុស្សជាតិ* ឆ្នាំ១៩៩៦ របស់គណៈកម្មការទទួលបន្ទុកច្បាប់អន្តរជាតិ ("សេចក្តីព្រាងក្រម ILC")[94]។ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ក៏មានចែងអំពីបទឧក្រិដ្ឋនៃការធ្វើទារុណកម្មដែរ[95]។ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចនៅក្នុងសំណុំរឿងលេខ០០១ ថា ការធ្វើទារុណកម្ម គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងឆ្នាំ១៩៧៥[96] ។

៤០. ចុងបញ្ចប់ ការដាក់ក្នុងមន្ទីរឃុំឃាំងក៏បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងឆ្នាំ ១៩៧៥[97] ផងដែរ ។ ដូចជាការធ្វើទារុណកម្មដែរ ការដាក់ក្នុងមន្ទីរឃុំឃាំងត្រូវបានដាក់បញ្ចូល ជាឧក្រិដ្ឋកម្ម

[89] សេចក្តីប្រកាសស្តីពីការការពារមនុស្សគ្រប់រូបពីការទទួលរងនូវការធ្វើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ដទៃទៀត ឬការផ្តន្ទាទោសចំពោះ អំពើបន្ទាបបន្ថោកដទៃទៀត, សេចក្តីសម្រេចរបស់ UNGA លេខ 3452, ៩ ធ្នូ ១៩៧៥ ។

[90] អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ និងអំពើបន្ទាបបន្ថោកដទៃទៀត ឬការផ្តន្ទាទោស, ១០ ធ្នូ ១៩៨៤ ។

[91] មាត្រា៥ នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន ។

[92] សាលដីកាជំនុំជម្រះរឿងក្តី *Celebici*, កថាខ័ណ្ឌទី៤៥៩ ។ *រដ្ឋអាជ្ញា ទល់នឹង Furundzija*, IT-95-17/1-A, សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ២១ កក្កដា ២០០០, កថាខ័ណ្ឌទី១១១ ។

[93] តុលាការ ICTY, *រដ្ឋអាជ្ញា ទល់នឹង Furundzija*, IT-95-17/1, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, ១០ ធ្នូ ១៩៩៨, កថាខ័ណ្ឌទី១៥១-១៥៣ ។ *រដ្ឋអាជ្ញា ទល់នឹង Krnojelac*, IT-97-25-T, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, ១៥ មីនា ២០០២, កថាខ័ណ្ឌទី១៨២ ។

[94] សេចក្តីព្រាងក្រម ILC, មាត្រា១៨(គ) ។

[95] មាត្រា៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។

[96] សាលក្រមសំណុំរឿងលេខ០០១, កថាខ័ណ្ឌទី៣៥២-៣៥៣ ។

[97] សូមមើល ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ, កថាខណ្ឌទី ១៨៨ ។

ប្រឆាំងមនុស្សជាតិយ៉ាងជាក់លាក់ នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងក្រុមប្រឹក្សា លេខ១០[98] ។ ការហាមឃាត់លើ ការដាក់ក្នុងមន្ទីរឃុំឃាំង ដែលមានមូលដ្ឋាននៅលើសិទ្ធិក្នុងការមាន សេរីភាព ត្រូវបានទទួលស្គាល់នៅក្នុងលិខិតុបករណ៍អន្តរជាតិមួយចំនួន រួមទាំងអនុសញ្ញាស្តីពី សិទ្ធិមនុស្សនៅអឺរ៉ុប[99], អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ[100], អនុសញ្ញាស្តីពីសិទ្ធិមនុស្សនៅអាមេរិក ឆ្នាំ១៩៦៩[101] និង ធម្មនុញ្ញស្តីពីសិទ្ធិមនុស្សនិងសិទ្ធិមហាជន នៅអាហ្វ្រិក ឆ្នាំ ១៩៨៦[102] ដោយមានការពឹងផ្អែកជាបឋមនៅលើការចម្រើនលូតលាស់នៃច្បាប់ អន្តរជាតិ នៅមុនឆ្នាំ១៩៧៥ តុលាការ ICTY បានរកឃើញថា ការដាក់ក្នុងមន្ទីរឃុំឃាំង បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្រោមច្បាប់តាមទម្លាប់អន្តរជាតិ[103]។ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងសេចក្តីព្រាងក្រម ILC រួមទាំង "ការដាក់ក្នុង មន្ទីរឃុំឃាំងតាមទំនើងចិត្ត"[104] ផង។ នៅក្នុងសំណុំរឿងលេខ០០១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការដាក់ក្នុងមន្ទីរឃុំឃាំង បង្កើតបានជាឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ចាប់ពីឆ្នាំ១៩៧៥[105] ។

## ឆ. អៀង សារី - ការលើកលែងទោស និងការអនុគ្រោះទោស

---

[98] ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ, កំណត់សម្គាល់ជើងទំព័រ លេខ៤៩១ ក្នុងកថាខណ្ឌទី ១៩១, *ដោយបានលើកឡើងពី* ច្បាប់ស្តីពីការគ្រប់គ្រងក្រុមប្រឹក្សា លេខ១០, ការផ្តន្ទាទោសបុគ្គលដែលមានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងប្រឆាំងមនុស្សជាតិ, ថ្ងៃទី២០ ធ្នូ ១៩៤៥, មាត្រា II(១)(គ), បោះពុម្ពឡើងវិញនៅក្នុងសវនាការស្តីពីឧក្រិដ្ឋកម្មសង្គ្រាម នៅចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់ស្តីពីការគ្រប់គ្រងក្រុមប្រឹក្សា លេខ១០ (វ៉ុលុមទី I), ទំព័រទី ១៦-១៧ ។

[99] មាត្រា៥ នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សនៅអឺរ៉ុប ។

[100] មាត្រា៩ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ។

[101] មាត្រា៥(២) និង៧ នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សនៅអាមេរិក ។

[102] មាត្រា៦ នៃធម្មនុញ្ញស្តីពីសិទ្ធិមនុស្ស និងសិទ្ធិមហាជននៅអាហ្វ្រិក ។

[103] ICTY, *រដ្ឋអាជ្ញា ទល់នឹង Krnojelac*, សំណុំរឿងលេខ IT-97-25-T, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៥ មីនា ២០០២, កថាខណ្ឌទី ១០៩-១១១ ។ *សូមមើលផងដែរ Kordić*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២៦ កុម្ភៈ ២០០១, កថាខណ្ឌទី ២៩៥-៣០៣ ។ *Simić*, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៧ តុលា ២០០៣, កថាខណ្ឌទី ៦៣-៦៥ ។

[104] សេចក្តីព្រាងក្រម ILC, មាត្រា ១៨(ឋ) ។

[105] សាលក្រមលើសំណុំរឿងលេខ០០១, កថាខណ្ឌទី ៣៤៧ ។

៤១. អៀង សារី បានពោលអះអាងក្នុងអញ្ញត្រកម្មបឋមថា អវតក មិនមានយុត្តាធិការលើរូបគាត់នោះឡើយដោយសារតែ "ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនៅតែមានសុពលភាព"[106]។

៤២. ជាការឆ្លើយតបវិញ សហព្រះរាជអាជ្ញាបានដាក់បញ្ចូលនូវសេចក្តីយោងទៅលើទឡ្ហីករណ៍ផ្សេងៗដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី៥៨ ដល់៦៧ នៃចម្លើយតបរួម ទៅនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ[107] និងសង្ខេបទឡ្ហីករណ៍របស់ខ្លួនដូចតទៅនេះ៖ ទីមួយការលើកលែងទោសដែលត្រូវបានចេញទៅឱ្យ អៀង សារី នោះគឺទាក់ទងតែទៅនឹងការកាត់ទោស នៅក្នុងពេលអនាគតពីបទរំលោភលើច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ឆ្នាំ១៩៩៤ តែប៉ុណ្ណោះ[108] ដែលច្បាប់នោះបានដាក់ឱ្យទៅជាបទល្មើសព្រហ្មទណ្ឌចំពោះសមាជិកនៃ "អង្គការនយោបាយ ឬកងកម្លាំងយោធារបស់ក្រុមកម្ពុជាប្រជាធិបតេយ្យ"[109] ហើយដែលមិនមានការទាក់ទងនឹងឧក្រិដ្ឋកម្មនានា ដែលរូបគាត់ត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះឡើយ។ ការលើកលែងទោសដែលត្រូវបានអនុញ្ញាតឱ្យ អៀង សារី នៅក្នុងព្រះរាជក្រឹត្យនោះ ត្រូវបានកំរិតកំណត់យ៉ាងច្បាស់ គឺលើកលែងឱ្យរួចខ្លួនតែពីទោសប្រហារជីវិត និងពីការរឹបអូសទ្រព្យសម្បត្តិ ដែលត្រូវបានចេញដីកាបង្គាប់ដោយតុលាការប្រជាជនបដិវត្តន៍កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ តែប៉ុណ្ណោះ[110]។ ក្នុងករណីណាក៏ដោយ ការផ្តល់ការលើក

[106] សេចក្តីសង្ខេបនៃអញ្ញត្រកម្មបឋមរបស់ អៀង សារី អនុលោមតាមវិធាន៨៩, ចុះថ្ងៃទី២៥ កុម្ភៈ ២០១១, ឯកសារលេខ E51/4, កថាខណ្ឌទី២២។

[107] ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ, កថាខណ្ឌទី៥៨-៦៧។

[108] ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០១ នស.៩៤,ចុះថ្ងៃទី១៥ កក្កដា១៩៩៤ ("ច្បាប់ស្តីពីការដាក់ឱ្យនៅក្រៅច្បាប់") ដែលអាចបើកមើលតាមអាស័យដ្ឋានគេហទំព័រ: http://www.cambodia.gov.kh/krt/pdfs/Law%20to% 20Outlaw% 20DK%20Group%201994.pdf ។

[109] ច្បាប់ស្តីពីការដាក់ឱ្យនៅក្រៅច្បាប់, មាត្រា២។ មាត្រា៧នៃច្បាប់ដាក់ឱ្យនៅក្រៅច្បាប់បានចែងច្បាស់ពីការផ្តល់អំណាចដល់ព្រះមហាក្សត្រកម្ពុជាជាអ្នកប្រទាននូវការលើកលែងទោសឬការអនុគ្រោះទោសដល់ជនទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងច្បាប់នេះ។

[110] ព្រះរាជក្រិត្យ ចុះថ្ងៃទី១៤កញ្ញា ១៩៩៦, ឯកសារលេខ D366/7.1.191 ត្រង់លេខ ERN 00523598។

លែងទោស ឬការអនុគ្រោះទោសចំពោះករណីឧក្រិដ្ឋកម្មទាំងឡាយដែល(តាមគោលការណ៍អន្តរជាតិ)*កំណត់ត្រូវតែផ្ដន្ទាទោសដាច់ខាត* តួយ៉ាងដូចជា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, និងការបំពារបំពានលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវ គឺមិនអាចមានសុពលភាពបានទេក្រោមច្បាប់អន្តរជាតិ ហើយ (ការលើកលែងទោសនេះ) មិនអាចឲ្យតុលាការនេះជាប់កាតព្វកិច្ចអនុវត្តតាមបានឡើយ ។

៤៣. អង្គបុរេជំនុំជម្រះបានពិនិត្យពិចារណា ហើយបានច្រានចោលនូវទឡ្ហីករណ៍របស់របស់ អៀង សារី ចំនួនពីរលើករួចមកហើយ។ នៅក្នុងដីកាសម្រេចរបស់ខ្លួនកាលពីខែតុលា ឆ្នាំ២០០៨ លើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី អំពីការឃុំខ្លួនគាត់បណ្ដោះអាសន្ន អង្គបុរេជំនុំជម្រះសម្រេចថា ការលើកលែងទោសឲ្យរួចពីការកាត់ទោសក្រោមច្បាប់ឆ្នាំ១៩៩៤ ស្ដីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ដូចដែលមាននៅក្នុងព្រះរាជក្រឹត្យនោះ “មិនអាចឲ្យយល់ឃើញថា អាចនឹងមានអានុភាពក្នុងការទប់ស្កាត់មិនឲ្យ អវតក កាត់ក្ដីឲ្យមានទោសនោះបានឡើយ”[111] ។ ក្នុងខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានច្រានចោលនូវបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ចំពោះដីកាដំណោះស្រាយ ដោយបានផ្អែកលើមូលដ្ឋាននៃការលើកលែងទោស និងការអនុគ្រោះទោស[112] ។

## ជ. អៀង សារី - ការកាត់ក្ដីពីរដង

[111] សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់ឲ្យឃុំខ្លួន អៀង សារី, ចុះថ្ងៃទី១៧ តុលា ២០០៨, ឯកសារលេខ C22/I/74, កថាខណ្ឌទី៦១ (“សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ការឃុំខ្លួន អៀង សារី”)។ អង្គបុរេជំនុំជម្រះក៏បានធ្វើសេចក្ដីសន្និដ្ឋានផងដែរថា “សុពលភាពនៃការឃុំខ្លួនមានភាពមិនប្រាកដប្រជា,” ទោះបីជាការវិភាគមានភាពច្រឡំបល់ដោយសារការបកស្រាយមិនត្រឹមត្រូវលើព្រះរាជក្រឹត្យថាបានប្រើពាក្យ “លើកលែងទោស” ជាជំនួសឲ្យពាក្យ “អនុគ្រោះទោស” ទៅវិញ ទាក់ទងទៅនឹងការផ្ដន្ទាទោសអស់មួយជីវិតកាលពីឆ្នាំ១៩៧៩ (*សូមអាន* កថាខណ្ឌទី៥៥-៥៨)។

[112] សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១៣ មករា ២០១១,ឯកសារលេខ D427/1/26,កថាខណ្ឌទី៤។

៤៤. អៀង សារី ក៏លើកយកជាអញ្ញត្រកម្មដែរថា អ.វ.ត.ក ពុំមានយុត្តាធិការលើរូបគាត់ទេ "ដោយសារគោលការណ៍ *គ្មានការកាត់ក្តីពីរដងចំពោះបទល្មើសតែមួយ*"[113] ។

៤៥. ជាការឆ្លើយតប សហព្រះរាជអាជ្ញា ធ្វើការដាក់បញ្ចូលដោយប្រើសេចក្តីយោងលើអំណះអំណាងដែលមាននៅចែងនៅក្នុងកថាខ័ណ្ឌទី៦៨ ដល់ ៨២ នៃចម្លើយតបរួម ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[114] និងសន្និដ្ឋានថា ការចោទប្រកាន់ អៀង សារី មិនត្រូវបានរារាំងដោយគោលការណ៍ការកាត់ក្តីពីរដងចំពោះបទល្មើសតែមួយ ទោះនៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក៏ដោយ ។ មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានកម្រិតចំពោះការអនុវត្តនៃគោលការណ៍ការកាត់ក្តីពីរដងចំពោះបទល្មើសតែមួយ ចំពោះករណីដែលជនជាប់ចោទត្រូវបាន "រួចខ្លួនជាស្ថាពរ" ។ ស្រដៀងគ្នានេះដែរ គោលការណ៍ការកាត់ក្តីពីរដងចំពោះបទល្មើសតែមួយមិនអនុវត្តបានឡើយ នៅក្រោមមាត្រា១៤(៧) នៃកតិកាសញ្ញា ICCPR ដោយសារសាលក្រមរបស់តុលាការប្រជាជនបដិវត្តន៍ (PRT) កើតចេញពីការកាត់ក្តីដោយ*កំបាំងមុខ* ហេតុដូច្នេះហើយបានជាមិនអាចត្រូវបានគេពិចារណាថា ស្ថាពរ នៅក្រោមច្បាប់ និងនីតិវិធីកម្ពុជាដែលចែងថា ការកាត់ទោសទាំងឡាយណាដោយ*កំបាំងមុខ* ត្រូវបានទុកមួយអន្លើនៅពេលណាចុងចោទត្រូវបានចាប់ខ្លួន ឬចុះចូល ហើយការកាត់ក្តីឡើងវិញនឹងត្រូវធ្វើឡើង[115] ។ ទោះក្នុងព្រឹត្តិការណ៍ណាក៏ដោយ ច្បាប់អន្តរជាតិចែងថា គោលការណ៍នៃការកាត់ក្តីពីរដងចំពោះបទល្មើសតែមួយមិនអនុវត្តទេនៅពេលសាលាក្តីអន្តរជាតិធ្វើការអនុវត្តការចោទប្រកាន់លើកទីពីរក្រោយពីការកាត់ទោសថ្នាក់ជាតិលើកទីមួយ ដូចជាសវនាការកាត់សេចក្តីនៃតុលាការប្រជាជនបដិវត្តន៍ជាដើម ដែលខកខានមិនបានបំពេញទៅតាមកិច្ចការពារចំពោះការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ជាអន្តរជាតិ ។ ក្នុងចំណោមបញ្ហា

---

[113] សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន៨៩ របស់លោក អៀង សារី, ថ្ងៃទី២៥ កុម្ភៈ ២០១១, E51/4, កថាខណ្ឌទី ២៣ ។

[114] ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌទី៥៨-៦០, ៦៨-៨២ ។

[115] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា៤១០, ៤១២, ៤៨៩-៤៩៣ ។

ផ្សេងទៀត អៀង សារី ត្រូវបានកាត់សេចក្ដីដោយ*កំបាំងមុខ* ដោយតុលាការប្រជាជនបដិវត្តន៍ នៅក្នុងសវនាការជំនុំជម្រះក្ដីមួយដែលប្រើពេលតែមួយសប្ដាហ៍ ហើយដែលមិនអាចប្ដឹងឧទ្ធរណ៍បានទៅទៀត ។ គាត់គ្មានមេធាវីការពារក្ដីប្រកបដោយសមត្ថភាពធ្វើតំណាងផលប្រយោជន៍របស់គាត់ទេ; ផ្ទុយមកវិញ មេធាវីការពារក្ដីរបស់គាត់ដែលត្រូវបានចាត់តាំងនោះ មិនបានសួរសាក្សីរបស់គូបដិបក្ខទេ និងថែមទាំងបានដាក់សេចក្ដីថ្លែងការប្រឆាំង អៀង សារី, បានសារភាពពីពិរុទ្ធភាពរបស់គាត់ និងបានកោតសរសើរអំពីការកាត់ទោសរបស់គាត់នៅក្នុងសេចក្ដីថ្លែងការណ៍បិទការចោទប្រកាន់ទៀតផង ។

៤៦. ចំពោះអំណះអំណាងទាក់ទងនឹងការលើកលែងទោស និងការអនុគ្រោះទោស អង្គបុរេជំនុំជម្រះធ្លាប់បានពិចារណាពីរដងរួចមកហើយលើអំណះអំណាងរបស់ អៀង សារី អំពីគោលការណ៍ការកាត់ក្ដីពីរដងចំពោះបទល្មើសតែមួយនេះ ។ ក្នុងខែតុលា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានកត់សំគាល់ថា ការចោទប្រកាន់នាពេលនេះហាក់ដូចជាបានបញ្ចូលបទល្មើសបន្ថែម និងខុសគ្នាពីការកាត់ទោសចំពោះអំពើប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៧៩ ដូច្នេះបញ្ហានេះមិនអាចលើកយកមកដោះស្រាយឱ្យបានពេញលេញនោះទេ រហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចេញ[116] ។ ក្នុងខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានច្រានចោលបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយផ្អែកលើគោលការណ៍ *គ្មានការកាត់ក្ដីពីរដងចំពោះបទល្មើសតែមួយ* នេះឯង[117] ។

### ឈ. ខៀវ សំផន - យុត្តាធិការបុគ្គល

[116] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការឃុំខ្លួន អៀង សារី, កថាខណ្ឌទី៥១-៥៤ ។

[117] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៣ មករា ២០១១, D427/1/26, កថាខណ្ឌទី៣ ។ សំអាងហេតុទាំងស្រុងចំពោះសេចក្ដីសម្រេចនេះនៅមិនទាន់បានផ្សព្វផ្សាយដោយ អបជ នៅឡើយ ។

៤៧. នៅក្នុងអញ្ញត្រកម្មបឋមរបស់ខ្លួន ខៀវ សំផន បានពោលអះអាងថាគាត់មិនឋិតនៅក្នុងយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះនេះទេ ពីព្រោះគាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់ម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយក៏មិនមែនជាអ្នកទទួលខុសត្រូវម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តក្នុងរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យដែរ ។

៤៨. មាត្រា ១ និង ២ នៃច្បាប់ អវតក និង កិច្ចព្រមព្រៀង អវតក បានបង្កើតយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះនេះទៅលើពួក "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួល ខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩"[118] ។

៤៩. ការប្រើសន្ទាន "និង" នៅក្នុងបទប្បញ្ញត្តិទាំងនេះ បង្កើតបានថាមានបុគ្គលពីរប្រភេទដាច់ដោយឡែកពីគ្នា ដែលឋិតនៅក្រោមយុត្តាធិការរបស់ អវតក៖ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តក្នុងរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជនជាប់ចោទម្នាក់ មិនចាំបាច់ ជាមេដឹកនាំជាន់ខ្ពស់ផង និងជាជនដែលទទួលខុសត្រូវខ្ពស់ផង នោះទេដើម្បីឲ្យខ្លួនឋិតនៅក្រោមយុត្តាធិការរបស់ អវតក ដូចដែលអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់រួចហើយដូច្នេះដែរ ។ នៅក្នុងសាលក្រមលើសំណុំរឿងលេខ ០០១ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា អវតក មានយុត្តាធិការបុគ្គលលើប្រធានមន្ទីរស-២១ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ថាជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតម្នាក់ ចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្ត"ក្នុងរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ

[118] មាត្រា ១ និង ២ នៃច្បាប់ អវតក ។ មាត្រា ១ និង ២.១ នៃកិច្ចព្រមព្រៀង អវតក ។

ហើយហេតុដូច្នោះ "មិនចាំបាច់ត្រូវពិនិត្យលើបញ្ហាថាតើជនជាប់ចោទរូបនេះជា មេដឹកនាំជាន់ខ្ពស់ ឬក៏មិនមែន នោះឡើយ"[119] ។

៥០. ទោះបីជាវាក្យស័ព្ទ "មេដឹកនាំជាន់ខ្ពស់" និងជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" មិនត្រូវបានផ្តល់និយមន័យនៅក្នុងច្បាប់ *អវតក*, កិច្ចព្រមព្រៀង *អវតក* ឬវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះនេះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបកស្រាយនិយមន័យនៃវាក្យស័ព្ទទាំងនោះដោយពឹងផ្អែកលើប្រវត្តិតាក់តែងច្បាប់របស់ *អវតក* និងយុត្តិសាស្ត្រអន្តរជាតិ ដែលបានធ្វើការបកស្រាយវាក្យស័ព្ទស្រដៀងគ្នានេះ[120] ។

៥១. ប្រវត្តិតាក់តែងច្បាប់ និងកិច្ចព្រមព្រៀង *អវតក* បានឆ្លុះបញ្ចាំងនៅក្នុងឯកសារនានាដូចជា របាយការណ៍របស់ក្រុមអ្នកជំនាញ អសប ក្នុងឆ្នាំ១៩៩៩[121] និងកិច្ចពិភាក្សាដេញដោលរបស់សភាជាតិ[122]

---

[119] សាលក្រមលើសំណុំរឿងលេខ ០០១, កថាខណ្ឌទី ២៥ ។ ក្នុងកថាខណ្ឌទី ១៧ នៃសាលក្រមនេះ អង្គជំនុំជម្រះសាលាដំបូង បានថ្លែងថា យុត្តាធិការបុគ្គលត្រូវបាន "កំណត់ចំពោះ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" ឬ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត..."" (សង្កត់ន័យបន្ថែមដោយគូសបន្ទាត់ពីក្រោម) ។

[120] សាលក្រមលើសំណុំរឿងលេខ ០០១, កថាខណ្ឌទី ១៩-២២ ។

[121] របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបានបង្កើតឡើងដោយអនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៥២/១៣៥, UN Doc. Nos. A/53/850 និង S/1999/231, ថ្ងៃទី១៨ កុម្ភៈ ១៩៩៩ ("របាយការណ៍របស់ក្រុមអ្នកជំនាញ") ។ ក្នុងឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បី "ស្វែងរកការពិត" អំពីរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និង "នាំយកជនទាំងឡាយដែលទទួលខុសត្រូវទៅជំនុំជម្រះ" U.N. Doc. No. A51/930 និង S/1997/488, ថ្ងៃទី២៤ មិថុនា ១៩៩៧ (ដោយបានភ្ជាប់លិខិតមួយពីនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា នរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន ជូនទៅលោកអគ្គលេខាធិការ)។ នៅខែកុម្ភៈ ១៩៩៨ មហាសន្និបាត អសប បានអនុម័តលើសេចក្តីសម្រេចមួយលេខ ៥២/១៣៥ ដែលបានអំពាវនាវដល់លោកអគ្គលេខាធិការឲ្យបង្កើត "ក្រុមអ្នកជំនាញ" មួយដើម្បីឆ្លើយតបទៅនឹងសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា ។ សេចក្តីសម្រេចរបស់មហាសន្និបាត អសប លេខ ៥២/១៣៥ ដែលមានចំណងជើងថា *ស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា*, U.N. Doc. No. A/RES/52/135, ចុះថ្ងៃទី២៧ កុម្ភៈ ១៩៩៨, កថាខណ្ឌទី ១៦ ។ ក្រុមមួយដែលមានអ្នកជំនាញបីនាក់ ត្រូវបានចាត់តាំងឡើងដោយលោកអគ្គលេខាធិការ ដើម្បីធ្វើការវាយតម្លៃពីភាពដែលអាចធ្វើបាន និងផ្តល់អនុសាសន៍ពីជម្រើសនានាតាមផ្លូវច្បាប់ដើម្បីនាំពួកមេដឹកនាំខ្មែរក្រហមយកមកជំនុំជម្រះ ចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ។

[122] ប្រតិចារឹក៖ សម័យប្រជុំលើកទី១ នៃនីតិកាលទី៣ របស់រដ្ឋសភាកម្ពុជា, ថ្ងៃទី៤-៥ តុលា ២០០៤, D288/6.9/8.22, ERN 00336414-18 ("កិច្ចពិភាក្សាដេញដោលរបស់សភាជាតិ") ។

។ របាយការណ៍របស់ក្រុមអ្នកជំនាញ អសប បានសន្និដ្ឋានថា បុគ្គលទាំងឡាយដែលត្រូវធ្វើការចោទប្រកាន់ត្រូវមានរួមបញ្ចូលទាំងពួក "មេដឹកនាំជាន់ខ្ពស់ដោយមានការទទួលខុសត្រូវលើការរំលោភបំពាន ក៏ដូចជាជនទាំងឡាយដែលនៅថ្នាក់ទាបជាង ដែលជាប់ទាក់ទងដោយផ្ទាល់នៅក្នុងអំពើសាហាវយង់ឃ្នងបំផុត"[123] ។ ក្នុងអំឡុងពេលនៃកិច្ចពិភាក្សាដេញដោលរបស់សភាជាតិកាលពីខែតុលា ឆ្នាំ២០០៤ ស្តីពីច្បាប់ អវតក ក្នុងការឆ្លើយតបទៅនឹងសំណួរមួយសុំឱ្យធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់ពីវិសាលភាពនៃបុគ្គល ដែលត្រូវធ្វើការជំនុំជម្រះក្តី ឯ.ឧ. សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារ [សហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេសដើម្បីរៀបចំនីតិវិធី] សម្រាប់កាត់ទោស [ឧក្រិដ្ឋជន] ខ្មែរក្រហម[124] បានពន្យល់ថា មាត្រា ២ នៃសេចក្តីព្រាងច្បាប់មានបំណងអនុញ្ញាតឱ្យមានការកាត់សេចក្តីលើ "ក្រុមគោលដៅចំនួនពីរប្រភេទ" គឺៈ ទី១) "មេដឹកនាំជាន់ខ្ពស់" ដែលជាការផ្តោតទៅនឹងបុគ្គលទាំងឡាយដែលបានកាន់"តំណែងធម្មតា" និង ទី២) "ជនទាំងឡាយណាដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ ក៏ប៉ុន្តែបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដូចជាពួកមេដឹកនាំជាន់ខ្ពស់ដែរ" ។

៥២. ច្បាប់លក្ខន្តិកៈ និងសេចក្តីសម្រេចនានារបស់តុលាការអន្តរជាតិដទៃទៀតក៏បានផ្តល់នូវការណែនាំពីនិយមន័យនៃពាក្យស័ព្ទ "មេដឹកនាំជាន់ខ្ពស់" និងបុគ្គលដែល "ទទួលខុសត្រូវខ្ពស់បំផុត" ផងដែរ ហើយដែលអង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែក ក្នុងការវិនិច្ឆ័យលើបញ្ហាយុត្តាធិការបុគ្គលក្នុងសំណុំរឿងលេខ ០០១[125] ។

[123] របាយការណ៍របស់ក្រុមអ្នកជំនាញ, កថាខណ្ឌទី ១១០ ។ សាលក្រមលើសំណុំរឿងលេខ ០០១, កថាខណ្ឌទី ២០ ។

[124] កិច្ចពិភាក្សាដេញដោលរបស់សភាជាតិ, ត្រង់លេខ ERN 00336417 ។

[125] សាលក្រមលើសំណុំរឿងលេខ ០០១, កថាខណ្ឌទី ២២ ។

៥៣. យុត្តាធិការនៃតុលាការ ICTY រួមបញ្ចូលនូវគ្រប់បុគ្គលទាំងអស់ដែលទទួលខុសត្រូវចំពោះការបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិនៅក្នុងអតីតប្រទេសយូហ្គោស្លាវី[126] ។ ទោះជាយ៉ាងដូច្នេះក៏ដោយ ក្នុងគោលបំណងដើម្បីបំពេញការងាររបស់ខ្លួនឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន តុលាការ ICTY ត្រូវបានណែនាំឱ្យផ្តោតការយកចិត្តទុកដាក់លើការកាត់ក្តីលើ ពួក "មេដឹកនាំជាន់ខ្ពស់បំផុតដែលបានសង្ស័យថាបានទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានាដែលនៅក្រោមយុត្តាធិការនៃតុលាការនោះ[127] ហើយឱ្យផ្ទេរសំណុំរឿងទាំងឡាយណាដែលមិនត្រូវទៅនឹងលក្ខណៈវិនិច្ឆ័យនេះជូនទៅយុត្តាធិការជាតិ[128] ។ នៅក្នុងការវាយតម្លៃថាតើបុគ្គលណាមួយជា មេដឹកនាំជាន់ខ្ពស់ដែលបានទទួលខុសត្រូវខ្ពស់បំផុត ក្រុមចៅក្រមបញ្ជូនសំណុំរឿងនៃតុលាការ ICTY (the ICTY Referral Bench) បានពិចារណា៖ ទី១) ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់, និងទី២) កំរិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ[129] ។

៥៤. នៅក្នុងការវាយតម្លៃពីកំរិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ក្រុមចៅក្រមបញ្ជូនសំណុំរឿងនៃតុលាការ ICTY បានសន្និដ្ឋានថាប្រភេទ "មេដឹកនាំជាន់ខ្ពស់បំផុត" មិនកំរិតត្រឹមតែបុគ្គលដែលជា "ស្ថាបនិក" នៃ "គោលនយោបាយទូទៅ" ដែលបង្កើតជាមូលដ្ឋាននៃឧក្រិដ្ឋកម្មដែលបានលើក

---

[126] ច្បាប់លក្ខន្តិកៈរបស់តុលាការ ICTY, មាត្រា ១ ។

[127] *សូមមើល* សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៥៣៤, ចុះថ្ងៃទី២៦ មីនា ២០០៤, ត្រង់កថាខណ្ឌទី ៥-៦, UN Doc. No. S/Res/1534 (2004) ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៥០៣, ចុះថ្ងៃទី២៨ សីហា ២០០៣, UN Doc. No. S/Res/1503 (2003) ។

[128] *សូមមើល* វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY, វិធាន១១*ស្ទួន* (រៀបរាប់ពីនីតិវិធីក្នុងការផ្ទេរសំណុំរឿងទៅតុលាការជាតិដែលមានសមត្ថកិច្ច) ។ វិធាន១១*ស្ទួន* យោងដល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៥៣៤ និងថ្លែងថា តុលាការ ICTY នឹងពិចារណាពី "ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់" និង "កំរិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ" នៅក្នុងការសម្រេចថាតើត្រូវផ្ទេរសំណុំរឿង ឬមួយយ៉ាងណា ។ *សូមមើល* ICTY, *រដ្ឋអាជ្ញា ទល់នឹង Dragomir Milosevic*, សំណុំរឿងលេខ IT-98-29/1-PT, សេចក្តីសម្រេចលើការផ្ទេរសំណុំរឿង ដោយអនុលោមតាមវិធាន១១*ស្ទួន*, ថ្ងៃទី៨ កក្កដា ២០០៥, កថាខណ្ឌទី ១-៣ (ដោយបានរៀបរាប់ពីនីតិវិធីក្នុងការផ្ទេរសំណុំរឿង) ("សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Milosevic") ។

[129] ICTY, *រដ្ឋអាជ្ញា ទល់នឹង Lukic*, សំណុំរឿងលេខ IT-98-32/1-PT, ថ្ងៃទី៥ មេសា ២០០៧, កថាខណ្ឌទី ២៦ ("សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Lukic") ។

00655379



ឡើងចោទប្រកាន់ប៉ុណ្ណោះទេ[130] ។ ផ្ទុយទៅវិញ ក្រុមចៅក្រមពិចារណាលើបុគ្គលនានាដែលដោយ អាស្រ័យនូវមុខតំណែង*តាមផ្លូវច្បាប់ (ជានីតិន័យ-de jure)* និង *តាមហេតុការណ៍ពិត (de facto-តាមព្រឹត្តន័យ)* និងមុខងារនៅក្នុងឋានានុក្រមដែលពាក់ព័ន្ធ ត្រូវបានលើកឡើងចោទប្រកាន់ថាបានប្រតិបត្តិនូវកំរិតបែបដូច្នេះនៃសិទ្ធិអំណាចនោះ ដែលវាជាការត្រឹមត្រូវមួយក្នុងការពិពណ៌នាពួកគេថាជា "ជាន់ខ្ពស់បំផុត" ជាជាង "ថ្នាក់កណ្តាល"[131] ។ កត្តាពាក់ព័ន្ធនានាដែលបានពិចារណានៅក្នុងការកំណត់ពីកំរិតនៃសិទ្ធិអំណាចនេះ មានរួមទាំង ភាពអចិន្ត្រៃយ៍នៃមុខតំណែងរបស់ជនជាប់ចោទ[132] វិសាលភាពនៃពេលវេលា[133] ឋានន្តរសក្តិនៃជនជាប់ចោទនៅក្នុងរចនាសម្ព័ន្ធនៃឋានុក្រម[134] សិទ្ធិអំណាចនៅក្នុងការចរចា ចុះហត្ថលេខា ឬអនុវត្តកិច្ចព្រមព្រៀងនានា[135] ការត្រួតពិនិត្យច្រកចូលក្នុងទឹកដី[136] ចំនួនអ្នកនៅក្រោមបង្គាប់[137] តួនាទីជាក់ស្តែងរបស់ជនជាប់ចោទនៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[138] និងថាតើ មានមេដឹកនាំជាន់ខ្ពស់ទាំងឡាយណាខ្លះដែលមានឋានន្តរសក្តិ ខ្ពស់ជាងជនជាប់ចោទត្រូវបានធ្វើការផ្តន្ទាទោសចំពោះតួនាទីរបស់ពួកគេ នៅក្នុងឧក្រិដ្ឋកម្មបែប ដូច្នោះដែរឬទេ[139] ។

---

[130] សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Milosevic, កថាខណ្ឌទី ២២ ។ សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Lukic, កថាខណ្ឌទី ២៨ ។

[131] សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Milosevic, កថាខណ្ឌទី ២២ ។ សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Lukic, កថាខណ្ឌទី ២៨ ។

[132] សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Milosevic, កថាខណ្ឌទី ២៣ ។

[133] សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Milosevic, កថាខណ្ឌទី ២៣ ។

[134] ICTY, *រដ្ឋអាជ្ញា ទល់នឹង Ademi*, សំណុំរឿងលេខ IT-04-78-PT, ថ្ងៃទី១៤ កញ្ញា ២០០៥, កថាខណ្ឌទី ២៩ ("សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Ademi") ។ ICTY, *រដ្ឋអាជ្ញា ទល់នឹង Kovacevic*, សំណុំរឿងលេខ IT-01-42/2-I, ថ្ងៃទី១៧ វិច្ឆិកា ២០០៦, កថាខណ្ឌទី ២០ ("សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Kovacevic") ។ សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Milosevic, កថាខណ្ឌទី ២៣ ។ សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Lukic, កថាខណ្ឌទី ២៨ ។

[135] សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Milosevic, កថាខណ្ឌទី ២៣ ។ សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Ademi, កថាខណ្ឌទី ២៩ ។

[136] សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Milosevic, កថាខណ្ឌទី ២៣ ។

[137] សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Milosevic, កថាខណ្ឌទី ២៣ ។

[138] សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Ademi, កថាខណ្ឌទី ២៩ ។ សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Lukic, កថាខណ្ឌទី ២៨ ។

[139] សេចក្តីសម្រេចផ្ទេរសំណុំរឿងរបស់ Kovacevic, កថាខណ្ឌទី ២០ ។

00655380



៥៥. ក្នុងការវាយតម្លៃអំពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋនានាដែលបានចោទប្រកាន់ អង្គចៅក្រមបញ្ជូនសំណុំរឿងនៃតុលាការ ICTY ពិនិត្យពិចារណាទៅលើកត្តានានាមួយចំនួនដែលរួមទាំង វិសាលភាពនៃពេលវេលា[140], វិសាលភាពនៃភូមិសាស្ត្រ[141], ចំនួនជនរងគ្រោះ[142], និងចំនួននៃព្រឹត្តិហេតុដែលបានកើតឡើងដាច់ដោយឡែកពីគ្នា ដែលជនជាប់ចោទត្រូវបានចោទប្រកាន់[143] ។

៥៦. ក្នុងការប្រើប្រាស់នូវកត្តាទាំងនេះ អង្គចៅក្រមបញ្ជូនសំណុំរឿងនៃតុលាការ ICTY បានធ្វើសេចក្តីសន្និដ្ឋានថា មេបញ្ជាការយោធាម្នាក់ដែលទទួលខុសត្រូវលើកងវរៈសេនាធំចំនួនដប់ និងបុគ្គលិកចំនួន ១៨.០០០នាក់ ដែលត្រូវរាយការណ៍ជូនថ្នាក់លើខាងយោធាដែលខ្ពស់ជាងគេបំផុត ហើយដែលត្រូវបានចោទប្រកាន់ថា បានបាញ់ផ្លោក់ និងកាត់ផ្តាច់ទីក្រុងសារ៉ាហ្សេវ៉ូ អស់រយៈពេលដប់ប្រាំខែ និងបានសម្លាប់ ព្រមទាំងធ្វើឱ្យរងរបួសប្រជាជនស៊ីវិលរាប់ពាន់នាក់ គឺមានលក្ខណៈសម្បត្តិជា "មេដឹកនាំជាន់ខ្ពស់បំផុតមួយរូបក្នុងចំណោមមេដឹកនាំនានា ដែលទទួលខុសត្រូវខ្ពស់បំផុត"[144] ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថាមេដឹកនាំកំពូល នៃយោធាប្រតិព័ទ្ធមួយរូបដែលត្រូវបានចោទប្រកាន់ថា បានសម្របសម្រួលឱ្យមានព្រឹត្តិហេតុសម្លាប់

---

[140] តុលាការ ICTY, *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Jankovic*, សំណុំរឿងលេខ IT-96-23/2-AR11bis.2, ចុះថ្ងៃទី១៥ វិច្ឆិកា ២០០៥, កថាខណ្ឌទី២២ ("សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ *Jankovic* ")។ តុលាការ ICTY, *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Todovic*, សំណុំរឿងលេខ IT-97-25/1-AR11bis.1, IT-97-25/1-AR11bis.2, ចុះថ្ងៃទី៤ កញ្ញា ២០០៦, កថាខណ្ឌទី ១៣ (" សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ Todovic") ។ តុលាការ ICTY, *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Ljubicic*, សំណុំរឿងលេខ IT-00-41-PT, ចុះថ្ងៃទី១២ មេសា ២០០៦, កថាខណ្ឌទី ១៨ ("សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ Ljubicic")។ សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ Ademi, កថាខណ្ឌទី ២៨ ។ សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ Kovacevic, កថាខណ្ឌទី២០។ សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ Lukic, កថាខណ្ឌទី២៧។

[141] សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ *Jankovic* , កថាខណ្ឌទី ២២។ សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ Kovacevic, កថាខណ្ឌទី ២០។ សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ Lukic , កថាខណ្ឌទី ២៧។

[142] ចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ *Jankovic* , កថាខណ្ឌទី ២២។ សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ Kovacevic, កថាខណ្ឌទី២០។ សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ Lukic , កថាខណ្ឌទី ២៧។

[143] សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ Lukic , កថាខណ្ឌទី ២៧។

[144] សេចក្តីសម្រេចបញ្ជូនសំណុំរឿងរបស់ Milosevic, កថាខណ្ឌទី ៨-១០, ១៩, ២១, ២៤។

00655381



រង្គាលជាច្រើនលើកច្រើនសារ ដែលបណ្ដាលឱ្យមានការស្លាប់មនុស្សអស់ជាង១៥០នាក់ ត្រូវតែបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់បំផុត" មួយរូបនិងត្រូវតែឱ្យតុលាការធ្វើការជំនុំជម្រះក្ដី[145]។

៥៧. ជនទាំងឡាយដែលមានកំរិតលំដាប់ថ្នាក់ (level seniority) និងការទទួលខុសត្រូវ ដែលត្រូវបានកំណត់ថាជាជាន់ទាប និងដែលសមស្របដើម្បីឱ្យតុលាការ ICTY ធ្វើការបញ្ជូនសំណុំរឿងទៅឱ្យយុត្តាធិការក្នុងស្រុកវិញ រួមមាន៖ មេដឹកនាំនៃយោធាប្រតិព័ទ្ធ និងជាមេបញ្ជាការរងនៃតម្រួតយោធាមួយរូបដែលសិទ្ធិអំណាចរបស់ខ្លួនត្រូវបានកំរិតត្រឹមតែជា "ថ្នាក់មូលដ្ឋាន" (ទីក្រុងហ្វូកា)[146] , ជំនួយការអ្នកគ្រប់គ្រងពន្ធនាគារម្នាក់ ការចោទប្រកាន់របស់គាត់ពីឧក្រិដ្ឋកម្មផ្សេងៗត្រូវបានកំរិតដោយជាក់លាក់ត្រឹមតែក្នុងភូមិភាគមួយ[147] , មេបញ្ជាការកងពលតូចម្នាក់ និងជាមេបញ្ជាការស្ដីទីនៃយោធាស្រុក ត្រូវបានចោទប្រកាន់ពីបទធ្វើឱ្យប្រជាជន៣៨នាក់ស្លាប់ នៅក្នុងអម្លុងពេលនៃកិច្ចប្រតិបត្តិការយោធាតែមួយលើកគត់ប៉ុណ្ណោះ[148] , និងមេបញ្ជាការកងវរៈសេនាតូចម្នាក់ត្រូវបានចោទប្រកាន់ពីបទចូលរួមនៅក្នុងយុទ្ធនាការយោធាមួយ ដែលមានរយៈពេលមួយខែក្នុងការបាញ់ផ្លោងដាក់ទីក្រុង Dubrownik ដែលធ្វើឱ្យរងរបួស និងស្លាប់ប្រជាជនចំនួនប្រាំនាក់[149] ។

៥៨. លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL") គ្រាន់តែយោងសំដៅទៅលើជនទាំងឡាយណាដែលមាន"ការទទួលខុសត្រូវខ្ពស់បំផុត(Greatest responsibility)" ប៉ុណ្ណោះ[150]

---

[145] តុលាការ ICTY, *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង* Lukic, សំណុំរឿងលេខ IT-98-32/1-AR11bis.1, 11 July 2007, កថាខណ្ឌទី ២១, ២២, ២៥ [ដែលកែប្រែសេចក្ដីសម្រេចរបស់ អង្គចៅក្រមបញ្ជូនសំណុំរឿង]។

[146] សេចក្ដីសម្រេចបញ្ជូនសំណុំរឿងរបស់ *Jankovic* , កថាខណ្ឌទី ៤, ១៩-២២។

[147] សេចក្ដីសម្រេចបញ្ជូនសំណុំរឿងរបស់ Todorovic , កថាខណ្ឌទី ១៣, ១៦, ២១-២២, ២៥។

[148] សេចក្ដីសម្រេចបញ្ជូនសំណុំរឿងរបស់ Ademi, កថាខណ្ឌទី ១៥-១៨, ២៨-៣១។

[149] សេចក្ដីសម្រេចបញ្ជូនសំណុំរឿងរបស់ Kovacevic, កថាខណ្ឌទី ១២-១៣,២០។

[150] មាត្រា១នៃលក្ខន្តិកៈរបស់តុលាការ ពិសេសសំរាប់ប្រទេសសៀរ៉ាឡេអូន (ថ្ងៃទី១៦ មករា ២០០២) ដែលមានខ្លឹមសារថា៖ "តុលាការពិសេសសំរាប់ប្រទេសសៀរ៉ាឡេអូន ..... ត្រូវមានអំណាចក្នុងការកាត់ទោសជនទាំងឡាយដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភលើច្បាប់មនុស្សធម៌អន្តរជាតិ" ដែលបានប្រព្រឹត្តនៅក្នុងប្រទេសសៀរ៉ាឡេអូន ។

ដែលពាក្យពេជន៍នេះ គឺមានគោលបំណងចង់ឲ្យមានការកំរិត និយមន័យឲ្យ បានកាន់ តែចង្អៀត ជាង "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ថែមទៀត[151]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ SCSL បានធ្វើសេចក្តីសន្និដ្ឋានថា "ជនដែលមានការទទួលខុសត្រូវខ្ពស់បំផុត" គឺបានរាប់បញ្ចូលទាំង "លំដាប់នៃមនុស្សដែលរាប់ចាប់តាំងពីមេដឹកនាំ នានាខាងយោធា និងនយោបាយចុះមកក្រោមរហូតដល់ជនដែលមានវ័យក្មេងអាយុត្រឹម១៥ឆ្នាំ"[152]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃ តុលាការ SCSL ជាបន្ទាប់មកទៀត បានធ្វើសេចក្តីសន្និដ្ឋានថា ប្រយោគ "ការទទួលខុសត្រូវខ្ពស់បំផុត" គឺមិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការដែលអាចឲ្យពឹងផ្អែកលើ ដើម្បីធ្វើការពិនិត្យឡើងវិញ ឬប្រឆាំងជំទាស់ចំពោះការសម្រេចចិត្តរបស់រដ្ឋអាជ្ញា ក្នុងការធ្វើបទចោទប្រកាន់ប្រឆាំងនឹងជនដោយឡែកណាម្នាក់នោះឡើយ[153]។

៥៩. នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេត (JIs) បានសំរេចថា ខៀវ សំផន និងជនជាប់ចោទដទៃទៀត គឺសុទ្ធតែជា "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងអម្លុងពេលនៃយុត្តាធិការពេលវេលារបស់ អវតក ព្រោះដោយសារតែសិទ្ធអំណាចតាមឋានានុក្រម *ជាក់ស្តែង* និង *តាមផ្លូវច្បាប់* របស់ពួកគាត់ "[154]។ សហចៅក្រមស៊ើបអង្កេត ក៏បានសន្និដ្ឋាន

---

[151] SCSL, អង្គជំនុំជម្រះសាលាដំបូង II, *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Brima និងគូកន*, សំណុំរឿងលេខ SCSL-04-16-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីដែលស្នើសុំឲ្យលើកលែងការចោទប្រកាន់អនុលោមតាមវិធាន៩៨ , ចុះថ្ងៃទី៣១ មីនា ២០០៦, កថាខណ្ឌទី៣២ (សេចក្តីសម្រេចអនុលោមតាមវិធាន៩៨ ករណី Brima)។ SCSL, អង្គជំនុំជម្រះសាលាដំបូង II, *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Brima និងគូកន*, សំណុំរឿងលេខ SCSL-04-16-T, សាលក្រម, ចុះថ្ងៃទី២០ មិថុនា ២០០៧, កថាខណ្ឌទី៦៥១ (សាលក្រមជំនុំជម្រះក្តីករណី Brima)។

[152] សាលក្រមជំនុំជម្រះក្តីករណី Brima, កថាខណ្ឌទី៦៥៨ -៦៥៩។ សូមអានផងដែរ សេចក្តីសម្រេចអនុលោមតាមវិធាន៩៨លើករណី Brima, កថាខណ្ឌទី៣៤, ៣៦ -៣៧។ អង្គជំនុំជម្រះសាលាដំបូង II ក៏បានបញ្ជាក់ផងដែរថា យុត្តាធិការរបស់តុលាការទៅលើជនជាប់ចោទមិនមានផលប៉ះពាល់នោះទេ ទោះបីបើសិនជាភស្តុតាងអំពីគុណបន្ថែមទៀតដែលមានការទទួលខុសត្រូវខ្ពស់បំផុតដែរក៏ដោយ។ សេចក្តីសម្រេចអនុលោមតាមវិធាន៩៨ ករណី Brima, កថាខណ្ឌទី៣៩។

[153] SCSL,, អង្គជំនុំជម្រះសាលាដំបូង, *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Brima និងគូកន*, សំណុំរឿងលេខ SCSL-04-16-T, សាលក្រម , ចុះថ្ងៃទី២២ កុម្ភៈ ២០០៨, កថាខណ្ឌទី២៨០-២៨៤។

[154] ដីកាដំណោះស្រាយ កថាខណ្ឌទី១៣២៧។

ផងដែរថា ជនជាប់ចោទម្នាក់ៗក្នុងចំណោមជនជាប់ចោទទាំងនេះ គឺត្រូវបានចាត់ចូលនៅក្នុងជំពូកនៃ "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត" ដោយផ្អែកលើមូលដ្ឋាន "ការចូលរួមជាឯកត្តជនដោយផ្ទាល់របស់ពួកគាត់នៅក្នុងការអនុវត្តនូវគោលបំណងរួមរបស់ បកក តាមរយៈមធ្យោបាយឧក្រិដ្ឋផ្សេងៗ"[155] ។ការរកឃើញជាក់លាក់ខាងអង្គហេតុដែលគាំទ្រចំពោះការសម្រេចថា ខៀវ សំផន គឺជាមេដឹកនាំជាន់ខ្ពស់មួយរូប និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះ គឺមានចែងដូចខាងក្រោមនេះ៖

៦០. ខៀវ សំផន បានក្លាយជា បេក្ខជនសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សនៃ បកក មួយរូប នៅក្នុងឆ្នាំ១៩៧១ និងជាសមាជិកពេញសិទ្ធិក្នុងឆ្នាំ១៩៧៦ និងបានកាន់កាប់តំណែងនេះនៅក្នុងទូទាំងអម្លុងពេលបន្តពីនោះមកនៃ របបកម្ពុជាប្រជាធិបតេយ្យ[156]។ គាត់បានចូលរួមជាទៀងទាត់នៅក្នុងអង្គប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំថ្នាក់ខ្ពស់ដទៃទៀតនៃ បកក ហើយដែលត្រូវបានសហព្រះរាជអាជ្ញាចោទប្រកាន់ថា គាត់ធ្លាប់ធ្វើជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍តាមព្រឹត្តិន័យ[157] ។ ក្នុងនាមជាប្រធាននៃគណៈប្រធានរដ្ឋ គាត់គឺជាប្រមុខរដ្ឋ ចាប់តាំងពីខែមេសាឆ្នាំ១៩៧៦រហូតដល់ ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[158]។ គាត់ គឺជាកម្មាភិបាលដឹកនាំម្នាក់នៅក្នុងមន្ទីរនយោបាយ៨៧០[159] និងដែលទទួលបន្ទុកខាងកិច្ចការពាណិជ្ជកម្ម ដូចជាការបែងចែកទំនិញនៅក្នុងទូទាំងប្រទេសជាដើម[160] ។ គាត់តែងតែថ្លែងសន្ទរកថា និងដឹកនាំវគ្គអប់រំរៀនសូត្រខាងនយោបាយនានាដើម្បីផ្សព្វផ្សាយពីគោលនយោបាយរបស់ បកក ដែលក្នុងនោះ

---

[155] ដីកាដំណោះស្រាយ កថាខណ្ឌទី១៣២៨។

[156] ដីកាដំណោះស្រាយ, កថាខណ្ឌទី១១៣១។

[157] ដីកាដំណោះស្រាយ, កថាខណ្ឌទី១១៣២-១១៣៤, ១១៥១-១១៥២ ។ ដីកាសន្និដ្ឋានស្ដាពរអនុលោមតាមវិធាន៦៦ នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា, ចុះថ្ងៃទី១៦ សីហា ២០១០, ឯកសារលេខ D390, កថាខណ្ឌទី ១០៦៥-១០៧១ ។

[158] ដីកាដំណោះស្រាយ, កថាខណ្ឌទី១១៣៥-១១៣៨។

[159] ដីកាដំណោះស្រាយ, កថាខណ្ឌទី១១៣៩-១១៤១។

[160] ដីកាដំណោះស្រាយ, កថាខណ្ឌទី១១៤២-១១៤៤។

រួមមានគោលនយោបាយទាក់ទងនឹងការកំណត់អត្តសញ្ញាណ និងការសម្លាប់ពួកអ្នកដែលគេយល់ថាជាខ្មាំង[161]។ គាត់ត្រូវបានរកឃើញថាបានចូលរួមដោយខ្លួនគាត់ផ្ទាល់នៅក្នុងការអភិវឌ្ឍន៍ និងការអនុវត្តនូវគោលនយោបាយដ៏ឧក្រិដ្ឋនានារបស់ បកក ដែលក្នុងនោះរួមមាន៖ ការជម្លៀសប្រជាជនចេញដោយបង្ខំ[162] ការធ្វើឱ្យប្រជាជនកម្ពុជាក្លាយទៅជាទាសករនៅតាមបណ្តាសហករណ៍ និងការដ្ឋាននានា[163] ការចាប់ខ្លួន ឃុំខ្លួន និងសម្លាប់ពួកអ្នកដែលគេចោទថាជាខ្មាំងរបស់បក្សនៅតាមមណ្ឌលអប់រំកែប្រែ និងមន្ទីរសន្តិសុខនានា[164] ការផ្តោតមុខសញ្ញាសំដៅលើពួកមន្ត្រីរដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរ និងក្រុមពុទ្ធសាសនិកជន ជនជាតិចាម និងជនជាតិវៀតណាម[165] ហើយនិងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[166]។ ឧក្រិដ្ឋកម្មដែល ខៀវ សំផន ត្រូវបានចោទប្រកាន់ ជាប្រភេទឧក្រិដ្ឋកម្មដែលសុទ្ធតែមានលក្ខណៈធ្ងន់ធ្ងរបំផុត ដែលមានផលប៉ះពាល់ទៅដល់ជនរងគ្រោះចំនួនរាប់សែននាក់ ក្នុងទូទាំងតំបន់ភូមិសាស្ត្រនៃប្រទេសទាំងមូលក្នុងទូទាំងអម្លុងពេលនៃយុត្តាធិការពេលវេលារបស់ អវតក[167]។

[161] ដីកាដំណោះស្រាយ, កថាខណ្ឌទី១១៤៨-១១៥០។

[162] ដីកាដំណោះស្រាយ, កថាខណ្ឌទី១១៥៣-១១៦៣។

[163] ដីកាដំណោះស្រាយ, កថាខណ្ឌទី១១៦៤-១១៧១។

[164] ដីកាដំណោះស្រាយ, កថាខណ្ឌទី១១៧២-១១៩០។

[165] ដីកាដំណោះស្រាយ, កថាខណ្ឌទី១១៥៧-១១៥៨, ១១៩១-១១៩៨។

[166] ដីកាដំណោះស្រាយ, កថាខណ្ឌទី១១៩៩។

[167] ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥៨ (ការរកឃើញដែលថា គោលនយោបាយដ៏ឧក្រិដ្ឋរបស់ បកក គឺបានចូលជាធរមាននៅក្នុងទូទាំងអម្លុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ដែលនៅក្នុងពេលនោះគោលនយោបាយ "មានការវិវឌ្ឍន៍ និងកើនឡើងនូវកំរិត និងសន្ទុះខ្លាំងឡើង " ហើយបានប្រែក្លាយទូទាំងប្រទេសទាំងមូលទៅជា "គុកឥតជញ្ជាំង"), កថាខណ្ឌទី១៧៨ (ការរកឃើញថា មានមន្ទីរសន្តិសុខចំនួនពីររយកន្លែងត្រូវបានបង្កើតឡើង ដែលមានទីតាំងស្ថិតនៅក្នុងគ្រប់ភូមិភាគទាំងអស់នៅក្នុងទូទាំងប្រទេសកម្ពុជា និងនៅតាមរចនាសម្ព័ន្ធរដ្ឋបាលគ្រប់ជាន់ថ្នាក់ទាំងអស់របស់ បកក ), កថាខណ្ឌទី១៣៦០ ( ការដែលរកឃើញថា ប្រព័ន្ធដែលអនុវត្តដោយ បកក "ជាលទ្ធផលគឺបណ្តាលឱ្យមានជនរងគ្រោះចំនួនរាប់លាននាក់, ដែលរួមមាន មនុស្សស្លាប់ពី១លាន៧សែន ទៅ២,២លាននាក់ , ដែលក្នុងនោះមានប្រមាណជា ៨សែននាក់ដោយសារអំពើហឹង្សា"), កថាខណ្ឌទី១៦១៣ (ដែលចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញានៃទីក្រុងហ្សឺណែវ និងរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦)។

៦១. សហព្រះរាជអាជ្ញា សូមធ្វើការកត់សំគាល់ថា ខៀវ សំផន មិនបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសំរេចអំពីយុត្តាធិការបុគ្គលរបស់ ដីកាដំណោះស្រាយទេ។ លើសពីនេះ សេចក្តីសំរេចអំពីថាតើជនជាប់ចោទជាមេដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុតដែរឬក៏អត់នោះ គឺតម្រូវឱ្យតុលាការពិនិត្យមើលភស្តុតាងឡើងវិញ និងធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុ។ ក្នុងករណីនេះ ខៀវ សំផន បានទទួលសារភាពថាគាត់ធ្លាប់ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស បកក និងថាគាត់ធ្លាប់បានចូលរួមជាទៀងទាត់នៅក្នុងអង្គប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ គ្រាន់តែអង្គហេតុទាំងនេះតែប៉ុណ្ណោះ គឺគ្រប់គ្រាន់សម្រាប់គាំទ្រចំពោះសេចក្តីសន្និដ្ឋានដែលថា គាត់គឺជាមេដឹកនាំជាន់ខ្ពស់ម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការរួចទៅហើយ។ រហូតមកទល់ពេលដែលមានអង្គហេតុបន្ថែមដែលកំពុងតែតវ៉ាជំទាស់ដែលថាភាគីនានាមានបំណងចង់ឱ្យពិនិត្យពិចារណាទៀតនោះ អង្គជំនុំជម្រះសាលាដំបូងនឹងអាចមានលទ្ធភាពធ្វើដូចនេះបាន តែក្រោយពីបានស្តាប់ភស្តុតាងក្នុងសវនាការរួចហើយតែប៉ុណ្ណោះ[168]។ វិធាន ៨៩.៣ នៃវិធានផ្ទៃក្នុងបានចែងយ៉ាងច្បាស់ពីការអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង ពន្យារពេលក្នុងការធ្វើសេចក្តីសំរេចលើអញ្ញត្រកម្មបឋម រហូតទល់ពេលចេញសាលក្រមលើអង្គសេចក្តី។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ភស្តុតាងដែលមានស្រាប់នៅក្នុងសំណុំរឿងនៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីនេះ គឺជាការបង្ហាញភស្តុតាងយ៉ាងច្បាស់ ដោយផ្អែកលើមូលដ្ឋាន

---

[168] តុលាការអន្តរជាតិនានាបានច្រានចោលនូវ ញត្តិស្នើសុំទាក់ទងនឹងយុត្តាធិការនៅមុនពេលសវនាការ និងបណ្តឹងឧទ្ធរណ៍នានាដែលពាក់ព័ន្ធអំពីបញ្ហាអង្គហេតុដែលទីបំផុតត្រូវតែដោះស្រាយនៅក្នុងដំណាក់កាលនៃសវនាការជំនុំជម្រះក្តី។ តុលាការ ICTY, *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Krajišnik,*សេចក្តីសម្រេចលើញត្តិជំទាស់អំពីយុត្តាធិការ, សំណុំរឿងលេខ IT-00-39, ចុះថ្ងៃទី ២២កញ្ញា ២០០០, កថាខណ្ឌទី២៥-២៦។ ។ តុលាការ ICTY, *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Hadžihansanović,*សេចក្តីសម្រេចលើញត្តិជំទាស់រួមអំពីយុត្តាធិការ, សំណុំរឿងលេខ IT-01-47-PT , ចុះថ្ងៃទី១២ វិច្ឆិកា ២០០២, កថាខណ្ឌទី២៣, ២០២។ ICTY Appeals Chamber, *Prosecutor v. Brđanin*, Decision on Interlocutory Appeal from Decision on Motion to Dismiss Indictment Filed under Rule 72, IT-99-36-A, 16 November 1999។ តុលាការ ICTY, *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Kordić and Čerkez*, សេចក្តីសម្រេចលើញត្តិរួមរបស់មេធាវីការពារក្តីដែលច្រានចោលនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែរួចដោយសារគ្មានយុត្តាធិការ ដោយផ្អែកលើមូលដ្ឋាននៃយុត្តាធិការដែលវិសាលភាពមានការកំរិតកំណត់ នៃមាត្រា២និង៣, សំណុំរឿងលេខ IT-95-14-2, ចុះថ្ងៃទី២ មីនា ១៩៩៩, កថាខណ្ឌទី១៤-១៦។ តុលាការ ICTY, *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Milutinović*, ,សេចក្តីសម្រេចលើញត្តិរបស់ Ojdanic ដែលតវ៉ាជំទាស់អំពីយុត្តាធិការ: ការចូលរួមប្រព្រឹត្តដោយប្រយោល, សំណុំរឿងលេខ IT-05-87-PT, ចុះថ្ងៃទី២២ មីនា ២០០៦, កថាខណ្ឌទី២៣ ។

*ការមើលមួយក្រឡេកភ្លែកដំបូង* ថា ខៀវ សំផន គឺជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យផង និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មផ្សេងៗផង ។

## ញ. ភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ

៦២. តាមរយៈការដាក់បញ្ចូលគ្នានៃអញ្ញត្រកម្មរបស់គាត់ នួន ជា ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចេញដីកាលើកលែងការចោទប្រកាន់ ឬ ផ្អាកដំណើរការនីតិវិធី ដោយមានមូលដ្ឋានមួយដែលថា "ដោយមានកំហុសជាសារវ័ន្ត និងដោយស្តែងបង្ហាញនូវភាពមិនត្រឹមត្រូវក្នុង កិច្ចស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០២ លេចចេញជាលទ្ធផលនូវកំហុសនានាជាសត្យានុម័ត ដែលបណ្តាលឱ្យមានការខូចខាតមួយដែលមិនអាចជួសជុលបានដល់សិទ្ធិ នួន ជា នៅក្រោមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ដែលកំពុងនៅជាធរមាន"[169]។ កំហុសទាំងនេះត្រូវបានលើកឡើងចោទប្រកាន់ដោយមានរួមទាំង ការជ្រៀតជ្រែករបស់រដ្ឋាភិបាលដែលមិនអាចអនុញ្ញាតឱ្យបាន, ភាពលំអៀងរបស់ កសចស ប្រឆាំងនឹងជនជាប់ចោទ ក៏ដូចជាកង្វះតម្លាភាព និងការប្រើប្រាស់នូវវិធីសាស្ត្រមួយដែលអាចលើកឡើងជាសំណួរបានរបស់ កសចស ផងដែរ។ នួន ជា បានលើកសំអាងថា ជាលទ្ធផល នៃកំហុសដែលបានលើកឡើងចោទប្រកាន់ទាំងនេះ គាត់មិនអាចទទួលបាននូវការកាត់សេចក្តីមួយដ៏ត្រឹមត្រូវបាននោះទេ ហើយថាការធ្វើឱ្យករណីរឿងនេះមានសម្បទាឡើងវិញ "ក្នុងកំរិតមួយដែលមាន"ភាពត្រឹមត្រូវ"អាចទទួលយកបាននោះ បង្ហាញថាវាមិនអាចទៅរួចឡើយ"[170]។

### *បទដ្ឋានច្បាប់ជាធរមាន*

[169] អញ្ញត្រកម្មបឋមប្រមូលផ្តុំ, ថ្ងៃទី២៥ កុម្ភៈ ២០១១, E51/3, កថាខណ្ឌទី ៣ ("អញ្ញត្រកម្មបឋមរបស់ នួន ជា") ។

[170] អញ្ញត្រកម្មបឋមរបស់ នួន ជា, កថាខណ្ឌទី ៦២ ។

៦៣. អង្គជំនុំជម្រះសាលាដំបូងមានអំណាចមួយដែលមានជាប់ជាមួយមក ក្នុងការចេញដីការផ្អាកដំណើរការនីតិវិធីជាអចិន្ត្រៃយ៍កាលណាមានការបំពានមួយជាក់ស្តែង និងយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ជនចាប់ចោទ ត្រូវបានបង្កើតឡើង[171]។ ទោះជាយ៉ាងដូច្នេះក៏ដោយ ដោយសារចរិតលក្ខណៈលើកលែងនៃការបញ្ចប់ដំណើរការនីតិវិធីព្រហ្មទណ្ឌ ចំណុចចាប់ផ្តើមដែលត្រូវតែមានចំពោះទម្រង់នៃដំណោះស្រាយមួយនេះ គឺវានៅខ្ពស់ណាស់។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC បានសម្រេចថា៖

> "ការផ្អាកដំណើរការនីតិវិធី គឺជាដំណោះស្រាយមួយដ៏គំហុក ។ វានាំដំណើរការនីតិវិធីទៅរកការឈប់ទ្រឹង, ធ្វើឱ្យមានការខកខានជាសក្តានុពលដល់គោលដៅនៃការកាត់សេចក្តី គឺផ្តល់នូវយុត្តិធម៌ក្នុងករណីរឿងជាក់លាក់ណាមួយ ក៏ដូចជាមានការប៉ះពាល់ដល់គោលបំណងទូលំទូលាយនានាដែលមានចែងយ៉ាងច្បាស់នៅក្នុងបុព្វកថានៃច្បាប់លក្ខន្តិកៈ ទីក្រុងរ៉ូម វាគឺជាដំណោះស្រាយពិសេសមួយ"[172]។

៦៤. ដូចដែលបានថ្លែងដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC ចំណុចចាប់ផ្តើមដែលនៅខ្ពស់ក្នុងការដាក់ឱ្យមានការផ្អាកដំណើរការនីតិវិធីនោះតម្រូវថាវា "មិនមានលទ្ធភាពនៅក្នុងការដាក់បញ្ចូលគ្នានូវធាតុផ្សំនានាដែលជាសមាសធាតុនៃការកាត់សេចក្តីដ៏ត្រឹមត្រូវមួយ"។ និយាយម្យ៉ាងវិញទៀតគឺ គេអាចផ្អាកដំណើរការនីតិវិធីបាន "កាលណាការរំលោភសិទ្ធិនានារបស់ ជនជាប់ចោទ

---

[171] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹង "ដីកាបដិសេធសំណើសុំមោឃភាព និងសំណើសុំផ្អាកដំណើរការនីតិវិធីដោយមានមូលដ្ឋានទៅលើការរំលោភលើនីតិវិធី ដែលដាក់ដោយ អៀង ធី រិទ្ធ" (D263/1 និង D264/1) ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩, ថ្ងៃទី១៩ កុម្ភៈ ២០១០, D264/2/2, កថាខណ្ឌទី ១៦ ។

[172] ICC, *រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dylio*, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទី I ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០ ដែលមានចំណងជើងថា "សេចក្តីសម្រេចលើបន្ទាន់របស់រដ្ឋអាជ្ញា ស្នើសុំឱ្យធ្វើការផ្លាស់ប្តូរពេលកំណត់ក្នុងការប្រកាសពីអត្តសញ្ញាណរបស់អន្តរការី ១៤៣ ឬដោយឆ្លាស់គ្នា សុំផ្អាកដំណើរការនីតិវិធី ដោយអាស្រ័យលើការប្រឹក្សាយោបល់បន្ថែមជាមួយនឹង VWU, ថ្ងៃទី៨ តុលា ឆ្នាំ២០១០, ICC-01/04-01/06 OA 18 ("សេចក្តីសម្រេចលើករណីរបស់ Lubanga ថ្ងៃទី៨ តុលា ២០១០"), កថាខណ្ឌទី ៥៥ ។

ជាការរំលោភដែលធ្វើឱ្យគាត់មិនអាចមានលទ្ធភាពធ្វើការការពារខ្លួនគាត់បាន" ហើយ "ដូច្នេះការកាត់សេចក្ដីដ៏យុត្តិធម៌មួយ គឺមិនអាចទៅរួចឡើយ តើនីតិវិធីអាចផ្អាកបានដែរឬទេ"[173] ។

៦៥. បទដ្ឋានដូចគ្នានេះ ត្រូវបាន តុលាការ*ពិសេស*នានាយកទៅអនុវត្ត។ នៅក្នុងសំណុំរឿងរបស់ *Barayawiza* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR បាន សម្រេចថា ដើម្បីអនុញ្ញាតឱ្យមានការផ្អាកដំណើរការនីតិវិធី ការរំលោភសិទ្ធិរបស់ជនជាប់ចោទត្រូវតែ "ជាក់ស្ដែងយ៉ាងខ្លាំង" ដែលថាបើបន្តដំណើរការនីតិវិធីទៀតនោះ នឹង"បំពារបំពានលើ" សេចក្ដីវិនិច្ឆ័យនៃយុត្តិធម៌របស់តុលាការ ហើយបើដូច្នេះ នឹងបង្ហាញពីការខូចខាតដល់សុចរិតភាពរបស់តុលាការ"[174]។ បទដ្ឋាននេះត្រូវបានធ្វើតាមដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីរបស់ *Nikolic*[175] ដែលសេចក្ដីសម្រេចរបស់ខ្លួនត្រូវបានគាំទ្រដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ដោយអង្គជំនុំជម្រះខាងក្រោយនេះបានបន្ថែមថា ការផ្អាកដំណើរការនីតិវិធីគឺជាដំណោះស្រាយមួយ ដែលត្រូវតែបានរក្សា

---

[173] ICC, *រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dylio*, សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dylio ប្រឆាំងនឹងសេចក្ដីសម្រេចលើការជំទាស់របស់មេធាវីការពារក្ដីពីយុត្តាធិការរបស់តុលាការ អនុលោមតាមមាត្រា១៩.២ នៃច្បាប់លក្ខន្តិកៈ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦, ថ្ងៃទី១៤ ធ្នូ ២០០៦, សំណុំរឿងលេខ ICC-01/04-01/06 (OA4) ("សេចក្ដីសម្រេចលើករណីរបស់ Lubanga ថ្ងៃទី១៤ ធ្នូ ២០០៦"), កថាខណ្ឌទី ៣៩ ។ សេចក្ដីសម្រេចលើករណីរបស់ Lubanga ថ្ងៃទី៨ តុលា ២០១០, កថាខណ្ឌទី ៥៥ ។ ICC, *រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dylio*, សេចក្ដីសម្រេចដែលលុបចេញខ្លះស្ដីពី "សំណើរបស់មេធាវីការពារក្ដីស្នើសុំផ្អាកដំណើរការនីតិវិធីជាអចិន្ត្រៃយ៍, ថ្ងៃទី៧ មីនា ២០១១, សំណុំរឿងលេខ ICC-01/04-01/06 ("សេចក្ដីសម្រេចលើករណីរបស់ Lubanga ថ្ងៃទី៧ មីនា ២០១១"), កថាខណ្ឌទី ១៦៥ ។

[174] ICTR, *រដ្ឋអាជ្ញា ទល់នឹង Barayawiza*, សាលក្រម, ថ្ងៃទី៣ ធ្នូ ១៩៩៩, សំណុំរឿងលេខ Case No. ICTR-97-19-AR72, កថាខណ្ឌទី ៧៤ និង ៧៧ ។

[175] ICTY, *រដ្ឋអាជ្ញា ទល់នឹង Nikolic*, សេចក្ដីសម្រេចលើញត្តិរបស់មេធាវីការពារក្ដីជំទាស់នឹងការអនុវត្តយុត្តាធិការដោយតុលាការ, ថ្ងៃទី៩ តុលា ២០០២, សំណុំរឿងលេខ IT-94-2-PT, កថាខណ្ឌទី ១១១ ។

ទុកសម្រាប់ករណី "ពិសេសៗ" ខ្លាំងមែនទែន[176]។ បទដ្ឋាននេះ ក៏ត្រូវបានអនុវត្តនៅក្នុងសេចក្ដីសម្រេចថ្មីៗនេះថែមទៀតរបស់តុលាការ ICTR ផងដែរ[177]។

៦៦. អបជ បានធ្វើតាមបទដ្ឋានអន្តរជាតិនេះនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ដោយបានបដិសេធសំណើរបស់ អៀង ធីរិទ្ធ ស្នើសុំផ្អាកដំណើរការនីតិវិធីនៅក្នុងករណីនេះ[178]។ អង្គជំនុំជម្រះបានសម្រេចថាការផ្អាកដំណើរការនីតិវិធី គឺជា "extreme measure" ដែលមិនគួរត្រូវបានអនុវត្តចំពោះតែ "an exceptional and very serious case of violations of rights of the accused, which cannot be rectified or [which] contravene the court's sense of justice"[179] ។ អង្គជំនុំជម្រះបានកត់សម្គាល់យ៉ាងត្រឹមត្រូវថា យុត្តិសាស្ត្រអន្តរជាតិ "មិនអនុញ្ញាតឲ្យមានទ្រឹស្ដីនៃការរំលោភបំពានលើនីតិវិធី ក្នុងការដាក់ពង្រាយនូវបទដ្ឋានមួយដែលទាបជាងនេះឡើយ"[180]។

៦៧. បន្ទុកភស្ដុតាងលើការសំណើសុំផ្អាកដំណើរការនីតិវិធី គឺឋិតនៅលើជនជាប់ចោទ[181] ហើយតុលាការត្រូវបានផ្ដល់នូវឆន្ទានុសិទ្ធិមួយចំនួននៅពេលដែលធ្វើការកំណត់ថា តើត្រូវទៅតាមតម្រូវការដែលថាឲ្យមានចំណុចចាប់ផ្ដើម "ដែលមានមូលដ្ឋាននៅលើការយល់ដឹងដល់ទីជម្រៅនូវនីតិវិធី

[176] ICTY, *រដ្ឋអាជ្ញា ទល់នឹង Nikolic*, សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្គំ ពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃការចាប់ខ្លួន, ថ្ងៃទី៥ មិថុនា ២០០៣, សំណុំរឿងលេខ IT-94-2-AR73, កថាខណ្ឌទី ៣០ ។

[177] ICTY, *រដ្ឋអាជ្ញា ទល់នឹង Karadzic*, សេចក្ដីសម្រេចញត្តិស្នើសុំបដិសេធការរំលោភលើនីតិវិធី, ថ្ងៃទី១២ ឧសភា ២០០៩, សំណុំរឿងលេខ IT-95-5/18-PT, ("សេចក្ដីសម្រេចលើករណីរបស់ Karadzic"), កថាខណ្ឌទី ១០-១១ ។ ICTY, *រដ្ឋអាជ្ញា ទល់នឹង Seselj*, សេចក្ដីសម្រេចលើសំណើផ្ទាល់មាត់របស់ជនជាប់ចោទពីការរំលោភលើនីតិវិធី, ថ្ងៃទី១០ កុម្ភៈ ២០១០, សំណុំរឿងលេខ IT-03-67-T, កថាខណ្ឌទី ២២ ។

[178] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើសុំផ្អាកដំណើរការនីតិវិធី ដោយមានមូលដ្ឋាននៅលើការរំលោភលើនីតិវិធី (D264/1), ថ្ងៃទី១០ សីហា ២០១០, D264/2/6, ("សេចក្ដីសម្រេចលើសំណើស្ដីពីការរំលោភលើនីតិវិធីរបស់ អៀង ធីរិទ្ធ") ។

[179] សេចក្ដីសម្រេចលើសំណើស្ដីពីការរំលោភលើនីតិវិធីរបស់ អៀង ធីរិទ្ធ, កថាខណ្ឌទី ២៨ ។

[180] សេចក្ដីសម្រេចលើសំណើស្ដីពីការរំលោភលើនីតិវិធីរបស់ អៀង ធីរិទ្ធ, កថាខណ្ឌទី ២៤ ។

[181] ICTR, *រដ្ឋអាជ្ញា ទល់នឹង Akayesu*, សាលដីកា, ថ្ងៃទី១ មិថុនា ២០០១, សំណុំរឿងលេខ ICTR-96-4-A ("សេចក្ដីសម្រេចលើករណីរបស់ Akayesu"), កថាខណ្ឌទី ៣៤០ ។

រហូតមកដល់ពេលនេះ” ហើយឬនៅ[182]។ សូម្បីតែបើមានអប្រក្រតីភាពណាមួយនៃដំណើរការនីតិវិធីត្រូវបានកំណត់អត្តសញ្ញាណ តុលាការត្រូវតែធានាថាដំណោះស្រាយដែលបានបង្គាប់នៅក្នុងចម្លើយតប គឺសមាមាត្រទៅនឹងការខូចខាតដែលបានរងទទួល[183]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងទី I នៃតុលាការ ICC បានសម្រេចនៅពេលថ្មីៗនេះថា “ដំណោះស្រាយដ៏គំហុក” នៃការបញ្ចប់[ផ្អាក] គឺត្រូវរក្សាទុកយ៉ាងតឹងរឹងសម្រាប់តែករណីរឿងទាំងឡាយណាដែលអនុញ្ញាតឱ្យមាន “the extreme and exceptional step of terminating the proceedings (as opposed to adopting some lesser remedy)”[184]។ ជាញឹកញាប់ ការវិភាគនេះនឹងនាំឆ្ពោះទៅរកសេចក្ដីសន្និដ្ឋានមួយដែលថាការផ្អាកដំណើរការនីតិវិធី គឺជាចម្លើយតបមួយដែលវិសមាមាត្រ[185]។

៦៨. ខណៈដែលទៅហួសពីវិសាលភាពនៃចម្លើយតបនេះ ដើម្បីដោះស្រាយដាច់ដោយឡែកពីគ្នារៀងៗខ្លួននៅមុនការដាក់ឯកសារដែលបានយោងដោយ នួន ជា ការឆ្លើយតបដោយសង្ខេបតទៅនេះបង្ហាញថា អញ្ញត្រកម្មរបស់គាត់គឺគិតគូរមិនបានល្អ និងត្រូវតែបានបដិសេធចោល។ បញ្ហានានាដែលបានលើកឡើងដោយជនជាប់ចោទ ឬមួយធ្លាប់ត្រូវបានវិនិច្ឆ័យរួចហើយ ឬមួយមិនត្រូវតាមបទដ្ឋានច្បាប់ដែលបានរៀបរាប់នៅខាងលើ។ នួន ជា បានដាក់ជាក្រុមនូវបណ្ដឹងទាំងឡាយរបស់គាត់ជាពីរក្រុមធំៗ៖ ការលើកឡើងចោទប្រកាន់ពីការជ្រៀតជ្រែកខាងផ្នែកនយោបាយ[186] និងបណ្ដឹងពាក់ព័ន្ធនឹងគុណភាពនៃការស៊ើបសួរ[187]។

---

[182] សេចក្ដីសម្រេចលើករណីរបស់ Lubanga ថ្ងៃទី៧ មីនា ២០១១, កថាខណ្ឌទី ១៦៧ ។

[183] សេចក្ដីសម្រេចលើករណីរបស់ Lubanga ថ្ងៃទី១៤ ធ្នូ ២០០៦, កថាខណ្ឌទី ៣០ ។

[184] សេចក្ដីសម្រេចលើករណីរបស់ Lubanga ថ្ងៃទី៧ មីនា ២០១១, កថាខណ្ឌទី ១៦៨ ។

[185] សេចក្ដីសម្រេចលើករណីរបស់ Karadzic, កថាខណ្ឌទី ១០-១១ ។ *សូមមើលផងដែរ* សេចក្ដីសម្រេចលើករណីរបស់ Akayesu, កថាខណ្ឌទី ៣៤០ ។

[186] អញ្ញត្រកម្មបឋមរបស់ នួន ជា, កថាខណ្ឌទី ៥-១៤ ។

[187] អញ្ញត្រកម្មបឋមរបស់ នួន ជា, កថាខណ្ឌទី ១៥-១៩ ។

00655391



## *ការលើកឡើងចោទប្រកាន់ពីការជ្រៀតជ្រែកខាងផ្នែកនយោបាយ*

៦៩. ***អំពើពុករលួយ៖*** នួន ជា អះអាងថា ដោយសារការលើកឡើងចោទប្រកាន់ដែលមិនទាន់បាន ដោះស្រាយពីអំពើពុករលួយក្នុងផ្នែករដ្ឋបាល អវតក នៅតែជាស្ថាប័នមួយដែលមានស្លាកស្នាមប្រឡាក់។ ទោះជាយ៉ាងដូច្នេះក៏ដោយ អង្គហេតុដែលបានលើកឡើងដោយ នួន ជា មិនគាំទ្រដល់ការ អះអាងរបស់គាត់ទេ ។ ក្នុងឆ្នាំ២០០៩ កសចស បានបដិសេធសំណើរបស់ នួន ជា ស្នើសុំឱ្យ ធ្វើការស៊ើបសួរលើការលើកឡើងចោទប្រកាន់ពីអំពើពុករលួយក្នុងផ្នែករដ្ឋបាល[188]។ ខណៈដែល ធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះថាមិនអាចទទួលយកបាន អង្គបុរេ ជំនុំជម្រះក៏បានសម្រេចផងដែរថា ការលើកឡើងចោទប្រកាន់នេះគឺមិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្ហាញថាមានការជ្រៀតជ្រែកនៅក្នុងដំណើរការរបស់តុលាការទេ[189] ។ មិនមានអង្គហេតុថ្មី ស្តីពីភាពពាក់ព័ន្ធណាមួយត្រូវបានដាក់ជូននោះទេ[190]។

៧០. ***ការជ្រៀតជ្រែករបស់រដ្ឋាភិបាលដែលបានលើកឡើងចោទប្រកាន់នៅក្នុងសំណុំរឿងលេខ០០២៖*** នួន ជា បានយោងទៅដល់ការបដិសេធរបស់រដ្ឋមន្ត្រីព្រះបរមរាជវាំងដែលមិនទទួលការប្រាស្រ័យទាក់ ទងមួយពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្វាយទៅសម្តេចព្រះរាជបិតា នរោត្តមសីហនុ ស្នើសុំ ឱ្យធ្វើជាសាក្សី ក៏ដូចជាសកម្មភាពនានារបស់មន្ត្រីផ្លូវការជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ទាក់ទង

---

[188] សាលដីកាលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី៣ មេសា ២០០៩, D158/5 ។

[189] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទី១១ របស់ជនត្រូវចោទ, ថ្ងៃទី១៨ សីហា ២០០៩, D158/5/1/15, កថាខណ្ឌទី ៥០ ។

[190] តាមអង្គហេតុពិត ចាប់តាំងពីមានសេចក្តីសម្រេចទាំងនេះមក អសប និង រាជរដ្ឋាភិបាលកម្ពុជា បានឯកភាពគ្នាលើវិធានការនានាដើម្បីធានានូវពាក្យបណ្តឹងទាំងឡាយ រួមទាំងការលើកឡើងចោទប្រកាន់ពីអំពើពុករលួយខាងផ្នែករដ្ឋបាល អាចនឹងត្រូវបានស៊ើបអង្កេតដោយអង្គភាពមួយដែលឯករាជ ។ *សូមមើល* សេចក្តីថ្លែងការណ៍រួមស្តីពីការបង្កើតទីប្រឹក្សាឯករាជនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ថ្ងៃទី១២ សីហា ២០០៩, អាចរកបានតាម៖ http://www.un.org/News/Press/docs/2009/l3146.doc.htm ។ របាយការណ៍របស់អង្គជំនុំជម្រះ, ខែធ្នូ ឆ្នាំ២០០៩, អាចរកបានតាម៖ http://www.eccc.gov.kh/english/cabinet/fileUpload/148/The_Court_Report_[Dec_2009]_FINAL.pdf.

00655392



នឹងសាក្សីដែលបានស្នើសុំផងទៀត។ សំណើរបស់ នួន ជា ស្នើសុំឱ្យធ្វើការស៊ើបសួរលើបញ្ហាទាំងនេះ គឺជាប្រធានបទនៃដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ទាក់ទងទៅនឹងការស្នើសុំឱ្យស្តាប់ចម្លើយសម្តេចព្រះរាជបិតា អង្គបុរេជំនុំជម្រះបានសម្រេចថា ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការចាត់វិធានការបន្តទៀតនោះ គឺសមហេតុសមផល ហើយអបជ បានសម្រេចបដិសេធបណ្តឹងឧទ្ធរណ៍នេះចោល[191]។ ស្តីពីបញ្ហាសកម្មភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងទៅនឹងសាក្សីដែលនៅសេសសល់នានា អង្គជំនុំជម្រះនេះមិនអាចឈានដល់សេចក្តីសម្រេចមួយជាវិជ្ជមានបាននោះទេ ហើយការបដិសេធរបស់ កសចស ក្នុងការចេញដីកាឱ្យធ្វើការស៊ើបសួរនៅមិនមានការផ្លាស់ប្តូរនៅឡើយ[192]។

៧១. សហព្រះរាជអាជ្ញា សូមកត់សំគាល់ថា ជនទាំងនេះ ត្រូវបានស្នើឡើងដើម្បីធ្វើជាសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយ នួន ជា[193]ហើយបញ្ហានេះមិនទាន់ត្រូវបានសំរេចនៅឡើយ។ នៅក្នុងកាលៈទេសៈទាំងនេះ មិនអាចឱ្យលើកឡើងដើម្បីតវ៉ាថា មានការរំលោភយ៉ាងធ្ងន់ធ្ងរឬយ៉ាងជាក់ស្តែងទៅលើសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌របស់ នួន ជា បានទេ នោះគឺជាការអនុញ្ញាតឱ្យមានវិធានការដែលហួសប្រមាណក្នុងការបញ្ឈប់នូវដំណើរការនីតិវិធី។ ផ្ទុយពីសេចក្តីសន្និដ្ឋានរបស់ នួន ជា[194] ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះមិនបានរកឃើញជាវិជ្ជមានណាមួយអំពីប្រការដែលថា "នួន ជាត្រូវបាន"ទប់ស្កាត់មិនឱ្យទទួលបាននូវអត្ថប្រយោជន៍ ដែលអាចនឹងត្រូវបានទទួល"" ដែលអាចលេចចេញមកពីសក្ខីកម្ម

[191] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី, ថ្ងៃទី៨ មិថុនា ២០១០, D314/2/7 ។

[192] ចៅក្រមអន្តរជាតិពីររូបបានព្រមព្រៀងជាមួយនឹង នួន ជា ថាសេចក្តីប្រកាសព័ត៌មានជាសាធារណៈ ធ្វើឡើងដោយអ្នកនាំពាក្យរដ្ឋាភិបាលម្នាក់បានអនុញ្ញាតឱ្យមានការស៊ើបអង្កេតមួយទៅលើថាតើរដ្ឋាភិបាលបានជ្រៀតជ្រែកទៅលើសាក្សីដែរឬទេ, ខណៈដែលចៅក្រមជាតិបីរូបមិនបានឯកភាពទៅនឹងការរកឃើញនេះទេ៖ សាលដីកាលើកទីពីរ លើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅ សាក្សី, ថ្ងៃទី៩ កញ្ញា ២០១០, D314/1/12 ។

[193] បញ្ជីឈ្មោះសាក្សី, អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំ, ចុះថ្ងៃទី១៥ កុម្ភៈ ឆ្នាំ២០១១, ឯកសារលេខ D9/4/4 ។

[194] អញ្ញត្រកម្មបឋមរបស់ នួន ជា, ត្រង់កថាខណ្ឌទី៥៧។

00655393



ទាំងឡាយដែលបានស្នើ[195]។ លើសពីនេះ ចម្លើយទាំងឡាយកន្លងមករបស់សាក្សីដែលបានស្នើសុំដែលនៅក្នុងសំណុំរឿងគឺជាចម្លើយដែលដាក់បន្ទុកហើយដែលមិនគាំទ្រចំពោះសេចក្ដីសន្និដ្ឋានដែលថាសក្ខីកម្មរបស់សាក្សីទាំងនេះមុខជានឹងមានអំណោយផលល្អដល់ នួន ជា នោះឡើយ។

៧២. ***ការដែលត្រូវបានចោទអំពីមានការជ្រៀតជ្រែករបស់រដ្ឋាភិបាលនៅក្នុងសំណុំរឿងលេខ ០០៣ និង០០៤។*** ក្នុងការគាំទ្រចំពោះអញ្ញត្រកម្មបឋមរបស់ខ្លួន នួន ជា បានលើកយោងទៅលើសេចក្ដីសំរេចនានារបស់លោកចៅក្រម យូ ប៊ុនឡេង ស្ដីពីកិច្ចស៊ើបសួរនៅក្នុងសំណុំរឿងលេខ ០០៣ និង០០៤។ នួន ជា ខ្លួនឯងទទួលស្គាល់ថា ពាក្យសុំរបស់ខ្លួនដែលលេចចេញមកពីការចោទប្រកាន់ទាំងនេះ ត្រូវបានបដិសេធចោលហើយ ព្រោះដោយសារមិនមានការចង្អុលបង្ហាញភស្តុតាងអំពីអង្គហេតុ៖ ១) អង្គបុរេជំនុំជម្រះបានបដិសេធពាក្យសុំមួយដែលសុំប្ដឹងជំទាស់ចៅក្រម យូ ប៊ុនឡេង ដែលរកឃើញថាការចោទប្រកាន់នេះមិនបានធ្វើឱ្យឃើញពីភាពជាក់ស្ដែងដែលថាចៅក្រមរូបនេះបានធ្វើសកម្មភាពដោយមិនមានឯករាជ្យភាព ឬដោយភាពលំអៀងនោះឡើយ[196]។ និង (២) បណ្ដឹងឧទ្ធរណ៍របស់ នួន ជា ដែលប្រឆាំងនឹងការបដិសេធរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមិនព្រមផ្ដួចផ្ដើមគំនិតក្នុងការបើកកិច្ចស៊ើបសួរមួយទៅលើសកម្មភាពនានារបស់លោកចៅក្រម យូ ប៊ុនឡេង ដែលត្រូវបានអង្គបុរេជំនុំជម្រះបដិសេធចោលផងដែរលើអង្គសេចក្ដី[197]។

*ការចោទអំពីមានកំហុសនៅក្នុងការស៊ើបសួរ*

[195] សេចក្ដីសម្រេចលើកទីពីរ លើលើបណ្ដឹងឧទ្ធរណ៍ របស់ នួន ជា និងអៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំឱ្យកោះហៅសាក្សីនានា, ចុះថ្ងៃទី៩ កញ្ញា ២០១១, ឯកសារលេខ D314/1/12, យោបល់របស់លោកចៅក្រម Catherine Marchie-Uhel និង Rowan Downing, ត្រង់កថាខណ្ឌទី១២ ។

[196] ដីកាសម្រេចលើពាក្យសុំប្ដឹងជំទាស់លោកចៅក្រម យូ ប៊ុនឡេង, ចុះថ្ងៃទី១០ កញ្ញា ២០១០, អបជ១០។

[197] សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំកិច្ចស៊ើបសួរលើកទី២របស់ នួន ជា(វិធាន៣៥ នៃវិធានផ្ទៃក្នុង) , ចុះថ្ងៃទី២ វិច្ឆិកា ២០១០, ឯកសារលេខ D384/5/2 ។

00655394



៧៣. ***អំពីកង្វះតម្លាភាព:*** នួន ជា ទាមទារថា កសចស "បានបដិសេធម្ដងហើយម្ដងទៀត"មិនព្រម ផ្ដល់ព័ត៌មានស្ដីពីវិធីសាស្ត្រ និងទិដ្ឋភាពផ្សេងៗទៀតនៃកិច្ចស៊ើបសួរ ដែលហេតុនេះគឺជាការដាក់ "របាំងដើម្បីបិទបាំងការសម្ងាត់"មួយ អំពីដំណើរការនីតិវិធី[198]។ ការទាមទារនេះ គឺជាការយល់ខុស។ នួន ជា បានចូលរួមនៅក្នុងសំណើសុំផ្ដល់ព័ត៌មានមួយ ដែលបានដាក់ដោយ អៀង សារី ដែលចំពោះសំណើនេះ កសចស បានផ្ដល់នូវចម្លើយតបយ៉ាងលំអិតមួយ[199]។ ដោយបណ្ដឹងឧទ្ធរណ៍នេះត្រូវបានដាក់នៅមុនពេលដែលចេញចម្លើយតបនេះ បញ្ហានេះក៏ត្រូវបានអង្គបុរេជំនុំជម្រះធ្វើការដោះស្រាយដោយផងដែរ។ អង្គបុរេជំនុំជម្រះ សម្រេចថា "សំណើដែលបានធ្វើឡើងនេះមិនមែនជាសំណើដែលស្ថិតនៅក្នុងសិទ្ធិដែលជនត្រូវចោទជាអ្នកត្រូវធ្វើនោះទេ"[200]។ ហេតុដូចនេះ នួន ជា មិនគ្រាន់តែបកស្រាយខុសអំពី ចម្លើយតបរបស់ កសចស ទៅនឹងសំណើរបស់គាត់ប៉ុណ្ណោះទេក៏ប៉ុន្តែគាត់ថែមទាំងខកខានមិនបានទទួលស្គាល់ថា ដូចដែលបានសម្រេចដោយអង្គបុរេជំនុំជម្រះជាដំបូងបង្អស់គឺសំណើរបស់គាត់គ្មានមូលដ្ឋានខាងអង្គច្បាប់។ សហព្រះរាជអាជ្ញា សូមធ្វើការកត់សំគាល់ជាបន្ថែមទៀតថា នួន ជា មានសិទ្ធិក្នុងការពិនិត្យមើលសំណុំរឿងរួចហើយនៅក្នុងទូទាំងអំឡុងពេលនៃកិច្ចស៊ើបសួរ ហើយនិងអាចមានលទ្ធភាពពិនិត្យមើលទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកនៅពេលដែលកំពុងតែប្រមូលទៀតផង។ អាស្រ័យហេតុនេះ គឺគ្មានទឡ្ហីករណ៍សមហេតុសមផលណាមួយដែលអាចត្រូវលើកឡើងថា មានការដាក់ "របាំងបិទបាំងការសម្ងាត់" ស្ដី ពីការស៊ើបសួរនោះឡើយ។

---

198 អញ្ញត្រកម្មបឋមរបស់ នួន ជា, កថាខណ្ឌទី១៦។

199 ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេត ទៅនឹង "សំណើសុំកិច្ចស៊ើបសួរ" ដែល ក្នុងចំណោមអ្វីៗជាច្រើនទៀត អំពីយុទ្ធសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងកិច្ចស៊ើបសួរ, ចុះថ្ងៃទី១១ ធ្នូ ២០០៩, ឯកសារលេខ D171/5។

200 សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធ តាមការសន្មត់តាមផ្លូវច្បាប់ចំពោះសំណើលើកទីបីរបស់ អៀង សារី ដែលស្នើសុំកិច្ចស៊ើបសួរ, ចុះថ្ងៃទី២២ ធ្នូ២០០៩, ឯកសារ D171/4/5 , ត្រង់លេខកថាខណ្ឌទី៩។

៧៤. ***អំពីទីភ្នាក់ងារ:*** នួន ជា លើកឡើងតវ៉ាថា លក្ខណៈដែលខុសក្នុងការស៊ើបសួរគឺមានភាពជាក់ស្តែង ដែលមកពីការសម្រេចរបស់ កសចស លើសំណើសុំកិច្ចស៊ើបសួររបស់គាត់ទាំង២៦(RIAs) ហើយថែមទាំងពោលអះអាងផងដែរថា ការស្តាប់ចម្លើគឺត្រូវបានធ្វើឱ្យខូចដោយកំហុសធ្ងន់ធ្ងរ ដែលដោយសារតែកំហុសនេះកសចសត្រូវបានស្តីបន្ទោសដោយ អបជ[201]។ ការលើកឡើងនេះក៏មានការយល់ខុសដែរ។ ក្នុងបញ្ហាដែលបានលើកឡើងដោយ នួន ជា នោះ គឺ អបជ មិនបានស្តីបន្ទោសចំពោះ កសចស អំពីវិធីសាស្ត្រនៃការស៊ើបសួររបស់កសចសនោះទេ ហើយក៏មិនបានធ្វើសេចក្តីសន្និដ្ឋានថា សំណើសុំកិច្ចស៊ើបសួរត្រូវបានបដិសេធចោលដោយខុស "ទាំងមូល"នោះដែរ។ អង្គបុរេជំនុំជម្រះកាលពីដំបូងបានសម្រេចថា កសចស ចាំបាច់ត្រូវតែផ្តល់នូវហេតុផលឱ្យបានលំអិតជាងនេះអំពីសេចក្តីសម្រេចរបស់ខ្លួនក្នុងការបដិសេធនូវកិច្ចស៊ើបសួរមួយចំនួន តែផ្ទុយទៅវិញ បានបដិសេធលើបណ្តឹងឧទ្ធរណ៍[202]។

៧៥. ក្នុងករណីណាក៏ដោយ ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួននៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួររបស់ នួន ជា ក៏ដូចជា សេចក្តីសំរេចរបស់ កសចស និង អបជ គឺគ្រាន់តែដើម្បីឱ្យបង្ហាញឱ្យឃើញថា ដំណើរការនៃនីតិវិធីគឺមានភាពត្រឹមត្រូវតែប៉ុណ្ណោះ[203]។ ឧទាហរណ៍ដូចជា អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ស្តីពីឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ (SMD) អបជ បានយល់ព្រមជាមួយមេធាវីការពារក្តីថា កសចស បានធ្វើការបកស្រាយដោយមិនត្រឹមត្រូវអំពីកាតព្វកិច្ចរបស់

---

[201] អញ្ញត្រកម្មបឋមរបស់ នួន ជា, កថាខណ្ឌទី១៨។

[202] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ដែលប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំឱ្យស្តាប់ចម្លើយសាក្សីរបស់ នួន ជា (ឯកសារលេខ D318, D319, D320, D336, D338, D339 និង D340), ចុះថ្ងៃទី១៦ មិថុនា ២០១០, ឯកសារលេខ D375/1/4 ។ សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍និងដីកាសន្និដ្ឋានបន្ថែមក្រោយៗទៀតក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើសំណើរបស់ នួន ជា ដែលស្នើសុំឱ្យស្តាប់ចម្លើយសាក្សី (ឯកសារលេខ D318, D319, D320, D336, D338, D339 និង D340), ចុះថ្ងៃទី២០ កញ្ញា ២០១០, ឯកសារលេខ D375/1/8។

[203] In fact, Nuon Chea recently pointed to the PTC's routine application of Rule 21 to safeguard his interests for "legal certainty, transparency and fairness of proceedings." Request to Trial Chamber to Order Resumption of Detention Interviews, 17 March 2011, E66, para. 9.

ខ្លួនក្នុងការស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ[204]។ ក៏ប៉ុន្តែអង្គបុរេជំនុំជម្រះ ក៏បានរកឃើញផងដែរថា សំណើរបស់មេធាវីការពារក្តីដែលសុំឱ្យ កសចស ធ្វើការស្រាវជ្រាវរកភស្តុតាងដោះបន្ទុកដែលមិនមានការកំណត់ច្បាស់នៅក្នុង SMD ទាំងមូល គឺមិនបានបំពេញគ្រប់ទៅតាមលក្ខខណ្ឌដែលតម្រូវឱ្យមានភាពជាក់លាក់ និងការទាក់ទងគ្នា ហើយដែលហេតុនេះ ការដែល កសចស បានធ្វើការបដិសេធសំណើនេះ គឺជាការត្រឹមត្រូវ[205]។ បន្ទាប់ពីសេចក្តីសម្រេចចិត្តនេះ នួន ជា បានសំរេចថានឹងមិនធ្វើសំណើសុំ ជាក់លាក់ទាក់ទងនឹង SMDនេះ តទៅទៀតឡើយ។

៧៦. ***អំពីវិធីសាស្ត្រស្វែងរកភស្តុតាងដែលមានភាពលំអៀង៖*** ក្នុងការដែលចោទថាមានភាពលំអៀងចំពោះរូបគាត់ ជាថ្មីម្តងទៀតគឺ នួន ជា ខកខានមិនបានចង្អុលភស្តុតាងទៅរក ភស្តុតាងណាមួយដែលគាំទ្រចំពោះការពោលអះអាងរបស់គាត់នោះទេ។ ទីមួយ គឺគាត់លើកយោងអំពីការបរាជ័យនៃពាក្យសុំប្តឹងជំទាស់ចិត្តលោកចៅក្រម Lemonde របស់គាត់[206]។ អង្គបុរេជំនុំជម្រះ បានរកឃើញអំពីអង្គហេតុដែលបានចោទប្រកាន់នានាដោយមេធាវីការពារក្តី និងដែលបានលើកឡើងសារជាថ្មីនៅក្នុងអញ្ញត្រកម្មបឋមនេះ ដែលមិនគ្រប់គ្រាន់ដើម្បីបង្ហាញភស្តុតាងអំពីវិធីសាស្ត្រដែលលំអៀងនៃកិច្ចស៊ើបសួរនោះទេ[207]។ នួន ជា ក៏លើកឡើងយោងផងដែរទៅលើការចែកចាយផ្ទៃក្នុងនៅក្នុងរង្វង់ កសចស នូវឯកសារមួយបានបង្កើតឡើងដោយសមាជិកបុគ្គលិកម្នាក់របស់ កសព (OCP)[208]។ ជាថ្មីម្តងទៀត បញ្ហានេះមិនគាំទ្រដល់អញ្ញត្រកម្មបឋមទេ ដូចដែលបានឆ្លុះបញ្ចាំងនៅ

[204] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ដែលជំទាស់នឹងដីកាសម្រេចលើសំណើដែលសុំឱ្យស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសារនៅរួមក្នុងកុំព្យូទ័រ (SMD), ចុះថ្ងៃទី១៨ វិច្ឆិកា ២០០៩, ឯកសារលេខ D-164/4/13, កថាខណ្ឌទី៣៨។

[205] ដូចគ្នានឹងខាងលើ ត្រង់កថាខណ្ឌទី៤៤។

[206] អញ្ញត្រកម្មបឋមរបស់ នួន ជា, កថាខណ្ឌទី១៩។

[207] ដីកាសម្រេចលើសំណើរបស់ នួន ជាដែលសុំប្តឹងជំទាស់ចិត្តលោកចៅក្រម Marcel Lemonde, ចុះថ្ងៃទី២៣ មីនា ២០១០ , អបជ០៥ , កថាខណ្ឌទី១៨-២៥។

[208] អញ្ញត្រកម្មបឋមរបស់ នួន ជា, កថាខណ្ឌទី១៩។

ក្នុងសេចក្តីសម្រេចនាពេលថ្មីៗនេះរបស់ អបជ ដើម្បីដោះស្រាយលើបញ្ហានេះ[209]។ គ្មានការរកឃើញភាពលំអៀងណាមួយត្រូវបានធ្វើឡើង អំពីទំនាក់ទំនងទៅក្រុម Lemonde ឬ កសចស នោះទេ នៅក្នុងរយៈពេលនៃដំណើរការនីតិវិធីទាំងនេះ។

៧៧. ជាសរុបរួមមក សំណើរបស់ នួន ជា ដែលសុំឱ្យបញ្ឈប់ការចោទប្រកាន់ ត្រូវតែបដិសេធចោល ព្រោះដោយសារអង្គហេតុនានាដែលបានបញ្ជូនមកត្រូវបានតុលាការពិនិត្យពិចារណារួចហើយ និងការតវ៉ាអំពីថាមានកំហុសនៅក្នុងកិច្ចស៊ើបសួរក៏ត្រូវបានច្រានចោលហើយដែរ។ នៅក្នុងពាក្យសុំនេះ មិនមានលើកឡើងអំពីអង្គហេតុណាថ្មី ឬមួយក៏អនុញ្ញាតឱ្យធ្វើការពិនិត្យសារជាថ្មីឡើងវិញលើអង្គហេតុទាំងឡាយដែលមានស្រាប់នោះទេ។ ដូចដែល អង្គបុរេជំនុំជម្រះ បានថ្លែងរួចហើយ ក្នុងការច្រានចោលនូវបណ្តឹងឧទ្ធរណ៍របស់ អៀង ធិរិទ្ធ ដែលប្រឆាំងនឹងដីកាសម្រេចបដិសេធលើសំណើរបស់គាត់ដែលសុំឱ្យផ្អាកដំណើរការនីតិវិធី។

> "ភស្តុតាងដែលដូចគ្នាបេះបិទដែលបានបង្ហាញនៅក្នុងករណីរឿងបច្ចុប្បន្ននេះ ដែលគាំទ្រចំពោះការចោទប្រកាន់ដដែលនោះ គឺមិនអាចបំពេញគ្រប់គ្រាន់នូវចំណុចពិសេសតាមលក្ខខណ្ឌតម្រូវដ៏ខ្ពស់ក្នុងការចាប់ផ្តើមដែលត្រូវបានអនុវត្តសម្រាប់ធ្វើការពិនិត្យឡើងវិញទៅលើការចោទប្រកាន់នានាអំពីការរំលោភលើនីតិវិធីបានតទៅទៀតឡើយ។ មិនមានបញ្ហាណាថ្មីៗទៀតត្រូវបានលើកឡើងទេ ហើយ អបជ នឹងមិនធ្វើការពិនិត្យឡើងវិញជាថ្មីម្តងទៀតលើសេចក្តីសំរេចនានាកាលពីមុនរបស់ខ្លួននោះឡើយ"[210]។

៧៨. រីឯចំពោះបញ្ហាតែមួយគត់ ដែលនៅទីបញ្ចប់មិនទាន់បានសម្រេចនៅឡើយ (គឺបញ្ហាអំពីសាក្សីដែលបានស្នើសុំ) ពាក្យសុំមួយដែលចោទថា ការជ្រៀតជ្រែកនៅក្នុងសវនាការជំនុំជម្រះក្តីដោយយុត្តិធម៌

[209] ដីកាសម្រេចជាការសំងាត់បំផុតរបស់អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី៧ មីនា២០១១, អបជ០៨, កថាខណ្ឌទី៨។

[210] សេចក្តីសម្រេចស្តីពីការរំលោភលើនីតិវិធី (បណ្តឹង) របស់ អៀង ធីរិទ្ធ, កថាខណ្ឌទី៣៦។

00655398



គឺជាការលើកឡើងមុនពេលពេកហើយ។ គ្មានអ្វីដែលរាំងមិនឱ្យ នួន ជា អនុវត្តសិទ្ធិរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះឡើយ រួមទាំងការស្វែងរកសុំឱ្យមានឧបាស្រ័យសមស្របផង ដែលអាចចង្អុលទៅរកសេចក្តីកង្វល់ពីបញ្ហានីតិវិធីត្រឹមត្រូវតាមច្បាប់ ដោយជំទាស់នឹងករណីចោទប្រកាន់ និងដោយសូមស្នើនូវភស្តុតាងរបស់គាត់វិញ[211]។

៧៩. សំខាន់ជាងនេះ ទោះបីជាពិនិត្យពិចារណាលើអង្គសេចក្តីក៏ដោយក៏ អញ្ញត្រកម្មបឋមរបស់ នួន ជា ខកខានមិនបានបង្ហាញថា គាត់បានទទួលរងការឈឺចាប់ដោយសារការរំលោភសិទ្ធិរបស់គាត់ដែលជាការបំពេញគ្រប់គ្រាន់ តាមលក្ខខណ្ឌតម្រូវយ៉ាងខ្ពស់នៃចំណុចចាប់ផ្តើមដែលអាចអនុវត្តបានចំពោះសំណើគាត់។ ជាការច្បាស់លាស់ណាស់ថា អង្គហេតុដែលបានពិភាក្សាខាងលើនេះគឺមិនគាំទ្រដល់សេចក្តីសន្និដ្ឋានដែលថា វិធីដំណើរការនៃការស៊ើបសួរ គឺមានកំហុសជាមូលដ្ឋាន ឬមានភាពលំអៀងប្រឆាំងនឹង នួន ជា ។ រីឯជនជាប់ចោទវិញ អាចនឹងមិនពេញចិត្តអំពីថា ការស៊ើបសួរដែលមានភាពលំអៀង គឺបាននាំឱ្យភស្តុតាងត្រូវបានគ្របដណ្តប់ទាំងស្រុងទៅដោយភស្តុតាងដាក់បន្ទុក ដែលមិនបើកឱ្យគាត់មានសិទ្ធិស្វែងរកសុំឱ្យបញ្ឈប់ការចោទប្រកាន់បាន។

## ង. នីត្យានុកូលភាពនៃវិធានផ្ទៃក្នុង អវតក និងដីកាត្រៀមរៀបចំសវនាការ

៨០. នៅក្នុងអញ្ញត្រកម្មរួមបញ្ចូលគ្នារបស់គាត់ នួន ជា ធ្វើអញ្ញត្រកម្មចំនួន៣ ដោយអនុលោមតាមវិធាន ៨៩.១.គ៖ ទី១) ការអនុម័ត និងវិសោធនកម្មលើវិធាននានានៅក្នុងសម័យប្រជុំ "ពេញអង្គ" របស់

[211] ដូចដែលអង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងត្រឹមត្រូវលើបណ្តឹងឧទ្ធរណ៍របស់ នួន ជាទាក់ទងនឹងការចោទប្រកាន់អំពីអំពើពុករលួយផ្នែករដ្ឋបាល៖ "ជនត្រូវចោទ នៅក្នុងអម្លុងពេលដំណើរការជំនុំជម្រះក្តី អាចស្នើសុំសួរដេញដោលសាក្សីរបស់ភាគីម្ខាងទៀតបាន បើសិនជាពួកគេមានកង្វល់ធ្ងន់ធ្ងរអំពីភស្តុតាងជាលាយលក្ខណ៍អក្សរ "។ នៅពេលធ្វើសេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃភស្តុតាងនៅចំពោះមុខខ្លួន អង្គជំនុំជម្រះនីមួយៗមានសិទ្ធអំណាចដែលជាប់មកជាមួយស្រាប់ក្នុងការធ្វើការស៊ើបអង្កេតបន្ថែម បើសិនជាបញ្ហាស្តីពីភាពត្រឹមត្រូវយុត្តិធម៌នៃការជំនុំជម្រះក្តីបានលេចឡើងទាក់ទងនឹងភស្តុតាងណាមួយ"។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំកិច្ចស៊ើបសួរលើកទី១១, ចុះថ្ងៃទី១៨ សីហា ២០០៩,ឯកសារលេខ D158/5/1/15 , ត្រង់កថាខណ្ឌទី៣៧។

00655399



អវតក គឺគ្មានធម្មនុញ្ញភាព និងហួសដែនអំណាច[212](ultra vires) ទី២) ការអនុវត្តជាខាងក្រោយទៀតនូវវិធានទាំងនេះនឹងមានការរំលោភទៅលើសិទ្ធិរបស់ នួន ជា[213] និងទី៣) ដីកាបង្គាប់ស្តីពីការរៀបចំសវនាការ[214] ត្រូវបានចេញដោយអនុលោមតាមវិធាននានាដែលហួសដែនអំណាច[215] ។

៨១. ទីមួយ អញ្ញត្រកម្មទាំងនេះទាក់ទិននឹងការអនុម័ត និងវិសោធនកម្មលើវិធានផ្ទៃក្នុងនានានាពេលកន្លងមក និងការអនុវត្តក្រោយមកទៀតនូវវិធានទាំងនេះ គឺមិនអាចទទួលយកបាន។ នេះគឺដោយសារវិធាន៨៩.១.គ អនុញ្ញាតសម្រាប់តែ អញ្ញត្រកម្មបឋមទាំងឡាយណាដែលទាក់ទងទៅនឹង "មោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកា ដំណោះស្រាយ" ប៉ុណ្ណោះ[216]។ វិធាន៨៩.១.គ មិនបានចែងអំពីមូលដ្ឋានណាសម្រាប់ នួន ជា ធ្វើឱ្យវិធានផ្ទៃក្នុងទាំងមូលក្លាយជាអសារឥតការ។

៨២. ទោះបីការជំទាស់ពីសុពលភាពនៃវិធានផ្ទៃក្នុងមិនអាចទទួលយកបានក៏ដោយ ក៏សហព្រះរាជអាជ្ញាសង្កេតឃើញថា អង្គបុរេជំនុំជម្រះបានពិចារណា និងបញ្ជាក់អះអាងអំពីសុពលភាពនៃវិធានផ្ទៃក្នុងដោយសម្រេចថា វិធានផ្ទៃក្នុង "ជាលិខិតុបករណ៍ចំបងដែលយើងគួរនឹងយកមកពិនិត្យមើល ក្នុងការកំណត់អំពីនីតិវិធី នៅចំពោះមុខ អ.វ.ត.ក"[217] ។ អង្គបុរេជំនុំជម្រះ បានលើកយោងមាត្រា ១២(១) នៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក ដែលអនុញ្ញាតឱ្យតុលាការបញ្ចូលវិធាននីតិវិធី ពីប្រភពអន្តរជាតិ នៅពេលណាដែល "ច្បាប់កម្ពុជាមិនអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ

---

[212] អញ្ញត្រកម្មរបស់ នួន ជា, កថាខណ្ឌទី ៦៦-៦៩ ។

[213] អញ្ញត្រកម្មរបស់ នួន ជា, កថាខណ្ឌទី ៧០-៧១ ។

[214] អង្គជំនុំជម្រះសាលាដំបូង, "ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ", ថ្ងៃទី១៧ មករា ២០១១, **E51/3** ("ដីកា បង្គាប់ស្តីពីការរៀបចំសវនាការ") ។

[215] អញ្ញត្រកម្មរបស់ នួន ជា, កថាខណ្ឌទី ៧២ ។

[216] វិធានផ្ទៃក្នុង ៨៩.១.គ ។

[217] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, ថ្ងៃទី២៦ សីហា ២០០៨, D55/I/8, កថាខណ្ឌទី ១២-១៤ ("សាលដីកាបដិសេធពាក្យសុំមោឃភាពរបស់ នួន ជា") ។

ឬមានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងនឹងភាពសមស្របគ្នា រវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ" ។ ដូចបានធ្វើការសន្និដ្ឋានដោយអង្គបុរេជំនុំជម្រះ អ.វ.ត.ក ត្រូវបានអនុញ្ញាតយ៉ាងច្បាស់តាមមាត្រា១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក នេះ និងមាត្រា៣៣ថ្មី នៃ ច្បាប់ អ.វ.ត.ក អនុម័ត "ប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង ដែលពាក់ព័ន្ធនឹងកាលៈទេសៈពិសេសរបស់ អ.វ.ត.ក"[218] ។ នៅក្នុងដំណើរការនីតិវិធីនោះ មេធាវីការពារក្តីរបស់ នួន ជា ខ្លួនឯងផ្ទាល់បានទទួលស្គាល់ថា "ការអនុម័តវិធានសមស្របមួយចំនួនបន្ថែមទៀត នៅពេលណាដែលច្បាប់កម្ពុជាជាធរមានពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ"[219] ។

៨៣. នួន ជា លើកសំអាងថា ដីកាបង្គាប់ស្តីពីការរៀបចំសវនាការ គួរតែត្រូវបានទុកជាមោឃៈ ពីព្រោះវាត្រូវបានចេញដោយអនុលោមតាមវិធាននានាដែលហួសដែនអំណាច។ ទោះជាយ៉ាងដូច្នេះក៏ដោយមោឃភាព មិនត្រូវបានកំណត់ដោយមូលដ្ឋានដែលបានលើកឡើងចោទប្រកាន់លើដីកានោះតាមវិធាននានាដែលហួសដែនអំណាចនោះឡើយ។ ផ្ទុយទៅវិញ មោឃភាពអាចនឹងមានអត្ថិភាពកាលណាដីកាបង្គាប់ស្តីពីការរៀបចំសវនាការនោះ *មិនមាន* មូលដ្ឋានគតិយុត្តិទាល់តែសោះ។ និយាយម្យ៉ាងទៀតវិធានខ្លួនឯងផ្ទាល់ (per se) មិនមែនជាប្រភពច្បាប់សម្រាប់ជានីត្យានុកូលភាពនៃកិច្ចមួយតាមដំណើរការនីតិវិធីនោះទេ។ វាគឺជា ច្បាប់លក្ខន្តិកៈជាមូលដ្ឋាន មួយសម្រាប់ អវតក ដែលកិច្ចនានាតាមដំណើរការនីតិវិធីត្រូវមានមូលដ្ឋាននៅលើនោះ។ ជាផលវិបាក គោលបំណងនៃចម្លើយតបនេះ គឺមិនមែនដើម្បីពិនិត្យមើលពីនីត្យានុកូលភាព នៃវិធានទាំងនេះ (ដែលវាមិនពាក់ព័ន្ធ) នោះទេ ។ វាគឺដើម្បីពិនិត្យមើលថាតើមានប្រភពច្បាប់សម្រាប់កិច្ចនានា តាមដំណើរការនីតិវិធី ដែលបានស្នើសុំនៅក្នុងដីកាបង្គាប់ស្តីពីការរៀបចំសវនាការដែរឬទេ។ ទោះជាយ៉ាងដូច្នេះ ក៏

[218] សាលដីកាបដិសេធពាក្យសុំមោឃភាពរបស់ នួន ជា, កថាខណ្ឌទី ១៤ ។

[219] បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងចំពោះដីកាបដិសេធបណ្តឹងសុំមោឃភាព, ថ្ងៃទី២៥ កុម្ភៈ ២០០៨, D55/I/1, កថាខណ្ឌទី ១០ ។

00655401



ដោយបើអង្គជំនុំជម្រះសាលាដំបូង យល់ឃើញថាមានការចាំបាច់ត្រូវពិនិត្យមើលពីនីត្យានុកូលភាពនៃវិធានទាំងនេះនោះ សហព្រះរាជអាជ្ញា ស្នើថាត្រូវផ្តល់នូវកាលានុវត្តភាព មួយដល់សហព្រះរាជអាជ្ញា ដើម្បីធ្វើការឆ្លើយតបទៅនឹងបញ្ហានេះ ។

៨៤. ដីកាបង្គាប់ស្តីពីការរៀបចំសវនាការ ដែលបង្កើតបានជាប្រធានបទមួយនៃការជំទាស់ដែលមានចំណងជើងថា "ដីកាបង្គាប់ឱ្យដាក់សម្ភារៈដើម្បីរៀបចំសវនាការ" ត្រូវបានចេញនៅថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១១ ។ ដីកានេះតម្រូវឱ្យភាគីទាំងអស់ដាក់៖ ទី១) បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលមិនបានស្នើសុំស្វែងរកវិធានការការពារ ទី២) បញ្ជីឈ្មោះសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីថ្មីដែលបានស្នើសុំស្វែងរកវិធានការការពារ។ ទី៣) ព័ត៌មានពាក់ព័ន្ធនឹងសាក្សីអ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំទាំងអស់។ ទី៤) បញ្ជីអង្គហេតុដែលមិនជំទាស់រួមទាំងអង្គហេតុនានា ដែលអង្គជំនុំជម្រះបានវិនិច្ឆ័យរួចហើយ នៅក្នុងសំណុំរឿងលេខ ០០១, និងទី៥) បញ្ជីឯកសារ និងវត្ថុតាងនានា[220] ។ ដីកាបង្គាប់ស្តីពីការរៀបចំ សវនាការនេះមានមូលដ្ឋានជាបឋមនៅលើការអនុវត្តជាអន្តរជាតិដែលធ្វើការដោះស្រាយ លើករណីនានាដែលមានទំហំ និង ភាពស្មុគស្មាញដូចនេះ[221]។ ជាឧទាហរណ៍ វិធានស្តីពីភស្តុតាង និងនីតិវិធីសម្រាប់តុលាការ ICTY បានចែងពីលក្ខណ្ឌតម្រូវនានាស្រដៀងគ្នានេះសម្រាប់ឱ្យរដ្ឋអាជ្ញា និងជនជាប់ចោទធ្វើការដាក់បញ្ជីឈ្មោះសាក្សី បញ្ជីវត្ថុតាង សេចក្តីសង្ខេបចម្លើយសាក្សី សេចក្តីទទួលសារភាពដោយភាគីនានា និង បញ្ហានានាដែលជំទាស់ និងមិនជំទាស់[222] ។

---

[220] ដីកា បង្គាប់ស្តីពីការរៀបចំសវនាការ។

[221] ដំណើរការនីតិវិធីរៀបចំមុនសវនាការដែលស្រដៀងគ្នានេះ ត្រូវបានរកឃើញនៅក្នុងបទប្បញ្ញត្តិនានានៃវិធានស្តីពីភស្តុតាង និងនីតិវិធីនៅតាម អង្គជំនុំជម្រះ និងតុលាការអន្តរជាតិនានា ។ ជាឧទាហរណ៍ សូមមើលវិធាន ៦៥*ស្ទួនទីបី* (ង) និង ៦៥*ស្ទួនទីបី* (ឆ) នៃតុលាការ ICTY និង វិធាន ៧៣*ស្ទួន* និង ៧៣*ស្ទួនទីបី* នៃតុលាការ ICTR ។

[222] សូមមើលវិធាន ៦៥*ស្ទួនទីបី* ង.១ នៃវិធានស្តីពីភស្តុតាង និងនីតិវិធីសម្រាប់តុលាការ ICTY ។

៨៥. ការស្វែងរកការណែនាំពីវិធាននីតិវិធីនានានៅកម្រិតអន្តរជាតិ គឺត្រូវបានអនុញ្ញាតដោយមាត្រា៣៣ នៃច្បាប់ អវតក នៅក្នុងករណីដែលនីតិវិធីកម្ពុជាមិនមានចែងពីករណីពិសេសណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ។ ទោះជាយ៉ាងដូច្នេះក៏ដោយ ការសម្រេចបាននូវកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង គឺដើម្បីធានាថា ពួកគេបានអនុវត្តនូវយុត្តាធិការរបស់ខ្លួន ដោយស្របតាមបទដ្ឋានយុត្តិធម៌ ភាពត្រឹមត្រូវ និង នីតិវិធីត្រឹមត្រូវតាមច្បាប់ជាអន្តរជាតិ ដូចដែលបានចែងនៅក្នុងមាត្រា១៤ និង ១៥ នៃ ICCPR[223] ។

៨៦. នួន ជា បានថ្លែងថា ដីកាបង្គាប់ស្តីពីការរៀបចំសវនាការ គួរតែត្រូវបានទុកជាមោឃៈ។ លក្ខណៈវិនិច្ឆ័យសម្រាប់មោឃភាពត្រូវបានចែងដោយវិធាន៤៨ នៃវិធានផ្ទៃក្នុង ដែលចែងថា៖ “កិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការអាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ”។ អង្គបុរេជំនុំជម្រះ ធ្លាប់បានសម្រេចថា មោឃភាពលើកិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការ អាចកើតឡើងបានចំពោះការរំលោភសិទ្ធិរបស់ជនត្រូវចោទ ដែលត្រូវបានទទួលស្គាល់នៅក្នុង ICCPR ដោយហេតុថា ការរំលោភនោះ នឹងបង្គ្រប់បានជាកំហុសនីតិវិធី ហើយនិងប៉ះពាល់ដល់ផលប្រយោជន៍របស់ជនជាប់ចោទ[224] ។

៨៧. អាស្រ័យហេតុដូច្នេះ នៅក្នុងករណីនេះ ដើម្បីឱ្យមានមោឃភាពនៃកិច្ចតាមនីតិវិធីទាំង៥ ដែលមាននៅក្នុងដីកាបង្គាប់ស្តីពីការរៀបចំសវនាការ នួន ជា ត្រូវតែបង្ហាញថា៖ ទី១) កំហុសនីតិវិធីមានអត្ថិភាពនៅក្នុងការចេញដីកានេះ និងទី២) កំហុសនីតិវិធីនោះប៉ះពាល់ដល់សិទ្ធិរបស់ខ្លួន។ នួន ជា

---

[223] មាត្រា ៣៣ថ្មី នៃច្បាប់ អវតក ។

[224] អង្គបុរេជំនុំជម្រះ, “សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំ មោឃភាព”, ថ្ងៃទី២៦ សីហា ២០០៨, D55/I/8 ត្រង់កថាខណ្ឌទី ៤០ ។

មិនបានប្តឹងថា កិច្ចតាមនីតិវិធីនោះមានកំហុសនីតិវិធីនោះឡើយ។ ផ្ទុយទៅវិញ គាត់បានឯកភាពថា ឯកសារដែលបានដាក់រហូតមកដល់ពេលនេះ ដូចជា បញ្ជីឈ្មោះ និងសេចក្តីសង្ខេបពីសាក្សី (ផ្នែកទី១, ២ និង ៣ នៃដីកា) ដូចដែលបានតម្រូវដោយដីកាបង្គាប់ស្តីពីការរៀបចំសវនាការនេះ គឺត្រូវគ្នាទៅនឹងកាតព្វកិច្ចនានារបស់គាត់នៅក្រោមច្បាប់កម្ពុជា[225] ។

៨៨. នួន ជា បានផ្តល់នូវការពិចារណាពីហេតុផលដែលផ្ទុយទៅនឹងការដាក់ឯកសារនៅក្រោមផ្នែកទី១, ២ និង ៣ នៃដីកាបង្គាប់ស្តីពីការរៀបចំសវនាការ។ ម្យ៉ាងវិញទៀត គាត់បានថ្លែងថា ដីកាបង្គាប់នោះគ្មានមូលដ្ឋានគតិយុត្តិ តែគាត់បានថ្លែងម្យ៉ាងទៀតថា ដីកាបង្គាប់នោះ គឺស្របទៅនឹងកាតព្វកិច្ចរបស់ខ្លួនដែលថិតនៅក្រោមច្បាប់កម្ពុជា។ ដូចដែលបានបង្ហាញនៅខាងលើនេះ ដីកាបង្គាប់ស្តីពីការរៀបចំសវនាការនេះ គឺស្របទៅនឹងបទដ្ឋានអន្តរជាតិ ជាងស្របទៅនឹងច្បាប់កម្ពុជាទៅទៀត ដែលថាគេអាចបានទទួលយកវាបាន ដោយសារភាពស្រដៀងគ្នានៅក្នុងករណីរឿងនានានៅក្នុងកម្រិតអន្តរជាតិ និងភាពខុសគ្នានៅក្នុងករណីរឿងនានានៅក្នុងកម្រិតជាតិ ។

៨៩. ពាក់ព័ន្ធទៅនឹងផ្នែកទី៥ នៃ ដីកាបង្គាប់ស្តីពីការរៀបចំសវនាការនេះ ដែលបានស្នើសុំឱ្យដាក់បញ្ជីឯកសារ និងវត្ថុតាងនោះ វាមិនមានការប្តឹងនៅក្នុងអញ្ញត្រកម្មបឋមថាកិច្ចមួយនេះមានកំហុសនីតិវិធីឡើយ។ តាមអង្គហេតុពិត ផ្នែកទី៤ នៃ ដីកាបង្គាប់ស្តីពីការរៀបចំសវនាការ គឺជាផ្នែកតែមួយគត់ដែល នួន ជា បានលើក ឡើងយ៉ាងជាក់លាក់នៅក្នុងអញ្ញត្រកម្មរបស់គាត់តាមរយៈ **ឧបសម្ព័ន្ធ** ក។ ផ្នែកនេះ តម្រូវឱ្យភាគី នានាធ្វើជាបញ្ជីមួយស្តីពីអង្គហេតុទាំងឡាយណាដែលមិន

[225] នួន ជា, សេចក្តីសង្ខេបអំពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំ", ថ្ងៃទី២៣ កុម្ភៈ ២០១១, E9/10 ត្រង់កថាខណ្ឌទី ២ ។"Additionally, the Defence reiterates that it has filed a preliminary objection regarding the legality of the Rules. *(footnote removed)* While that objection does not specifically mention Rule 80 (3) (a), it does suggest that such provision (and by extension, paragraph six of the Preparation Order) is without legal basis. *(footnote removed)* In any event, the Defence submits that the material filed to date is consistent with its obligations under Cambodian law and reserves its right to continue to challenge any Rule that unlawfully departs from such established domestic procedure. *(footnote removed).*"

ជំទាស់[226]។ នួន ជា បានជជែកតវ៉ាថា ការណ៍នេះគឺបានរំលោភលើសិទ្ធិក្នុងការឋិតនៅស្ងៀមស្ងាត់របស់គាត់ សច្ចធារណ៍នៃនិរទោស និង បន្ទុកនៅលើសហព្រះរាជអាជ្ញាក្នុងការបង្ហាញពីករណីរឿងនេះប្រឆាំងនឹងគាត់[227]។ ការជជែកតវ៉ានេះ គឺមិនពិតទេ។ ដីកាបង្គាប់ស្តីពីការរៀបចំសវនាការមិនទាមទារឱ្យ នួន ជា ឯកភាពទៅនឹង អង្គហេតុនានាជាមួយនឹងសហព្រះរាជអាជ្ញានោះទេ (ដែលជាការរំលោភយ៉ាងច្បាស់ទៅលើសិទ្ធិក្នុងការឋិតនៅស្ងៀមស្ងាត់)។ ផ្ទុយទៅវិញ វាបានដំណើរការទៅដោយតម្រូវឱ្យ នួន ជា និងសហព្រះរាជអាជ្ញា ធ្វើការផ្តល់ជូននូវអង្គហេតុដែលមិនជំទាស់ទាំងឡាយណាក្នុងករណីដែលពួកគេទាំងអស់នោះបានឯកភាពតែប៉ុណ្ណោះ។ ជាផលវិបាក គឺវាមិនមានការរំលោភទៅលើសិទ្ធិដែលបានបញ្ជាក់ណាមួយរបស់គាត់ឡើយ ហើយហេតុដូច្នោះការសាកល្បងអំពីមោឃភាពមិនមានឡើយ ។

៩០. ជាផលវិបាក ដូចដែល នួន ជា បានទទួលស្គាល់យ៉ាងច្បាស់លាស់ថា នីត្យានុកូលភាពនៃសំណើទី១, ២ និង ៣ ក្នុង ដីកាបង្គាប់ស្តីពីការរៀបចំសវនាការនេះ និងមិនបានធ្វើការយោងទៅដល់សំណើទី៥ ថាមានបញ្ហាកំហុសនីតិវិធីក្នុងការប៉ះពាល់ដល់ជនចាប់ចោទ គឺវាមិនទាក់ទងទេ ដោយហេតុថា មិនមានកំហុសនីតិវិធីណាមួយត្រូវបានលើកឡើងចោទប្រកាន់នោះទេ។ រីឯសំណើទី៤នៃដីកាដីកាបង្គាប់ស្តីពីការរៀបចំសវនាការ នួន ជា មិនបានបង្ហាញថាតើវាមានកំហុសនីតិវិធីតាមរបៀបណាមួយនោះឡើយ ថាតើវាបានធ្វើឱ្យមានការប៉ះពាល់ដល់រូបគាត់តាមរបៀបណា។ ការប៉ះពាល់ដែល នួន ជា បានលើកឡើងចោទប្រកាន់ថាបានទទួលរងនោះ គឺពិតជាគ្មានមូលដ្ឋានទាំងស្រុង ដោយហេតុថា គាត់បានយល់ខុសទៅលើគោលបំណង និងប្រសិទ្ធភាពនៃសំណើសុំឱ្យដាក់បញ្ជីអង្គហេតុដែលមិនជំទាស់។ តាមវិធីណាមួយក៏ដោយ សំណើបែបធ្វើឱ្យមានការប៉ះពាល់

[226] វិធាន ៨០.៣.ង នៃវិធានផ្ទៃក្នុង ។

[227] អញ្ញត្រកម្មរបស់នួន ជា, ឧបសម្ព័ន្ធ ក ត្រង់ ក-១ ។

ដល់សិទ្ធិរបស់ជនជាប់ចោទ ហើយវាក៏គ្មានកំហុសនីតិវិធីជាដំបូងនៅក្នុងបរិបទនៃមាត្រា៣៣ថ្មី នៃច្បាប់ អវតក នោះឡើយ ។

## III. សេចក្តីសន្និដ្ឋាន

៩១. អាស្រ័យដោយមូលហេតុដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញា សូមសន្និដ្ឋានថា អញ្ញត្រកម្មបឋមរបស់ជនជាប់ចោទទាំងអស់គួរបានបដិសេធចោល ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ | លោកស្រី ជា លាង<br>សហព្រះរាជអាជ្ញា | | [signature] |
| | លោក Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |